សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ដំណើរការរឿងក្តីព្រហ្មទណ្ឌនៅសាលាដំបូងខេត្តបាត់ដំបង

ស្រាវជ្រាវពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០១៦ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៦

តាក់តែងឡើងដោយ
និស្សិតឈ្មោះ **ក. លិ ស៊ីវទាន**
**ក. សុក្រាត សុជាតា**

សាស្ត្រាចារ្យណែនាំ
លោក **ជួន ប៊ុនធី**

ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ
ជំនាន់ទី ១៦

ឆ្នាំចូលសិក្សា ២០១២
ឆ្នាំសរសេរសារណា ២០១៦

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំ **លិ ស៊ីវឆាន** និង **សូត្រាត សុជាតា** ជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រឆ្នាំទី៤ ជំនាន់ទី១៦ ឆ្នាំសិក្សា ២០១៥-២០១៦។

**សូមថ្លែងអំណរគុណ**

– ចំពោះ **មាតាបិតា** ដែលលោកអ្នកមានគុណបានផ្តល់កំណើតដល់កូនៗ បីបាច់ថែរក្សា ប្រៀនប្រដៅទូន្មាន តែងផ្តល់ដំបូន្មានល្អៗកូនៗធ្វើជាកូនល្អ សិស្សល្អ និងជាពលរដ្ឋល្អក្នុងសង្គម។ មិនថាលំបាក ក្តៅ ឬរងាយ៉ាងណាលោកទាំងពីរអាចតស៊ូពុះពារបានគ្រប់ឧបសគ្គដើម្បីកូនៗ គុណលោកទាំងពីរធ្ងន់ជាងប្រថពី និងធំធេងគ្មានអ្វីប្រៀបផ្ទឹមបាន។ កូនៗនឹងប្រណិប័តន៍តបស្នងចំពោះគុណូបការៈព្រហ្មវិហារធម៌នៃលោកទាំងពីរដោយសេចក្តីគោរព និងស្រលាញ់យ៉ាងជ្រាលជ្រៅបំផុត។

– ចំពោះ **អគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលជាប្រមុខរាជរដ្ឋាភិបាល ដោយលោកបានដឹកនាំប្រទេសជាតិឱ្យមានភាពរុងរឿង សន្តិភាព និងរីកចម្រើនលើគ្រប់វិស័យ។

– ចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ** សាកលវិទ្យាធិការរង លោកព្រឹទ្ធបុរស-រង លោកលោកស្រីសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានផ្តល់នូវជាចំណេះវិជ្ជាតាំងពីឆ្នាំមូលដ្ឋានរហូតដល់ឆ្នាំបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រនេះផងដែរ។

– ចំពោះលោកសាស្ត្រាចារ្យ **ជួន ម៉ុនធី** ដែលជាសាស្ត្រាចារ្យណែនាំបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការដឹកនាំ ពន្យល់ និងកែចំណុចខ្វះខាតនៃការសរសេរនេះតាំងពីដើមរហូតដល់យើងខ្ញុំទទួលបាននូវលទ្ធផលជាស្ថាពរ។

– ចំពោះលោកចៅក្រម **លិ សុខា** ជាចៅក្រមនៃសាលាដំបូងខេត្តបាត់ដំបង ដែលលោកបានផ្តល់ជាឯកសារ និងការពិគ្រោះយោបល់ដល់ការសរសេរសារណារបស់យើងខ្ញុំ។

ជាចុងបញ្ចប់ យើងខ្ញុំគោរពជូនពរដល់លោកអ្នកមានគុណ ប្រមុខរដ្ឋាភិបាល ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោក លោកស្រីសាស្ត្រាចារ្យ និងលោកចៅក្រមសូមឱ្យទទួលនូវបានពុទ្ធិពរទាំង ៤ប្រការ គឺអាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីបានបញ្ចប់ការសិក្សាអស់រយៈពេល ៤ ឆ្នាំ ផ្នែកនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សាកលវិទ្យាល័យបានផ្តល់ឱកាសឱ្យយើងខ្ញុំទាំងពីរអាចបានរួមគ្នាជាដៃគូសរសេរសារណាបញ្ចប់ការសិក្សាទុកជាស្នាដៃ បន្ទាប់ពីយើងខ្ញុំទាំងពីរបានចំណាយពេលក្នុងការខិតខំក្រេបយកចំណេះវិជ្ជា សិក្សាស្រាវជ្រាវ និងការដកបទពិសោធន៍ដ៏ល្អៗមានអត្ថប្រយោជន៍ទុកជាគោលគំនិតបន្ថែមពីមេរៀនរបស់លោក លោកស្រីសាស្ត្រាចារ្យដែលបានបង្ហាត់បង្រៀន ពន្យល់បកស្រាយរាល់ចម្ងល់របស់និស្សិតយ៉ាងក្បោះក្បាយ និងអស់ពីកម្លាំងកាយចិត្ត។

ចំពោះការសិក្សាផ្នែកបរិញ្ញាបត្រនីតិសាស្ត្រនេះ យើងខ្ញុំបានទទួលចំណេះដឹងពីវិស័យនានាជាច្រើន ប៉ុន្តែយើងខ្ញុំមានចំណាប់អារម្មណ៍យ៉ាងខ្លាំងទៅលើវិស័យយុត្តាធិការនៅព្រះរាជាណាចក្រកម្ពុជា ហេតុដូចនេះ យើងខ្ញុំក៏បានសម្រេចមូលមតិរួមគ្នាជ្រើសរើសយកប្រធានបទស្តីពី " **ដំណើរការរឿងក្តីព្រហ្មទណ្ឌនៅសាលាដំបូងខេត្តបាត់ដំបង** " មកធ្វើការបកស្រាយឱ្យបានយល់ដឹងបន្ថែមទៀតពីការអនុវត្តចំពោះរឿងក្តីព្រហ្មទណ្ឌ ដែលកើតមានឡើងនៅក្នុងខេត្តបាត់ដំបងនេះផ្ទាល់តែម្តង ដើម្បីឱ្យដឹងថាតើកាលណាមាននូវរឿងក្តីព្រហ្មទណ្ឌមួយកើតឡើង តើមន្ត្រីដែលមានសមត្ថកិច្ចពាក់ព័ន្ធត្រូវមានវិធានការក្នុងការចាត់ចែងលើរឿងក្តីនោះទៅតាមនីតិវិធីយ៉ាងដូចម្តេចខ្លះ ហើយថាតើរឿងក្តីព្រហ្មទណ្ឌនោះនឹងត្រូវបានបញ្ចប់ទៅវិញយ៉ាងដូចម្តេច។

ដូចនេះ ក្នុងនាមយើងខ្ញុំទាំងពីរជាអ្នកចងក្រងនូវស្នាដៃមួយនេះឡើងដោយមានការខិតខំប្រឹងប្រែងសិក្សាស្រាវជ្រាវ និងស្វែងរកនូវឯកសារមួយចំនួនផងដែរនោះ យើងខ្ញុំធ្វើឡើងក្នុងគោលបំណងដើម្បីទទួលបានចំណេះដឹង និងបទពិសោធន៍ថ្មីមុននឹងបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះក៏ដូចជាចង់បន្សល់ទុកជាស្នាដៃដល់មិត្តនិស្សិតជំនាន់ក្រោយសម្រាប់សិក្សាស្រាវជ្រាវ។ យើងខ្ញុំក៏សូមអភ័យទោសទុកជាមុនបើសិនជាស្នាដៃនេះមានកំហុសខ្វះខាត ឬពុំទាន់មានភាពក្បោះក្បាយត្រង់ចំណុចណាមួយនោះ យើងខ្ញុំស្វាគមន៍នូវមតិរិះគន់ដើម្បីស្ថាបនាពីសំណាក់លោក លោកស្រីសាស្ត្រាចារ្យ មិត្តនិស្សិត មិត្តអ្នកអានទាំងអស់ដោយភាពសោមនស្សរីករាយ ដើម្បីអាចឱ្យយើងខ្ញុំអាចមានឱកាសធ្វើការកែតម្រូវឱ្យស្នាដៃមួយនេះកាន់តែមានភាពល្អប្រសើរជាងមុនផងដែរ។

# មាតិកា


ទំព័រ

**សេចក្ដីផ្ដើម** ........................................ ១

**ជំពូកទី១៖ ស្ថានភាពទូទៅនៃសាលាដំបូងខេត្តបាត់ដំបង**

**ផ្នែកទី១៖ ប្រវត្តិនៃការកកើតសាលាដំបូងខេត្តបាត់ដំបង** ........................................ ៣

**ផ្នែកទី២៖ សមាសភាព និងតួនាទីភារកិច្ច** ........................................ ៤

១.សមាសភាពនៃសាលាដំបូងខេត្តបាត់ដំបង ........................................ ៤

២.តួនាទីភារកិច្ច ........................................ ៥

**ជំពូកទី២៖ ដំណាក់កាលនៃការស៊ើបអង្កេតក្នុងរឿងក្ដីព្រហ្មទណ្ឌ**

**ផ្នែកទី១៖ ការស៊ើបអង្កេតបទល្មើសជាក់ស្ដែង** ........................................ ១០

១.លក្ខខណ្ឌនៃការបើកការស៊ើបអង្កេតករណីជាក់ស្ដែង ........................................ ១១

១.១.ដែនកំណត់ ........................................ ១១

១.២.ការកំណត់អំពីស្ថានភាពជាក់ស្ដែង ........................................ ១២

២.នីតិវិធីការស៊ើបអង្កេត ........................................ ១៦

២.១.ថិរវេលានៃការស៊ើបអង្កេតករណីជាក់ស្ដែង ........................................ ១៦

២.២.កិច្ចស៊ើបអង្កេត ........................................ ១៦

២.២.១.ការចុះដល់ទីកន្លែងកើតហេតុ ........................................ ១៦

២.២.២.ការឆែកឆេរ និងការចាប់យកវត្ថុតាង ........................................ ១៧

២.២.៣.ការស្ដាប់ចម្លើយ ........................................ ១៩

២.២.៤.ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ ........................................ ១៩

២.២.៥.ការស្ដាប់ការសន្ទនា ........................................ ២០

២.២.៦.ការឃាត់ខ្លួន ........................................ ២០

២.៣.ការបញ្ជូនកំណត់ហេតុ ភស្តុតាង និងបុគ្គលដែលត្រូវបញ្ជូនទៅដល់ ព្រះរាជអាជ្ញា ........................................ ២២

**ផ្នែកទី២៖ ការស៊ើបអង្កេតបឋម** ........................................ ២២

## ជំពូកទី៣៖ ដំណាក់កាលការចោទប្រកាន់ក្នុងរឿងក្ដីព្រហ្មទណ្ឌ

**ផ្នែកទី១៖ លក្ខខណ្ឌនៃការចោទប្រកាន់** ........ ២៥
១.ការពិនិត្យទៅលើគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ ........ ២៦
២.សេរីភាពក្នុងការសម្រេចរបស់ព្រះរាជអាជ្ញា ........ ២៦
**ផ្នែកទី២៖ សេចក្ដីសម្រេចរបស់អយ្យការ** ........ ២៧
១.ការតម្កល់រឿងទុកឥតចាត់ការ ........ ២៧
២.ការចោទប្រកាន់ ........ ២៨
២.១.ការបើកការស៊ើបសួរ ........ ២៩
២.២.ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ........ ៣០
២.៣.នីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម ........ ៣២

## ជំពូកទី៤៖ ដំណាក់កាលការស៊ើបសួរក្នុងរឿងក្ដីព្រហ្មទណ្ឌ

**ផ្នែកទី១៖ ការចាប់ផ្ដើមបើកការស៊ើបសួរ និងការបិទការស៊ើបសួរ** ........ ៣៤
១.ការបើកការស៊ើបសួរ ........ ៣៤
១.១.បែបបទនៃការស៊ើបសួរ ........ ៣៤
១.១.១.កិច្ចសម្ងាត់នៃការស៊ើបសួរ ........ ៣៤
១.១.២.វិសាលភាពនៃការស៊ើបសួរ ........ ៣៤
ក.សមត្ថកិច្ចតាមសាច់រឿង ........ ៣៤
ខ.សមត្ថកិច្ចតាមដែនដី ........ ៣៥
១.២.មូលហេតុនៃការបើកការស៊ើបសួរ ........ ៣៦
១.២.២.ការបញ្ជូនរឿងឱ្យស៊ើបសួររបស់អយ្យការ ........ ៣៦
១.២.២.ការទទួលពាក្យបណ្ដឹងពីជនរងគ្រោះ ........ ៣៧
២.ការបិទការស៊ើបសួរ ........ ៣៩
២.១.ការជូនដំណឹងដល់គូភាគី ........ ៣៩
២.២.ការចេញដីកាដោះស្រាយ ........ ៤១
២.២.១.ការលើកលែងការចោទប្រកាន់ ........ ៤១

២.២.២.ដីកាបញ្ជូនខ្លួនជនត្រូវចោទទៅជំនុំជម្រះ........................................ ៤២
**ផ្នែកទី២៖ ដំណើរការនៃការស៊ើបសួរ** ........................................ ៤៤
១.អំណាចបង្ខំរបស់ចៅក្រម........................................ ៤៤
១.១.អំណាចក្នុងការចេញដីកា ........................................ ៤៤
១.១.១.ដីកាបង្គាប់ឱ្យចូលខ្លួន ........................................ ៤៤
១.១.២.ដីកាបង្គាប់ឱ្យនាំខ្លួន........................................ ៤៥
១.១.៣.ដីកាបង្គាប់ឱ្យចាប់ខ្លួន........................................ ៤៦
១.១.៤.ដីកាបង្គាប់ឱ្យឃុំខ្លួន........................................ ៤៨
១.២.ការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ ........................................ ៤៩
១.២.១.បុគ្គលដែលអាចដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ ........................................ ៤៩
១.២.២.បែបបទនៃការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ........................................ ៤៩
១.៣.ការរក្សាជនត្រូវចោទឱ្យនៅក្រោមការចាត់ចែងរបស់តុលាការ........................................ ៥០
១.៣.១. ការឃុំខ្លួនបណ្តោះអាសន្ន........................................ ៥០
ក.មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន ........................................ ៥០
ខ.ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន........................................ ៥១
គ.ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ........................................ ៥២
១.៣.២.ការត្រួតពិនិត្យតាមផ្លូវតុលាការ ........................................ ៥៣
ក.មូលហេតុនៃការត្រួតពិនិត្យតាមផ្លូវតុលាការ........................................ ៥៣
ខ.បែបបទនៃការត្រួតពិនិត្យតាមផ្លូវតុលាការ ........................................ ៥៥
គ.បុគ្គលដែលអាចកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការ ........................................ ៥៥
ឃ.អានុភាពនៃការត្រួតពិនិត្យតាមផ្លូវតុលាការ........................................ ៥៦
២.អំណាចស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ........................................ ៥៦
២.១.ការសួរចម្លើយជនត្រូវចោទ ........................................ ៥៦
២.២.ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី........................................ ៥៨
២.៣.ការស្តាប់ចម្លើយសាក្សី ........................................ ៥៨

២.៤.ការឆែកឆេរ និងការចាប់យកភស្តុតាង ............ ៦០
២.៥.កោសលវិច័យ ............ ៦១
២.៦.ការស្តាប់ទូរស័ព្ទ ............ ៦៣
២.៧.ការចាត់ឱ្យស៊ើបសួរជំនួស ............ ៦៣

## ជំពូកទី៥៖ ដំណាក់កាលជំនុំជម្រះក្នុងរឿងព្រហ្មទណ្ឌ

**ផ្នែកទី១៖ ចំណាត់ការរបស់តុលាការមុនសវនាការ** ............ ៦៥
១.ការកំណត់កាលបរិច្ឆេទសវនាការ ............ ៦៥
២.ការកោះហៅភាគីឱ្យចូលសវនាការ ............ ៦៥
២.១.ការកោះហៅជនជាប់ចោទឱ្យចូលសវនាការ ............ ៦៦
២.២.ការកោះហៅជនក្រៅពីជនជាប់ចោទឱ្យចូលសវនាការ ............ ៦៧
**ផ្នែកទី២៖ នីតិវិធីក្នុងពេលសវនាការ** ............ ៦៨
១.ការរៀបចំសណ្តាប់ធ្នាប់ក្នុងពេលសវនាការ ............ ៦៨
១.១.ការពិនិត្យ និងផ្ទៀងផ្ទាត់អត្តសញ្ញាណអ្នកចូលរួម ............ ៦៨
១.២.ការដឹកនាំធ្វើសម្បថ ............ ៦៨
២.សមាសភាពនៃអង្គសវនាការ ............ ៦៩
៣.កិច្ចពិភាក្សាដេញដោលក្នុងពេលសវនាការ ............ ៧០
៣.១.ការសួរដេញដោលរបស់តុលាការ ............ ៧០
៣.២.ការបិទកិច្ចពិភាក្សាដេញដោល ............ ៧១
៣.៣.ការកត់កំណត់ហេតុសវនាការ ............ ៧២
៤.ការប្រកាសសាលក្រម ............ ៧២
**ផ្នែកទី៣៖ នីតិវិធីក្រោយសវនាការ** ............ ៧៣
១.ការតាក់តែងសាលក្រម ............ ៧៣
២.ការជូនដំណឹងពីសាលក្រម ............ ៧៥
២.១.សាលក្រមចំពោះមុខ ............ ៧៥
២.២.សាលក្រមដែលចាត់ទុកថាចំពោះមុខ ............ ៧៥

២.៣.សាលក្រមកំបាំងមុខ ............................................................ ៧៦
៣.បណ្តឹងទាស់ និងបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រម ............................................ ៧៦
៣.១.បណ្តឹងទាស់ ............................................................ ៧៦
៣.១.១.ទម្រង់នៃបណ្តឹងទាស់ ............................................................ ៧៦
៣.១.២.រយៈពេលនៃការធ្វើបណ្តឹងទាស់ ............................................................ ៧៧
៣.១.៣.អានុភាពនៃបណ្តឹងទាស់ ............................................................ ៧៨
៣.២.បណ្តឹងឧទ្ធរណ៍ ............................................................ ៧៨
៣.២.១.ទម្រង់នៃបណ្តឹងឧទ្ធរណ៍ ............................................................ ៧៩
៣.២.២.រយៈពេលនៃការប្តឹងឧទ្ធរណ៍ ............................................................ ៨០
៣.២.៣.អានុភាពនៃបណ្តឹងឧទ្ធរណ៍ ............................................................ ៨១
**សេចក្តីសន្និដ្ឋាន** ............................................................ ៨៤
**ការផ្តល់អនុសាសន៍** ............................................................ ៨៧
**ឯកសារពិគ្រោះ**
**ឧបសម្ព័ន្ធ ១**
**ឧបសម្ព័ន្ធ ២**
**ឧបសម្ព័ន្ធ ៣**
**ឧបសម្ព័ន្ធ ៤**

# សេចក្តីផ្តើម

ក្នុងចំណុចចាប់ផ្តើមមួយក្រោយពីការរងនូវគ្រោះមហន្តរាយធំមួយ ដោយសារការសម្លាប់យ៉ាងរង្គាលជាពិសេសចំពោះអ្នកមានចំណេះដឹងគ្រប់ផ្នែករួមទាំងផ្នែកច្បាប់ផងទៀតនោះ។ ក្រោយពីទទួលបានសន្តិភាពដោយយោងតាមឯកសារជាច្រើនបានបង្ហាញថា ប្រទេសកម្ពុជាស្ថិតក្នុងវិបត្តិមួយយ៉ាងធ្ងន់ធ្ងរដោយសារការខ្វះខាតនូវធនធានជាច្រើន ជាពិសេសគឺធនធានមនុស្សដែលជាអ្នកចេះដឹងជាគ្រឹះសំរាប់ជាថ្នាលបណ្តុះបណ្តាលមនុស្សជំនាន់ក្រោយ។ មិនសំដៅលើវិស័យណាមួយក៏ដោយត្រូវបានបាត់បង់ស្ទើរតែអស់ រួមទាំងតែវិស័យច្បាប់ក៏ត្រូវបានរលត់ស្ទើរតែសូន្យឈឹងតែម្តងដែលវាជាកត្តាមួយ ឬជាឧបសគ្គមួយយ៉ាងធំក្នុងការរាំងស្ទះដល់ការអភិវឌ្ឍន៍របស់ប្រទេសកម្ពុជា។ តួយ៉ាងចំពោះអ្នកច្បាប់វិញ គឺត្រូវបានគេស្វែងរកក្រោយពីប្រទេសទទួលបាននូវសន្តិភាពដោយមិនគិតប្រកាន់ថាគាត់មានចំណេះដឹងផ្នែកច្បាប់បានជ្រៅជ្រះ ឬក៏តិចតួចនោះឡើយគឺត្រូវបានអញ្ជើញមកដើម្បីធ្វើការចែករំលែកតាមរយៈអ្នកចេះច្រើនបង្រៀនអ្នកចេះតិច ហើយអ្នកចេះតិចត្រូវបង្រៀនអ្នកមិនចេះសោះក្នុងគោលបំណងបណ្តុះបណ្តាលថ្នាលអ្នកច្បាប់សារជាថ្មី។ ក្រោយពីកិច្ចខិតខំប្រឹងប្រែងយ៉ាងមុះមុតពីជំណាក់កាលមួយទៅជំណាក់កាលមួយយ៉ាងលំបាក គេក៏បានរៀបចំសារជាថ្មីនូវប្រព័ន្ធលើយុត្តាធិការតាមបណ្តាខេត្ត-ក្រុងនីមួយៗ និងបន្តធ្វើការពង្រីកឱ្យប្រព័ន្ធយុត្តិធម៌នេះឱ្យមាននៅគ្រប់ខេត្ត-ក្រុងទូទាំងប្រទេសកម្ពុជា។

ជាក់ស្តែង នៅឯខេត្តបាត់ដំបងក៏បានបង្កើតនូវយុត្តាធិការមួយផងដែរដែលមានទីតាំងស្ថិតនៅជិតសាលាខេត្តបាត់ដំបង ហើយនៅក្នុងអតីតកាលសាលាដំបូងខេត្តបាត់ដំបងមួយនេះមានកិច្ចទទួលខុសត្រូវស្វែងរកយុត្តិធម៌ជូនប្រជាជនចំនួនបួនខេត្ត ដោយមានសមត្ថកិច្ចក្នុងការគ្រប់ដណ្តប់លើខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ និងខេត្តប៉ៃលិន។ ដំណើរការប្រព្រឹត្តទៅនៃសាលាដំបូងខេត្តបាត់ដំបងនេះ ឃើញថាកើតមានរឿងក្តីជាច្រើនហូរហែដែលបានដាក់បន្ទុកដល់មន្ត្រីតុលាការនៃសាលាដំបូងនេះ ដើម្បីធ្វើការដោះស្រាយនូវរឿងក្តីទាំងនោះដោយរួមមានទាំងរឿងក្តីព្រហ្មទណ្ឌ និងរឿងក្តីរដ្ឋប្បវេណី។ វាជាការពិតណាស់ ក្នុងសង្គមមួយតែងតែកើតមានរឿងក្តីផ្សេងៗ ដែលតម្រូវឱ្យមន្ត្រីតុលាការត្រូវបំពេញតួនាទីរបស់ខ្លួនយ៉ាងសកម្មដើម្បីរកដំណោះស្រាយចំពោះបញ្ហាគ្រប់បែបយ៉ាងដែលជាទុក្ខលំបាករបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយក្រុមយើងខ្ញុំលើកយកត្រឹមតែបណ្តឹងផ្នែកព្រហ្មទណ្ឌមួយប៉ុណ្ណោះដើម្បីយកមកធ្វើការបកស្រាយ ។

ចំពោះដំណើរការនីតិវិធីនៃការស្វែងរកយុត្តិធម៌នេះ សាលាដំបូងខេត្តបាត់ដំបងបានធ្វើការអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវនីតិវិធីច្បាប់ ដោយពុំមានលក្ខណៈខុសគ្នាពីសាលាដំបូងនៃបណ្តាខេត្ត-ក្រុងដទៃទៀត ដែលបានប្រត្តិបត្តិក្នុងព្រះរាជាណាចក្រកម្ពុជានោះទេ គឺការអនុវត្តតាមនីតិវិធីព្រហ្មទណ្ឌអន្តរកាល។ ប៉ុន្តែក្រោយមក ដើម្បីសម្រួលកាន់តែមានភាពស៊ីជម្រៅ និងល្អិតល្អន់ចំពោះការអនុវត្តនូវនីតិវិធីឱ្យកាន់តែមានលក្ខណៈល្អប្រសើរថែមទៀត ក្រសួងយុត្តិធម៌ក៏បានសម្រេចបង្កើតឡើងនូវក្រមនីតិវិធីព្រហ្មទណ្ឌថ្មីមួយទៀតដែលត្រូវបានរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ ២០០៧ ។ ក្រោយពីក្រមនីតិវិធីព្រហ្មទណ្ឌថ្មីបានចូលជាធរមាន រាល់សេចក្តីសម្រេចដែលចេញដោយសាលាដំបូងខេត្តបាត់ដំបងនេះ ការប្រើប្រាស់នូវឆន្ទានុសិទ្ធិរបស់ចៅក្រមដើម្បីសម្រេចចេញសាលក្រមលើរឿងក្តីណាមួយនោះ ដោយត្រូវផ្អែកតាមក្រមនីតិវិធីព្រហ្មទណ្ឌថ្មីមួយនេះធ្វើជាគោលចម្បង។ ចំពោះការបកស្រាយរៀបរាប់លើកិច្ចការស្រាវជ្រាវយ៉ាងទូលំទូលាយនៃសារណាមួយនេះ បានលើកឡើងក្រោមប្រធានបទ "**ដំណើរការនៃរឿងក្តីព្រហ្មទណ្ឌនៃសាលាដំបូងខេត្តបាត់ដំបង**" ក្រុមយើងខ្ញុំបានធ្វើការកំណត់អំពីចំណុចដែលនឹងត្រូវលើកយកមកបកស្រាយ ហើយធ្វើការរៀបចំឡើងធ្វើបទបង្ហាញដោយទាក់ទងប្រវត្តិមួយចំនួននៃសាលាដំបូងខេត្តបាត់ដំបង និងអំពីនីតិវិធីក្នុងដំណើរការនៃរឿងក្តីព្រហ្មទណ្ឌ ដោយគិតចាប់ពីដំណាក់កាលនៃសមត្ថកិច្ចនគរបាលយុត្តិធម៌រហូតដល់ការប្រកាសសាលក្រម ដែលចេញដោយសាលាដំបូងខេត្តបាត់ដំបងដូចដែលមានរៀបរាប់ក្នុងប្លង់ខាងក្រោមដូចតទៅ៖

**ជំពូកទី១៖ ស្ថានភាពទូទៅនៃសាលាដំបូងខេត្តបាត់ដំបង**

**ជំពូកទី២៖ ដំណាក់កាលនៃការស៊ើបអង្កេតក្នុងរឿងក្តីព្រហ្មទណ្ឌ**

**ជំពូកទី៣៖ ដំណាក់កាលការចោទប្រកាន់ក្នុងរឿងក្តីព្រហ្មទណ្ឌ**

**ជំពូកទី៤៖ ដំណាក់កាលការស៊ើបសួរក្នុងរឿងក្តីព្រហ្មទណ្ឌ**

**ជំពូកទី៥៖ ក្នុងរឿងព្រហ្មទណ្ឌដំណាក់កាលជំនុំជម្រះ**

# ជំពូកទី១
# ស្ថានភាពទូទៅនៃសាលាដំបូងខេត្តបាត់ដំបង

ជាទូទៅស្ថាប័នតុលាការ ជាស្ថាប័នមួយដែលមានកាតព្វកិច្ចជំនុំជម្រះក្តី ឬវិវាទទាំងឡាយដែលបានកើតឡើងទាំងរឿងក្តីព្រហ្មទណ្ឌ និងរដ្ឋប្បវេណី។ សាលាដំបូង គឺជាសាលាជម្រះក្តីថ្នាក់ទីមួយ ដែលត្រូវបង្កើតឡើងអោយមាននៅគ្រប់បណ្តារាជធានី ខេត្តក្នុងព្រះរាជាណាចក្រកម្ពុជា។[1] ជាក់ស្តែង សាលាដំបូងខេត្តបាត់ដំបងបានបំពេញនូវតួនាទីរបស់ខ្លួនលើសមត្ថកិច្ចដែនដីដោយផ្អែកតាមគោលការណ៍ឯករាជ្យមិនចំណុះឱ្យស្ថាប័នណាមួយ ក្នុងគោលបំណងរក្សានូវសន្តិសុខ យុត្តិធម៌ជូនប្រជាពលរដ្ឋគ្រប់រូបដោយមិនប្រកាន់នូវពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពណាមួយឡើយ។

សាលាដំបូងខេត្តបាត់ដំបង ជាសាលាជម្រះក្តីថ្នាក់ទី១ ឬសាលាជម្រះក្តីថ្នាក់ទាប ដែលមានសមត្ថកិច្ចគ្របដណ្តប់លើដែនដីខេត្តបាត់ដំបងទាំងមូល។ តុលាការនេះក៏បានរៀបចំនូវរចនាសម្ព័ន្ធមន្ត្រីរបស់ខ្លួនឱ្យមានស្ថាប័នតុលាការ និងអង្គការអយ្យការ ដែលទាមទារឱ្យមានចៅក្រម តំណាងអយ្យការ និងក្រឡាបញ្ជីជាជំនួយការ។

## ផ្នែកទី១៖ ប្រវត្តិនៃការកកើតសាលាដំបូងខេត្តបាត់ដំបង

ប្រព័ន្ធតុលាការនៅប្រទេសកម្ពុជាធ្លាប់បានឆ្លងកាត់នូវការផ្លាស់ប្តូររបបជាច្រើន គឺចាប់តាំងពីឆ្នាំ ១៩៧៩ រហូតមកទល់ឆ្នាំ ១៩៨៥ តុលាការនៅកម្ពុជាមានតែមួយថ្នាក់តែប៉ុណ្ណោះ គឺតុលាការខេត្ត-ក្រុង ដែលជាតុលាការដំបូងកាត់ក្តី ឬជំនុំជម្រះជាលើកទីមួយ និងជាលើកចុងក្រោយបង្អស់មានន័យថាសាលក្រមទាំងឡាយដែលបានចេញដោយតុលាការនេះ មានប្រសិទ្ធិភាពអនុវត្តតែម្តងប៉ុន្តែសាលក្រមទាំងនោះត្រូវបានត្រួតពិនិត្យមើលឡើងវិញដោយក្រសួងយុត្តិធម៌ និងសម្រេចចុងក្រោយដោយក្រុមប្រឹក្សារដ្ឋ នៅក្នុងករណីមានការស្នើពីក្រសួងយុត្តិធម៌ចំពោះសេចក្តីសម្រេចដែលក្រសួងយុត្តិធម៌រកឃើញថាមានកំហុស។ នៅឆ្នាំ ១៩៨៥ តុលាការកំពូលត្រូវបានបង្កើតឡើងដោយទទួលយកតួនាទីក្រុមប្រឹក្សារដ្ឋមានពីមុន។ លុះដល់អាជ្ញាធរអង្គការសហប្រជាជាតិនៅកម្ពុជា ដែលហៅកាត់ថា អ៊ុនតាក់ បានបង្កើតឡើងពេលនោះតុលាការមានពីរថ្នាក់គឺតុលាការជាន់ទាប រួមមាន

[1] មាត្រា ១២ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការឆ្នាំ ២០១៤

តុលាការខេត្ត-ក្រុង និងតុលាការយោធា និងតុលាការជាន់ខ្ពស់ដែលរួមមានសាលាឧទ្ធរណ៍ និងតុលាការកំពូល។

ចំពោះសាលាដំបូងខេត្តបាត់ដំបង បានកកើតឡើងតាំងពីសម័យអាណានិគមនិយមបារាំងមកម្ល៉េះ។ ប៉ុន្តែដោយសារតែប្រទេសកម្ពុជាត្រូវឆ្លងកាត់នូវរបបប៉ុលពត ដែលគឺជារបបមួយបានលុបបំបាត់ចោលនូវវិស័យសំខាន់ៗដោយក្នុងនោះរួមមានវិស័យច្បាប់ផងដែរ ជាកត្តាបណ្តាលឱ្យប្រព័ន្ធតុលាការនៅប្រទេសកម្ពុជាពុំអាចដំណើរការទៅបានទៀតនោះឡើយ។ បន្ទាប់ពីរួចចាកផុតនូវរបបប៉ុលពតមក សាលាដំបូងខេត្តបាត់ដំបងមិនទាន់អាចបើកដំណើរការវិញបានភ្លាមៗនោះទេ គឺរហូតមកដល់សម័យ លន់ នល់ ក្នុងអំឡុងឆ្នាំ ១៩៨១ - ១៩៨២ ទើបតុលាការនេះចាប់ផ្តើមដំណើរការប្រក្រតីដូចដើមវិញ។ ដោយនាពេលនោះ សាលាដំបូងខេត្តបាត់ដំបងមិនមែនមានដែនសមត្ថកិច្ចរបស់ខ្លួនត្រឹមតែលើខេត្តបាត់ដំបងនោះទេ គឺលាតសន្ធឹងដល់ខេត្តបន្ទាយមានជ័យ ខេត្តប៉ៃលិន និងមួយផ្នែកនៃខេត្តឧត្តរមានជ័យផងដែរ។ ក្រោយមក ក៏ត្រូវមានការផ្លាស់ប្តូរដោយគេធ្វើការបំបែកមួយផ្នែកនៃខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ និងខេត្តប៉ៃលិននោះចេញពីសមត្ថកិច្ចរបស់សាលាដំបូងខេត្តបាត់ដំបង ដោយសារតែត្រូវបានគេបង្កើតឱ្យមានសាលាដំបូងរៀងៗខ្លួននៅតាមបណ្តាខេត្តទាំងនោះ ដើម្បីសម្រួលដល់ប្រជាពលរដ្ឋឱ្យកាន់តែមានភាពងាយស្រួលជាងមុនក្នុងការធ្វើដំណើរស្វែងរកយុត្តិធមិរបស់ខ្លួន។ដូចនេះ ពេលបច្ចុប្បន្នតុលាការនេះមានសមត្ថកិច្ចដែនដីរបស់ខ្លួនគ្របដណ្តប់លើខេត្តបាត់ដំបងតែមួយគត់។

តុលាការនេះមានរចនាបទអគារបែបបុរាណ ដែលមានលក្ខណៈពិសេសខុសប្លែក និងស្អាតជាងតុលាការនៅតាមបណ្តារាជធានី ខេត្តដទៃទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយសំណង់អគារនៃតុលាការនេះ បានបន្សល់ទុកតាំងតែពីសម័យដើមមករហូតមកដល់បច្ចុប្បន្ននេះ។

ចំណែកឯទីតាំងនៃសាលាដំបូងខេត្តបាត់ដំបង ក៏ស្ថិតនៅទីតាំងដដែលតាំងពីសម័យដើមរហូតដល់បច្ចុប្បន្នផងដែរ ដោយមានទីតាំងស្ថិតនៅភូមិកម្មករ សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង។

## ផ្នែកទី២៖ សមាសភាព និងតួនាទីភារកិច្ច

### ១. សមាសភាពនៃសាលាដំបូងខេត្តបាត់ដំបង

ជាក់ស្តែងនាពេលបច្ចុប្បន្នក្នុងឆ្នាំ ២០១៦ នៅសាលាដំបូងខេត្តបាត់ដំបងមានសមាសភាព

ចំនួន ៤៧រូប ដោយរួមគិតទាំងប្រធានសាលាដំបូង អនុប្រធានសាលាដំបូង ចៅក្រម ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង ប្រធានលេខាធិការដ្ឋាន អនុលេខាធិការដ្ឋាន ក្រឡាបញ្ជី និងមន្ត្រីក្រៅកិច្ចសន្យា។

រចនាសម្ព័ន្ធផ្ទៃក្នុងនៃសាលាដំបូងខេត្តបាត់ដំបងមានសមាសភាពដូចនៅក្នុងគំនូសតាងដូចតទៅ៖

**រចនាសម្ព័ន្ធផ្ទៃក្នុងនៃសាលាដំបូងខេត្តបាត់ដំបង**




## ២. តួនាទីភារកិច្ច

❖ **ប្រធានសាលាដំបូង**

ប្រធានសាលាដំបូងខេត្តបាត់ដំបង គឺជាអ្នកចាត់នូវវិធាននៃការគ្រប់គ្រងជាចាំបាច់សម្រាប់ដំណើរការនៃសាលាដំបូងខេត្តបាត់ដំបង។ ប្រធានសាលាដំបូងត្រូវចេញដីកាសម្រេចដើម្បី[2]៖

- ចាត់តាំងនូវអនុប្រធានសាលាដំបូងណាម្នាក់ឱ្យចាត់ចែងការងារជំនួសខ្លួនបាន ក្នុងករណីចាំបាច់

[2] មាត្រា ១៧ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការឆ្នាំ ២០១៤

- ចាត់តាំងអនុប្រធានសាលាដំបូងឱ្យទទួលបន្ទុកធ្វើជាប្រធានតុលាការជំនាញនីមួយៗដោយផ្អែកតាមជំនាញ ឬតាមបទពិសោធន៍ការងារ។ ក្នុងករណីខ្វះអនុប្រធានសាលាដំបូង អាចចាត់តាំងចៅក្រមណាម្នាក់ដែលមានឋានន្តរស័ក្តិខ្ពស់ ឬមានបទពិសោធន៍ច្រើនធ្វើជាប្រធានតុលាការជំនាញ

- កំណត់លំដាប់សម្រាប់ជំនួសចៅក្រមនៅក្នុងតុលាការជំនាញនីមួយៗ ព្រមទាំងនៅក្នុងក្រុមប្រឹក្សាជំនុំជម្រះនៃតុលាការជំនាញទាំងនេះ ក្នុងករណីដែលចៅក្រមណាម្នាក់អវត្តមាន ឬមានធុរៈ

- ចាត់តាំង និងផ្លាស់ប្តូរក្រឡាបញ្ជីនៅក្នុងតុលាការជំនាញនីមួយៗតាមសេចក្តីត្រូវការចាំបាច់ជាក់ស្តែង។

ម្យ៉ាងវិញទៀត ប្រធានសាលាដំបូងមានភារកិច្ចពិនិត្យសំណុំរឿងធ្វើការបែងចែកចាត់តាំងចៅក្រមស៊ើបអង្កេត ចៅក្រមជំនុំជម្រះ ឬចាត់តាំងខ្លួនជាចៅក្រមជំនុំជម្រះ ព្រមទាំងគ្រប់គ្រងរាល់ចំណូលចំណាយផ្សេងៗនៅក្នុងស្ថាប័ន និងចេញសេចក្តីសម្រេចនានាដែលទាក់ទងនឹងរឿងក្តី។

❖ **អនុប្រធានសាលាដំបូង**

អនុប្រធានសាលាដំបូងខេត្តបាត់ដំបង គឺជាអ្នកជួយគ្រប់គ្រងការងារមួយផ្នែករបស់ប្រធានសាលាដំបូងខេត្តបាត់ដំបង ដែលស្ថិតក្រោមការដឹកនាំរបស់ប្រធាន ដោយមានភារកិច្ច និងតួនាទីប្រហាក់ប្រហែលគ្នា។

❖ **ចៅក្រម**

មានតែចៅក្រមប៉ុណ្ណោះដែលមានសិទ្ធិជម្រះរឿងក្តី និងចេញសេចក្តីសម្រេចរបស់តុលាការបាន[3]។ ចៅក្រមត្រូវបំពេញភារកិច្ចនេះដោយឯករាជ្យដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ និងឱ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន។ ការសម្រេចសេចក្តីទាំងឡាយគឺត្រូវតែធ្វើក្នុងនាមប្រជារាស្ត្រខ្មែរដោយមិនលំអៀង ដោយឈរលើគោលការណ៍គោរពច្បាប់ ដោយមិនទទួលនូវការគាបសង្កត់ ឬការគំរាមគំហែង ការបំភិតបំភ័យ ការបង្គាប់បញ្ជាដោយផ្ទាល់ ឬដោយប្រយោលពីភាគីណាមួយក្នុងរឿងក្តី ឬពីបុគ្គលណាមួយឡើយ។

ចៅក្រមគ្រប់រូបត្រូវបានចាត់តាំងឱ្យបំពេញការងារនៅសាលាដំបូងខេត្តបាត់ដំបង សម្រាប់រយៈពេល ៤ (បួន) ឆ្នាំ ប៉ុន្តែឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមអាចផ្លាស់ប្តូរចៅក្រមណាមួយឱ្យបំពេញ

[3] មាត្រា ៦ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការឆ្នាំ ២០១៤

ការងារកន្លែងណាមួយផ្សេងបាន ក្នុងករណីចៅក្រមនោះមានទោសវិន័យថ្នាក់ទី២ (ពីរ) ដូចមានចែងក្នុងមាត្រា ៥៥ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឬទៅតាមតម្រូវការចាំបាច់ដើម្បីដំណើរការល្អនៃយុត្តិធម៌[4]។

❖ **ព្រះរាជអាជ្ញា និង ព្រះរាជអាជ្ញារងអមសាលាដំបូង**

ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងអមសាលាដំបូង ជាតំណាងអង្គការអយ្យការអមតុលាការខេត្តបាត់ដំបង[5]។ អង្គការអយ្យការ គឺជាម្ចាស់បណ្តឹងអាជ្ញា ជាស្ថាប័នតំណាងឱ្យរដ្ឋជាស្ថាប័នការពារនូវសិទ្ធិសេរីភាពបុគ្គល ការពារផលប្រយោជន៍ជាសាធារណៈ ដែលស្ថាប័ននេះមានតួនាទីក្នុងការចោទប្រកាន់ដោយធ្វើឡើងតាមរយៈការធ្វើបណ្តឹងអាជ្ញា ចំពោះសិទ្ធិក្នុងការធ្វើបណ្តឹងអាជ្ញានេះដែរ គឺមានតែអង្គការអយ្យការតែមួយប៉ុណ្ណោះដែលមានសិទ្ធិ[6]។

ព្រះរាជអាជ្ញាទទួលបណ្តឹងបរិហារ ឬបណ្តឹងទាមទារពីមន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ពីដើមបណ្តឹងរដ្ឋប្បវេណី ឬពីជនរងគ្រោះក្នុងករណីជនរងគ្រោះនៅមានជីវិត និងពីបុគ្គលដទៃទៀតដែលពាក់ព័ន្ធ។ បន្ទាប់ពីទទួលបានបណ្តឹងបទល្មើសព្រហ្មទណ្ឌ និងទទួលបានរបាយការណ៍ពីមន្ត្រីនគរបាលយុត្តិធម៌ ព្រះរាជអាជ្ញាត្រូវចាត់វិធានការលើពាក្យប្តឹង ឬពាក្យបរិហារដែលខ្លួនបានទទួលដោយផ្ទាល់ ឬមន្ត្រីនគរបាលយុត្តិធម៌បានបញ្ជូនមកនោះទៅតាមនីតិវិធីដែលច្បាប់បានកំណត់រួចគឺមាននៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ ដោយកំណត់ប្រភេទនៃបទល្មើសព្រមទាំងរកភស្តុតាង ឬវត្ថុតាងដែលពាក់ព័ន្ធដើម្បីដាក់បន្ទុក។ ព្រះរាជអាជ្ញាមានសិទ្ធិធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌ ព្រមទាំងមានសិទ្ធិសុំឱ្យមានការអនុវត្តច្បាប់ចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ[7]។

អង្គការអយ្យការធានារ៉ាប់រងនូវការអនុវត្តសេចក្តីសម្រេចខាងបទព្រហ្មទណ្ឌ និងធានាយកចិត្តទុកដាក់ទៅលើការផ្សព្វផ្សាយដីកាបង្គាប់ឱ្យចាប់ខ្លួន។ ចំពោះការបំពេញភារកិច្ចរបស់ខ្លួនវិញគឺចៅក្រមអយ្យការមានសិទ្ធិកេណ្ឌកម្លាំងសាធារណៈដោយផ្ទាល់ជាជំនួយ។ ម្យ៉ាងវិញទៀត ចៅក្រម

---

[4] មាត្រា ៩ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញាឆ្នាំ ២០១៤

[5] មាត្រា ៣៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[6] មាត្រា ១៣១ថ្មី រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣

[7] មាត្រា ៤ កថាខណ្ឌ ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

អយ្យការត្រូវតែមានវត្តមានក្នុងសវនាការរឿងព្រហ្មទណ្ឌ[8]។

ក្រៅពីសិទ្ធិខាងលើព្រះរាជអាជ្ញាអាចដឹកនាំ និងសម្របសម្រួលសកម្មភាពរបស់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។ ប៉ុន្តែ កាលណាអនុវត្តដីកាសម្រេចចាត់ឱ្យមានការស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌តម្រូវឱ្យស្ថិតនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ។ ព្រះរាជអាជ្ញាក៏អាចប្រើប្រាស់អំណាចទាំងអស់ ដែលក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ បានទទួលស្គាល់នោះឱ្យទៅដល់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេត។ ព្រះរាជអាជ្ញាអាចចុះទៅកាន់ទីកន្លែងស៊ើបអង្កេត និងធ្វើគ្រប់ការណែនាំដែលយល់ថាប្រយោជន៍ដល់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌។ ក្នុងករណីចាំបាច់ពិសេសព្រះរាជអាជ្ញាអាចដកសិទ្ធិស៊ើបអង្កេតពីមន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ និងរៀបចំជំនួសមន្ត្រី និងភ្នាក់ងារនោះ។ មិនតែប៉ុណ្ណោះ ព្រះរាជអាជ្ញាអាចធ្វើអធិការកិច្ចបានគ្រប់ពេលវេលានៅអង្គភាពនគរបាលយុត្តិធម៌ ហើយព្រះរាជអាជ្ញាអាចចូលរួមក្នុងការស្តាប់ចម្លើយ អាចត្រួតពិនិត្យការអនុវត្តវិធានការឃាត់ខ្លួនជាពិសេសគឺការគោរពទម្រង់ច្បាប់ និងការកាន់កាប់ទីកន្លែងឃាត់ខ្លួន[9]។

ព្រះរាជអាជ្ញារងដែលស្ថិតនៅក្រោមអំណាចរបស់ព្រះរាជអាជ្ញា ប្រើប្រាស់អំណាចទាំងអស់ដែលព្រះរាជអាជ្ញាមានក្នុងការស្រាវជ្រាវ និងការចោទប្រកាន់បទល្មើស[10]។

- **ក្រឡាបញ្ជី**

ក្នុងរឿងព្រហ្មទណ្ឌក្រឡាបញ្ជីជាជំនួយការសំខាន់ណាស់សម្រាប់ចៅក្រម និងព្រះរាជអាជ្ញា ចាប់តាំងពីសំណុំរឿងបានចូលមកដល់ បេសសកម្មរបស់ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរ ចៅក្រមជំនុំជម្រះ រហូតដល់សំណុំរឿងត្រូវបានជំនុំជម្រះ និងប្រកាសសាលក្រម ពុំអាចប្រត្តិបត្តិការដោយគ្មានវត្តមានរបស់ក្រឡាបញ្ជីបានឡើយ។ ដើម្បីអនុវត្តឱ្យបានខ្ជាប់ខ្ជួនត្រឹមត្រូវតាមទៅគោលការណ៍យុត្តិធម៌ ឥតលំអៀង និងត្រឹមត្រូវតាមច្បាប់ក្រឡាបញ្ជីត្រូវមានភារកិច្ចដូចខាងក្រោម[11]៖

- តាក់តែង ឬបំពេញសេចក្តីក្នុងរូបមន្តតុលាការ និងអយ្យការ

[8] មាត្រា ២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[9] មាត្រា ៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[10] មាត្រា ៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[11] សៀវភៅក្រឡាបញ្ជីតុលាការ និងអយ្យការក្នុងរឿងព្រហ្មទណ្ឌ លោក ហ៊ីង ធីឫទ្ធិ

- សរសេរកំណត់ហេតុសួរចម្លើយ កំណត់ហេតុសវនាការ និងកំណត់ហេតុផ្សេងៗទៀត
- ចុះបញ្ជីរឿងក្តីគ្រប់ប្រភេទ
- គ្រប់គ្រង និងថែរក្សាសំណុំរឿង
- គ្រប់គ្រង និងថែរក្សាវត្ថុតាង
- ចេញសម្រង់សាលក្រម សម្រង់សេចក្តីជំនុំជម្រះ និងជូនដំណឹងអំពីសាលក្រមកំបាំងមុខ
- ធ្វើបញ្ជីរាយលិខិត បញ្ជីប្រចាំខែ និងមុខងារផ្សេងៗទៀតដែលច្បាប់ ឬបទបញ្ជាទាំងឡាយប្រគល់ឱ្យ។

# ជំពូកទី២

# ដំណាក់កាលការស៊ើបអង្កេតក្នុងរឿងក្តីព្រហ្មទណ្ឌ

ការស៊ើបអង្កេត គឺជាដំណាក់កាលត្រៀមនៃរឿងក្តីព្រហ្មទណ្ឌ ដែលប្រព្រឹត្តទៅមុនពេលចាប់ផ្តើមការចោទប្រកាន់ក្នុងគោលបំណងស្វែងរកភស្តុតាង ពោលគឺដើម្បីរកឱ្យឃើញថាតើពិតជាមានបទល្មើសកើតឡើងមែនឬយ៉ាងណា ស្រាវជ្រាវឱ្យច្បាស់ដើម្បីអាចដាក់បន្ទុកនៃបទល្មើសទៅលើបុគ្គលណាម្នាក់ ឬច្រើននាក់ ដែលត្រូវកំណត់ពីអត្តសញ្ញាណឱ្យបានច្បាស់លាស់ រកឱ្យឃើញថាកម្មវត្ថុនៃអំពើល្មើសគឺជាអ្វី រួមទាំងជួយទប់ស្កាត់នូវអំពើល្មើសទាំងឡាយដែលនាំឱ្យសង្គមជាតិមានភាពអាណាធិបតេយ្យ និងអស្ថេរភាព។

រាល់នូវការស៊ើបអង្កេតទាំងឡាយ ច្បាប់តម្រូវឱ្យមន្ត្រីមានសមត្ថកិច្ចទាំងអស់បំពេញការងារដោយសម្ងាត់ ដោយហេតុថាកាលណាមិនបានរក្សាឱ្យបានជាការសម្ងាត់នោះទេ វាអាចបណ្តាលឱ្យជនទុច្ចរិតដែលពាក់ព័ន្ធទៅនឹងបទល្មើសព្រហ្មទណ្ឌណាមួយនោះមានឱកាសលុបបំបាត់ ឬបំផ្លាញចោលភស្តុតាងនានាទប់ស្កាត់ជាមុនដើម្បីជាការបំភ័ន្ត ឬបំភ្លៃការពិតដល់មន្ត្រីមានសមត្ថកិច្ច បង្កជាភាពពិបាកដល់ការស្វែងរកតម្រុយជាដើម។ កិច្ចស៊ើបអង្កេតមិនមែនមានតែមន្ត្រីនគរបាលយុត្តិធម៌ដែលមានភារកិច្ចក្នុងការចុះស៊ើបអង្កេតប៉ុណ្ណោះទេ ក្នុងនោះរួមមានចៅក្រមខាងអយ្យការ មេធាវី ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ មន្ត្រីរាជការ អ្នកបកប្រែ គ្រូពេទ្យ និងបុគ្គលមានសមត្ថកិច្ចដែលមានជំនាញខាងត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ ក៏អាចតម្រូវឱ្យចូលរួមក្នុងការស៊ើបអង្កេតផងដែរ។ ទោះជាយ៉ាងណាក៏ដោយ បុគ្គលដែលបានរៀបរាប់ខាងលើនេះគឺត្រូវទទួលបាននូវការរក្សាការសម្ងាត់នៃវិជ្ជាជីវៈ តែករណីបើមានការបំពានលើការសម្ងាត់នៃការស៊ើបអង្កេតគឺជាបទល្មើសដែលត្រូវផ្តន្ទាទោសតាមផ្លូវច្បាប់ព្រហ្មទណ្ឌជាធរមាន[12]។

ចំពោះការស៊ើបអង្កេតលើរឿងក្តីព្រហ្មទណ្ឌក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ គឺត្រូវបានបែងចែកចេញជាពីររបៀបគឺការស៊ើបអង្កេតបទល្មើសជាក់ស្តែង និងការស៊ើបអង្កេតបឋម។

## ផ្នែកទី១ ការស៊ើបអង្កេតបទល្មើសជាក់ស្តែង

មូលដ្ឋានគ្រឹះនៃការស៊ើបអង្កេតនេះគឺភាពបន្ទាន់ ដោយតម្រូវឱ្យប្រមូលភស្តុតាងដែលមាន

[12] មាត្រា ៨៣ នៃនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

នៅឡើយរបស់បទល្មើសដែលទើបនឹងប្រព្រឹត្តថ្មីៗ។ ដើម្បីជាការឆ្លើយតបទៅនឹងករណីចាំបាច់នេះ ក្រមនីតិវិធីព្រហ្មទណ្ឌបានបង្កើតឱ្យមានវិធានរហ័ស និងការបង្កើនអំណាចរបស់នគរបាល។ ក្នុងករណីនេះពេលវេលាពិតជាសំខាន់ណាស់ កាលបើមន្ត្រីមានសមត្ថភាពមានការយឺតយ៉ាវតែបន្តិចក៏ដោយក៏អាចប្រឈមនឹងការបាត់បង់នូវអត្តសញ្ញាណពិតរបស់ជនល្មើស ស្លាកស្នាម ឬជាភស្តុតាងនានាដែលពាក់ព័ន្ធជុំវិញនៃបទល្មើស ដូច្នេះក្នុងដំណាក់កាលនេះតម្រូវឱ្យមានភាពរហ័សរហួនជាទីបំផុតតាមតែភាពអាចទៅរួច ដើម្បីជៀសវាងនូវការរត់គេចរបស់ជនសង្ស័យ ឬបាត់បង់នូវភស្តុតាងសំខាន់ៗ។

## ១. លក្ខខណ្ឌនៃការបើកការស៊ើបអង្កេតករណីជាក់ស្តែង

ការស៊ើបអង្កេតករណីជាក់ស្តែង មិនត្រូវបានអនុញ្ញាតឱ្យបើកការស៊ើបអង្កេតនេះគ្រប់ពេលដែលមានបទល្មើសព្រហ្មទណ្ឌកើតឡើងនោះទេ។ ក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់នូវលក្ខខណ្ឌមួយចំនួនដែលអាចនាំឱ្យមានការបើកការស៊ើបអង្កេតករណីជាក់ស្តែងនេះបាន។

ចំពោះលក្ខខណ្ឌចម្បងសម្រាប់ការស៊ើបអង្កេតជាក់ស្តែង គឺក្នុងករណីមានបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង និងលក្ខខណ្ឌមួយទៀតនោះ គឺក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមទាំងឡាយណាដែលត្រូវបានប្រព្រឹត្តនៅក្នុងទីកន្លែងដែលអ្នកកាន់កាប់នៅទីកន្លែងនោះ សុំឱ្យព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ចូលមកពិនិត្យ ឬឱ្យភ្នាក់ងារនគរបាលយុត្តិធម៌ក្នុងករណីដែលគ្មានមន្ត្រីនគរបាលយុត្តិធម៌នៅទីកន្លែងនោះ។

### ១.១ ដែនអនុវត្តន៍

ការបើកការស៊ើបអង្កេតជាក់ស្តែងអាចធ្វើទៅបាន តែក្នុងករណីដែលមានបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងតែប៉ុណ្ណោះ ដូចនេះការស៊ើបអង្កេតបែបនេះមិនត្រូវបានធ្វើឡើងនោះទេចំពោះបទលហុ។ អ្នកដែលមានសមត្ថកិច្ចក្នុងការដឹកនាំការស៊ើបអង្កេតជាក់ស្តែងនេះគឺព្រះរាជអាជ្ញា និងមន្ត្រីនគរបាលយុត្តិធម៌ ចំណែកឯភ្នាក់ងារនគរបាលយុត្តិធម៌មានអំណាចផ្ទាល់ត្រឹមតែពិនិត្យកត់ត្រាបទឧក្រិដ្ឋ បទមជ្ឈិមជាក់ស្តែងក្នុងកំណត់ហេតុតែប៉ុណ្ណោះ។ ចំពោះកិច្ចស៊ើបអង្កេតនេះ ការបំពេញកិច្ចទាំងឡាយរបស់ភ្នាក់ងារនគរបាលយុត្តិធម៌ គឺត្រូវបានស្ថិតក្រោមការត្រួតពិនិត្យរបស់មន្ត្រីនគរបាលយុត្តិធម៌។ កត្តាដែលគួរឱ្យកត់ចំណាំផងនោះគឺថាបើក្នុងករណីបទឧក្រិដ្ឋ ឬបទបទមជ្ឈិមជាក់ស្តែង

បុគ្គលគ្រប់រូបអាចចាប់ខ្លួនជនល្មើស និងនាំខ្លួនជននោះទៅប្រគល់ជូនមន្ត្រីនគរបាលយុត្តិធម៌ដែលនៅជិតបំផុត[13]។

### ១.២ ការកំណត់អំពីស្ថានភាពជាក់ស្តែង

មុននឹងបើកការស៊ើបអង្កេតជាក់ស្តែង ដាច់ខាតត្រូវតែកំណត់អំពីស្ថានភាពជាក់ស្តែងជាមុនសិន។ ការកំណត់លក្ខណៈជាក់ស្តែងគឺមានសារៈសំខាន់ណាស់ ដោយហេតុថាដោយសារតែឃើញមាននូវស្ថានភាព ដូច្នោះហើយទើបក្នុងនីតិវិធីច្បាប់តម្រូវឱ្យអនុវត្តនូវការស៊ើបអង្កេតជាក់ស្តែង។

ត្រង់ចំណុចនេះវាជាសមត្ថកិច្ចរបស់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ ដែលស្ថិតក្រោមការត្រួតពិនិត្យដោយអំណាចតុលាការ ក្នុងការវាយតម្លៃជាបឋមអំពីអត្ថិភាពនៃលក្ខណៈជាក់ស្តែងមុននឹងអនុវត្តអំណាចបង្ខំរបស់ខ្លួន និងមុននឹងបើកការស៊ើបអង្កេតបទល្មើសជាក់ស្តែង បើពុំដូចនេះទេមន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌នឹងប្រឈមនូវការមោឃៈភាពនៃកិច្ចដែលបានបំពេញ។ ការពិនិត្យវិនិច្ឆ័យនេះត្រូវបានធ្វើឡើងដោយយោងតាមស្ថានភាពជាក់ស្តែង ដែលមានចែងក្នុងមាត្រា ៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ដូច្នេះ ការស៊ើបអង្កេតបទល្មើសជាក់ស្តែង អាចធ្វើទៅបានតែក្នុងករណីដែលរកឃើញថាដូចទៅនឹងស្ថានភាពមួយក្នុងចំណោមស្ថានភាពជាក់ស្តែង ដែលច្បាប់បានកំណត់ជាមុន និងពិតជាមានយ៉ាងប្រត្យក្ស ហើយការវាយតម្លៃនូវស្ថានភាពជាក់ស្តែងនេះនឹងត្រូវធ្វើឡើងនៅពេលមានការអន្តរាគមន៍របស់នគរបាល។ ផ្ទុយទៅវិញ បើពុំមានស្ថានភាពជាក់ស្តែងដូចដែលបានកំណត់ជាមុននោះទេភ្នាក់ងារដែលបើកការស៊ើបអង្កេតនោះនឹងគ្មានសមត្ថកិច្ច ឯគ្រប់កិច្ចទាំងឡាយដែលខ្លួនបានបំពេញនឹងទុកជាមោឃៈដោយស្វ័យប្រវត្តិ។

ដើម្បីទទួលបានតម្រុយពីខាងក្រៅដែលកំណត់ពីស្ថានភាពជាក់ស្តែង ដែលមន្ត្រីនគរបាលយុត្តិធម៌មានការសង្ស័យដោយសារមានបណ្តឹងបរិហារជាដើមនោះ មន្ត្រីនេះអាចបើកនូវការស៊ើបអង្កេតជាបឋមជាមុនសិន ដើម្បីឈានដល់ការរកឃើញពីតម្រុយដែលអាចឱ្យខ្លួនអាចសន្និដ្ឋានបានពីលក្ខណៈជាក់ស្តែងនៃបទល្មើសនោះបាន ហើយនឹងអាចប្រើប្រាស់នូវអំណាចបង្ខំដែលកើតចេញពីការស៊ើបអង្កេតនេះបើខ្លួនបានប្រមូលតម្រុយពីខាងក្រៅ ដែលអនុញ្ញាតឱ្យអាចកំណត់នូវស្ថានភាពជាក់ស្តែងបាន។

[13] មាត្រា ៨៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ឧទាហរណ៍: ការឃ្លាំមើលជនទុច្ចរិតអាចអនុញ្ញាតឱ្យរកឃើញតម្រុយជាវត្ថុ ដែលអាចកំណត់បាននូវភាពជាក់ស្តែងនៃអំពើលួចរបស់ជននោះ។

មិនតែប៉ុណ្ណោះ ស្ថានភាពជាក់ស្តែងអាចត្រូវបានរកឃើញនៅក្នុងពេលបំពេញកិច្ចស្រាវជ្រាវដើម្បីស្វែងរកបទល្មើសណាមួយផ្សេងទៀតក្នុងក្របខ័ណ្ឌការស៊ើបអង្កេតបឋម ការស៊ើបអង្កេតបទល្មើសជាក់ស្តែង ឬការស៊ើបសួរ។

ឧទាហរណ៍: ពេលអន្តរាគមន៍ដោយស្របច្បាប់ក្នុងផ្ទះ នគរបាលបានសម្គាល់ថាមានវត្ថុដែលដូចគ្នានឹងវត្ថុ ដែលទើបតែត្រូវបានលួចក្នុងពេលមានអំពើលួចដោយប្រើប្រាស់ហិង្សា។

អាចត្រូវចាត់ទុកថាជាស្ថានភាពជាក់ស្តែងបាន លុះត្រាជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងដែលស្ថិតក្នុងករណីដូចខាងក្រោម៖[14]

- **បទល្មើសដែលកំពុងប្រព្រឹត្ត:** គឺជាករណីនៃបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលកំពុងតែប្រព្រឹត្ត។ ចារីត្រូវបានគេឃើញទាន់ក្នុងអំពើសកម្ម ឬអកម្ម។ ការប្រព្រឹត្តអាចត្រូវបានពិនិត្យឃើញដោយផ្ទាល់ (ឧទាហរណ៍: ក្នុងករណីដែលបុគ្គលម្នាក់ត្រូវបានគេឃើញថាកំពុងបន្លំយករបស់អ្នកដទៃ) ដូច្នេះវាគឺជាភាពជាក់ស្តែងពិតប្រាកដ ដែលនគរបាលបានឃើញដោយផ្ទាល់នូវការប្រព្រឹត្តអំពើដែលច្បាប់ចាត់ទុកជាបទល្មើស ហើយអនុញ្ញាតឱ្យបើកការស៊ើបអង្កេតជាក់ស្តែងភ្លាមៗដែលជាទូទៅត្រូវបានកំណត់ដោយនៅពេលចាប់បានចារី។

ការប្រព្រឹត្តនេះក៏អាចត្រូវបានពិនិត្យឃើញតាមរយៈការទទួលបាននូវតម្រុយ ដែលបញ្ជាក់ថាវាទំនងជាពិត។ ជាក់ស្តែងមានបទល្មើសមួយចំនួនដែលកំពុងបានប្រព្រឹត្ត ប៉ុន្តែវាមិនបានបង្ហាញឱ្យឃើញដោយផ្ទាល់នោះទេ (ឧទាហរណ៍: ការកាន់កាប់អាវុធដែលហាមឃាត់ ការកាន់កាប់គ្រឿងញៀន) ស្ថានភាពជាក់ស្តែងអាចនឹងត្រូវបានកំណត់ ហើយការស៊ើបអង្កេតបទល្មើសជាក់ស្តែងអាចនឹងត្រូវបើក លុះត្រាតែមានតម្រុយខាងក្រៅពីអាកប្បកិរិយាទុច្ចរិត។

ទាក់ទងនឹងបទល្មើសលាក់កំបាំង ដូចជាបទល្មើសដែលកើតឡើងក្នុងកន្លែងបិទជិត ដែលមន្ត្រី ឬភ្នាក់ងារនគរបាលយុត្តិធម៌មិនអាចចូល ហើយដែលការទទួលបានតម្រុយមិនអាចធ្វើទៅកើត (ឧទាហរណ៍: កន្លែងពិសោធន៍ ឬកន្លែងផលិតគ្រឿងញៀន) គេត្រូវធ្វើការស៊ើបអង្កេតបឋមជាមុន

[14] មាត្រា ៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ដើម្បីអាចរកឱ្យឃើញតម្រុយជាវត្ថុដែលអនុញ្ញាតឱ្យបើកការស៊ើបអង្កេតបទល្មើសជាក់ស្តែង ឬបើកការស៊ើបសួរ។ ក្នុងករណីជួញដូរគ្រឿងញៀន បន្ទាប់ពីទទួលបានភស្តុតាងជាក់ស្តែងពីសកម្មភាពទុច្ចរិតដោយមានជំនួយពីការតាមដាន មន្ត្រីនគរបាលយុត្តិធម៌អាចបើកធ្វើការឆែកឆេររកន្លែងផលិតលួចលាក់ក្នុងក្របខ័ណ្ឌការស៊ើបអង្កេតជាក់ស្តែង។ ហេតុដូច្នេះ បើពុំមានតម្រុយពីខាងក្រៅទេនោះការសង្ស័យ និងការបរិហារអាណាមិក មិនចូលក្នុងលក្ខខណ្ឌដែលទាមទារដោយមាត្រា ៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌទេ លើកលែងមានបណ្តឹងបរិហារពីជនរងគ្រោះទើបអាចចាត់ទុកជាភស្តុតាងជាក់ស្តែងបាន។

- **បទល្មើសដែលទើបប្រព្រឹត្តរួចភ្លាមៈ** ដោយហេតុក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ចូលសញ្ញាណចិរវេលារវាងការប្រព្រឹត្តបទល្មើស និងការរកឃើញការប្រព្រឹត្ត ដោយពុំបានបញ្ជាក់ពីរយៈពេលណាមួយឱ្យបានច្បាស់លាស់ ដូច្នេះរយៈពេលអាចត្រូវបានកំណត់យកត្រឹម ២៤ ម៉ោង[15]។ បណ្តឹង ឬការពិនិត្យកត់ត្រា គួរតែធ្វើឡើងក្នុងរយៈពេលមួយដែលនៅជិតការប្រព្រឹត្ត ចៀសវាងកាលដែលបាត់លក្ខណៈបច្ចុប្បន្នរបស់ការប្រព្រឹត្ត។

- **ជនដែលគេសង្ស័យត្រូវបានសាធារណជនស្រែកដេញប្រដាប់ចាប់ប្រភីងៈ** នៅក្រោយពេលប្រព្រឹត្តបទល្មើសហើយមានការស្រែកប្រកូកប្រកាសជាសាធារណៈ ត្រូវបានច្បាប់កំណត់ថាជាការស្រែកដេញតាមប្រកិត ដោយមានការចង្អុលបង្ហាញភ្លាមៗនូវបុគ្គលណាម្នាក់ ឬច្រើននាក់ដែលបានប្រព្រឹត្តអំពើបង្កជាភាពប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ។ ការស្រែកប្រកូកប្រកាសនេះវាមានលក្ខណៈខុសគ្នាពីពាក្យចចាមអារ៉ាម ឬការបរិហារ ដោយការស្រែកនេះត្រូវបានធ្វើឡើងក្នុងពេលមួយដែលកៀកទៅនឹងពេលប្រព្រឹត្តបំផុត។ ចំពោះរយៈពេលនេះ ច្បាប់ពុំបានកំណត់ឱ្យបានច្បាស់លាស់នោះទេដោយទុកឆន្ទានុសិទ្ធិជូនចៅក្រមដើម្បីធ្វើការវាយតម្លៃ។

- **បុគ្គលដែលត្រូវបានគេរកឃើញមានវត្ថុ ឬមានស្លាកស្នាម ឬតម្រុយច្បាស់លាស់ ហើយស៊ីចង្វាក់ផ្សេងទៀត ដែលនាំឱ្យគេសន្និដ្ឋានបានថាបុគ្គលនោះបានប្រព្រឹត្ត ឬបានចូលរួមប្រព្រឹត្តបទ-ល្មើសៈ**ករណីដែលបុគ្គលម្នាក់ ឬច្រើននាក់ត្រូវបានកត់សម្គាល់ដោយនគរបាល ឬកងរាជអាវុធហត្ថដែលពុំបានដឹងជាមុនថាមានបទល្មើសព្រហ្មទណ្ឌណាមួយកើតឡើងនោះទេ ប៉ុន្តែបានកត់សម្គាល់

[15] មេរៀននីតិវិធីព្រហ្មទណ្ឌ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

តាមរយៈការរកឃើញវត្ថុ ឬតម្រុយផ្សេងៗ។ ស្ថានភាពជាក់ស្តែងបែបនេះអាចត្រូវបានស្តែងចេញក្នុងករណីដែលកំពុងតែបំពេញភារកិច្ចរបស់នគរបាល (ឧទាហរណ៍: នគរបាលកំពុងមានការត្រួតពិនិត្យចរាចរណ៍ នគរបាលចាប់អារម្មណ៍ពិនិត្យឃើញថាមានក្លិនអាភៀនចេញពីឡាន)។

បន្ថែមពីករណីខាងលើក៏នៅមានករណីផ្សេងទៀត ដែលអនុញ្ញាតឱ្យមានការស៊ើបអង្កេតបទល្មើសជាក់ស្តែងផងដែរ។ ជាការពិត ការស៊ើបអង្កេតបទល្មើសជាក់ស្តែងនេះអាចត្រូវបានបើកចំពោះគ្រប់បទឧក្រិដ្ឋ ឬបទមជ្ឈិមបើបទល្មើសទាំងនេះត្រូវបានប្រព្រឹត្តក្នុងកន្លែងដែលអ្នកកាន់កាប់ស្នើសុំឱ្យព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ធ្វើការពិនិត្យ។ ប្រសិនបើគ្មានវត្តមានមន្ត្រីនគរបាលយុត្តិធម៌ទេ ភ្នាក់ងារនគរបាលយុត្តិធម៌អាចចូលអន្តរាគមន៍ និងពិនិត្យកត់ត្រាបាន។ នៅក្នុងករណីនេះភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវផ្តល់ដំណឹងភ្លាមៗទៅឱ្យមន្ត្រីនគរបាលយុត្តិធម៌ ដើម្បីឱ្យមន្ត្រីនេះបំពេញបេសកកម្មរបស់ខ្លួន[16]។

ឧទាហរណ៍: មានបទល្មើសលួចដោយមានការទម្លាយសោរ ដែលកម្មសិទ្ធិករ ឬអ្នកកាន់កាប់ផ្ទះបានឃើញនៅពេលត្រលប់មកផ្ទះវិញ។ ការលួចនេះអាចត្រូវប្រព្រឹត្តច្រើនថ្ងៃមុនការពិនិត្យឃើញ ប៉ុន្តែការស្នើសុំរបស់ម្ចាស់ផ្ទះ នាំឱ្យមានអានុភាពប្រគល់អំណាចក្នុងការស៊ើបអង្កេតបទល្មើសជាក់-ស្តែងទៅដល់មន្ត្រីនគរបាលយុត្តិធម៌ ដែលទទួលបណ្តឹងដោយផ្ទាល់ ឬតាមរយៈព្រះរាជអាជ្ញាក្នុងករណីដែលព្រះរាជអាជ្ញាជាអ្នកដែលម្ចាស់ផ្ទះបានស្នើសុំ។

ស្ថានភាពជាក់ស្តែងនឹងត្រូវបានពិនិត្យកត់ត្រា តាមរយៈតម្រុយជាវត្ថុខាងក្រៅមួយ ឬច្រើនដែលនាំឱ្យគេអាចសន្និដ្ឋានអំពីអត្ថិភាពរបស់វា។ មន្ត្រីនគរបាល ឬភ្នាក់ងារនគរបាលយុត្តិធម៌នឹងប្រមូលភស្តុតាងដែលអាចឱ្យខ្លួនគិតថាបទឧក្រិដ្ឋ ឬបទមជ្ឈិមកំពុងតែប្រព្រឹត្ត ឬទើបតែប្រព្រឹត្តរួច។ ម្យ៉ាងទៀត ស្ថានភាពជាក់ស្តែងតម្រូវឱ្យមានតម្រុយជាសត្យានុម័តច្បាស់លាស់ ដែលយើងអាចកំណត់បានថាជាធាតុនៃអំពើ ដែលពុំអាចត្រឹមតែជាការសង្ស័យធម្មតារបស់នគរបាល ប៉ុន្តែត្រូវតែមើលឃើញជាក់ស្តែងពីខាងក្រៅ ហើយដែលធ្វើឱ្យការប្រព្រឹត្តបច្ចុប្បន្ននៃបទល្មើសមើលទៅទំនងជាពិត។

[16] មាត្រា ៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

## ២. នីតិវិធីការស៊ើបអង្កេត

### ២.១ ថិរវេលានៃការស៊ើបអង្កេតករណីជាក់ស្តែង

ថិរវេលានៃការស៊ើបអង្កេតបទល្មើសជាក់ស្តែងនេះមិនអាចលើសពី ៧ (ប្រាំពីរ) ថ្ងៃ គិតពីថ្ងៃប្រព្រឹត្តបទល្មើស[17] ។ ថិរវេលានៃការស៊ើបអង្កេតមិនរាប់បញ្ចូលរយៈពេលចន្លោះរវាងនៃការប្រព្រឹត្តបទល្មើសទៅនឹងការប្តឹងទៅមន្ត្រីនគរបាលយុត្តិធម៌ ឬព្រះរាជអាជ្ញានោះទេ ដោយថិរវេលានៃការស៊ើបអង្កេតបទល្មើសជាក់ស្តែង ត្រូវគិតពីថ្ងៃដែលមានការពិនិត្យកត់ត្រាបទល្មើស មិនមែនត្រូវគិតចាប់ពីថ្ងៃដែលបទល្មើសប្រព្រឹត្តនោះទេ។

ដើម្បីធានាឱ្យការស៊ើបអង្កេតនេះអាចធ្វើឡើងក្នុងថិរវេលាកំណត់ខាងលើ ច្បាប់តម្រូវឱ្យធ្វើកិច្ចស៊ើបអង្កេតត្រូវតែប្រព្រឹត្តទៅជាបន្តជាប់ជានិច្ចនៅក្នុងថិរវេលានេះ។ ដូច្នេះ គ្រប់ការស៊ើបអង្កេតត្រូវធ្វើឡើងជាបន្តបន្ទាប់ក្នុងអំឡុងពេល ៧ ថ្ងៃ បើពុំនោះទេនឹងនាំឱ្យមានមោឃភាពនៃនីតិវិធី។ នៅពេលដែលថិរវេលានេះត្រូវបានបញ្ចប់ ប៉ុន្តែបើមន្ត្រីនគរបាលយុត្តិធម៌មិនទាន់បញ្ចប់ការស៊ើបអង្កេត មន្ត្រីនោះត្រូវរាយការណ៍ទៅឱ្យព្រះរាជអាជ្ញា ដែលព្រះរាជអាជ្ញាត្រូវធ្វើការពិនិត្យពិចារណាវាយតម្លៃអំពីភាពចាំបាច់ក្នុងការបន្តការស៊ើបអង្កេតក្នុងក្របខ័ណ្ឌការស៊ើបអង្កេតបឋម ឬការស៊ើបសួរ ឬតម្កល់រឿងទុកមិនចាត់ការ ឬបញ្ជូនរឿងទៅសាលាជម្រះក្តីដោយផ្ទាល់។

### ២.២ កិច្ចស៊ើបអង្កេត

#### ២.២.១ ការចុះដល់ទីកន្លែងកើតហេតុ

នៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌ទទួលបានព័ត៌មានស្តីពីករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង វិធានដំបូងបង្អស់ដែលមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើនោះគឺ ត្រូវធ្វើជាសេចក្តីរាយការណ៍ភ្លាមជូនដល់ព្រះរាជអាជ្ញា[18]។ បន្ទាប់ពីរាយការណ៍រួចមក មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះទៅកាន់ទីកន្លែងកើតហេតុ ដើម្បីធ្វើការពិនិត្យបទល្មើស។ មន្ត្រីនគរបាលយុត្តិធម៌នឹងពិនិត្យកត់ត្រានូវអ្វីដែលមានប្រយោជន៍ ធានារ៉ាប់រងរក្សាទុកនូវតម្រុយនៃភស្តុតាងទាំងឡាយណាដែលអាចបាត់បង់ ទាំងនេះបង្ហាញឱ្យឃើញអំពីការអនុវត្តអំណាចពិនិត្យកត់ត្រាបទល្មើសទូទៅ ដែលបានប្រគល់ឱ្យដោយមាត្រា ៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌទាក់ទងទៅនឹងបេសកកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌។

[17] មាត្រា ១០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[18] មាត្រា ៨៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ដើម្បីអាចបំពេញបេសកកម្មនេះដោយរលូនបាន មន្ត្រីនគរបាលយុត្តិធម៌មានអំណាចហាមឃាត់បុគ្គលគ្រប់រូបកុំឱ្យទៅទីណាឆ្ងាយពីកន្លែងបទល្មើសនោះ រហូតដល់ពេលបញ្ចប់កិច្ចប្រតិបត្តិការរបស់ខ្លួនដើម្បីអាចឃាត់ទុកសាក្សីជាយថាហេតុណាមួយ ព្រមទាំងជួយទប់ស្កាត់ការរត់គេចខ្លួនរបស់អ្នកដែលបានប្រព្រឹត្ត។ ម្យ៉ាងទៀត មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីការពិនិត្យកត់ត្រា និងការស្រាវជ្រាវរបស់ខ្លួន[19]។

ប្រសិនបើមានការបន្ទាន់ ព្រះរាជអាជ្ញាអាចអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់ធ្វើប្រតិបត្តិការលើវិសាលភាពទាំងមូលនៃដែនដីជាតិ ដោយគោរពតាមលក្ខខណ្ឌទាំងឡាយដែលមានចែងក្នុងមាត្រា ៦៨ (ការពន្លាតសមត្ថកិច្ចដែនដី) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ព្រះរាជអាជ្ញាអាចចុះទៅកាន់ទីកន្លែងកើតហេតុ និងដឹកនាំការស៊ើបអង្កេត ក្នុងករណីបើយល់ឃើញថាមានប្រយោជន៍ និងដើម្បីធានារ៉ាប់រងដំណើរការល្អនៃការស៊ើបអង្កេត។

### ២.២.២ ការឆែកឆេរ និងការចាប់យកវត្ថុតាង

ការឆែកឆេរ គឺសំដៅទៅលើការរុករកតម្រុយ ឬភស្តុតាងក្នុងកន្លែងណាមួយដែលបិទជិត ហើយសកម្មភាពនៃការឆែកឆេរនេះដែរ វាអនុញ្ញាតឱ្យកំណត់បាននូវអត្ថិភាពនៃបទល្មើស ឬចង្អុលបង្ហាញពីចារី។

មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរណាដែលមានប្រយោជន៍បាន លុះត្រាតែខ្លួនបានទទួលជាបឋមនូវការអនុញ្ញាតឱ្យធ្វើការឆែកឆេរពីព្រះរាជអាជ្ញា ទោះបីជាការអនុញ្ញាតនោះដោយផ្ទាល់មាត់ក្តី ឬជាលាយលក្ខណ៍អក្សរក្តី។ នៅពេលធ្វើការឆែកឆេរ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែធ្វើឡើងដោយនៅចំពោះមុខរបស់អ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេនោះត្រូវធ្វើឡើងនៅចំពោះមុខសាក្សីចំនួនពីរនាក់ ប៉ុន្តែសាក្សីនោះមិនអាចត្រូវជាកងកម្លាំងចូលរួមប្រតិបត្តិការក្នុងការឆែកឆេរនោះទេ ពោលគឺមិនអាចជានគរបាល ឬកងរាជអាវុធហត្ថឡើយ ដោយសាក្សីនឹងត្រូវបានចាត់តាំងដោយមន្ត្រីនគរបាលយុត្តិធម៌។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវគោរពពេលវេលាដែលច្បាប់បានកំណត់[20] ដោយការឆែកឆេរមិនអាចផ្តើមធ្វើនៅមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចឡើយ។

---

[19] មាត្រា ៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[20] មាត្រា ៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ប៉ុន្តែ មន្ត្រីនគរបាលយុត្តិធម៌នៅតែអាចធ្វើការឆែកឆេរបាននៅពេលមានករណីដូចជា៖

- ករណីមានបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង
- ករណីមានសំរែកស្រែកឱ្យគេជួយពីក្នុងទីកន្លែង
- ករណីឆែកឆេរនៅទីកន្លែងក្នុងពេលម៉ោងដែលបើកចំហដល់សាធារណជន
- ករណីឆែកឆេរនៅគ្រប់ទីកន្លែងដែលផលិត រក្សាទុក ជួញដូរ ចែកចាយ ប្រើប្រាស់គ្រឿងញៀន។

ក្នុងការឆែកឆេរការិយាល័យមេធាវី មន្ត្រីនគរបាលយុត្តិធម៌មិនអាចធ្វើការឆែកឆេរបានទេគឺមានតែព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរតែប៉ុណ្ណោះ ដែលអាចធ្វើការឆែកឆេរនេះបាននៅចំពោះមុខប្រធានគណៈមេធាវី ឬប្រតិភូរបស់ប្រធានគណៈមេធាវី ឬមេធាវីសាមី។

ចំពោះការឆែកឆេរនៅក្នុងអគារសារព័ត៌មាន សហគ្រាសនៃសារពត៌មានសរសេរ ឬសហគ្រាសសារព័ត៌មានសោតទស្សន៍ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរបាន ប៉ុន្តែការឆែកឆេរគឺត្រូវធ្វើឡើងនៅចំពោះមុខព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរម្នាក់ដែលធានាប៉ារងកុំឱ្យការឆែកឆេរប៉ះពាល់ដល់ការប្រកបដោយសេរីនូវមុខរបរអ្នកសារព័ត៌មាន និងធ្វើឱ្យយឺតយ៉ាវដល់ការផ្សព្វផ្សាយព័ត៌មាននេះដោយមិនត្រឹមត្រូវ។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីការឆែកឆេរ ដែលនៅក្នុងនោះមានចុះ៖

- ការអនុញ្ញាតរបស់ព្រះរាជអាជ្ញាដោយប្រាប់ថ្ងៃ និងម៉ោងនៃការអនុញ្ញាត
- អត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬរបស់សាក្សីនីមួយៗ។

ម្យ៉ាងទៀត មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការចាប់យកវត្ថុតាង ដោយត្រូវបិទស្លាកបោះត្រានៅលើវត្ថុតាងនោះ។ ក្រោយពីបានបង្ហាញវត្ថុដែលចាប់បានដល់អ្នកកាន់កាប់ទីកន្លែង ឬដល់សាក្សីចំនួនពីរនាក់មើលរួច មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីការចាប់យកដែលរួមមានបញ្ជីសារពើភ័ណ្ឌនៃវត្ថុដែលបានចាប់ ហើយនៅក្នុងកំណត់ហេតុនោះត្រូវមានការចុះហត្ថលេខា ឬផ្ដិតម្រាមដៃដោយអ្នកកាន់កាប់ទីកន្លែង ឬដោយសាក្សីពីរនាក់[21]។

[21] មាត្រា ៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

### ២.២.៣ ការស្តាប់ចម្លើយ

គ្រប់មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយបុគ្គលទាំងឡាយណាដែលអាចផ្តល់ព័ត៌មានទាក់ទងនឹងអង្គហេតុ[22]។ មន្ត្រីនេះក៏អាចហៅ និងនាំមកកាន់អង្គភាពរបស់ខ្លួននូវបុគ្គលគ្រប់រូប ដែលសង្ស័យថាបានចូលរួមក្នុងបទល្មើសដើម្បីធ្វើការស្តាប់ចម្លើយជនទាំងនោះ។ ក្នុងការស៊ើបអង្កេតបទល្មើសជាក់ស្តែងសាក្សីដែលបានកោះហៅដោយមន្ត្រីនគរបាលយុត្តិធម៌មានកាតព្វកិច្ចចូលមកបង្ហាញខ្លួន។ ក្នុងករណីរឹងទទឹង សាក្សីអាចត្រូវបានបង្ខំតាមរយៈសេចក្តីបង្គាប់ឱ្យចូលខ្លួនដែលចេញដោយព្រះរាជអាជ្ញាតាមសំណើមន្ត្រីនគរបាលយុត្តិធម៌ នោះមន្ត្រីនគរបាលយុត្តិធម៌នឹងទទួលបានការអនុញ្ញាតឱ្យប្រើកម្លាំងសាធារណៈដើម្បីបង្ខំបុគ្គលនោះឲ្យចូលបង្ហាញខ្លួន។

ការស្តាប់ចម្លើយនីមួយៗត្រូវមានធ្វើកំណត់ហេតុ ហើយកំណត់ហេតុនោះត្រូវដកស្រង់តាមយ៉ាងត្រឹមត្រូវនូវសេចក្តីរាយការណ៍របស់បុគ្គលដែលផ្តល់ចម្លើយ។ ក្នុងករណីចាំបាច់មន្ត្រីនគរបាលយុត្តិធម៌អាចរកអ្នកបកប្រែដែលស្បថថានិយាយការពិតស្របតាមជំនឿ ឬសាសនារបស់ខ្លួន។ អ្នកបកប្រែមិនអាចជ្រើសរើសយកពីក្នុងចំណោមនគរបាល កងរាជអាវុធហត្ថ ឬបុគ្គលដែលទាក់ទិនក្នុងរឿងជាមួយគ្នាបានទេ។ បុគ្គលផ្តល់ចម្លើយត្រូវធ្វើការចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃនៅរាល់ទំព័រនីមួយៗនៃកំណត់ហេតុ។ មុននឹងចុះហត្ថលេខា ឬផ្តិតម្រាមដៃ បុគ្គលនោះត្រូវអានខ្លឹមសារកំណត់ហេតុឡើងវិញដោយខ្លួនឯង ឬដោយមន្ត្រីនគរបាលយុត្តិធម៌ក្នុងករណីចាំបាច់ ប៉ុន្តែបើបុគ្គលនោះមិនព្រមចុះហត្ថលេខា ឬផ្តិតម្រាមដៃទេ ក្នុងករណីនេះមន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ[23]។

### ២.២.៤ ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ

ករណីត្រូវធ្វើការពិនិត្យបច្ចេកទេស ឬវិទ្យាសាស្ត្រដែលមិនអាចបង្អង់បាន មន្ត្រីនគរបាលយុត្តិធម៌អាចពឹងដល់បុគ្គលគ្រប់រូបដែលមានជំនាញ តែត្រូវឱ្យបុគ្គលនេះស្បថតាមសាសនា ឬជំនឿរបស់ខ្លួនថានឹងជួយដោយភក្តីភាពដល់តុលាការជាមុនសិន ប្រសិនបើបុគ្គលនេះពុំមានឈ្មោះនៅក្នុងបញ្ជីអ្នកជំនាញថ្នាក់ជាតិទេ[24]។

---

[22] មាត្រា ៩៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[23] មាត្រា ៩៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[24] មាត្រា ៩៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

### ២.២.៥ ការស្តាប់ការសន្ទនា

មន្ត្រីនគរបាលយុត្តិធម៌ ពុំមានសមត្ថភាពបង្គាប់ឱ្យស្តាប់ ឬថតសម្លេងសន្ទនាតាមទូរស័ព្ទ ចាប់ ឬថតការឆ្លើយឆ្លងដែលចេញតាមមធ្យោបាយទូរគមនាគមន៍ សារតាមទូរសារ ឬសារតាមអ៊ីន-ធើរណែតឡើយ[25]។ ក្រមនីតិវិធីព្រហ្មទណ្ឌទទួលស្គាល់អំណាចនេះសម្រាប់តែចៅក្រមស៊ើបសួរតែប៉ុណ្ណោះ។

### ២.២.៦ ការឃាត់ខ្លួន

ដើម្បីឆ្លើយតបនឹងតម្រូវការចាំបាច់នៃការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួនបុគ្គលសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស ឬដែលអាចផ្តល់ព័ត៌មានស្តីពីរឿងហេតុ។ ប្រសិនបើជនដែលអាចផ្តល់ព័ត៌មានប្រកែកមិនព្រមផ្តល់វិញ នោះការឃាត់ខ្លួននឹងអាចធ្វើទៅបានដោយមានការអនុញ្ញាតពីព្រះរាជអាជ្ញាជាលាយលក្ខណ៍អក្សរ[26]។

វិធាននេះជាអំណាចតែមួយគត់របស់មន្ត្រីនគរបាលយុត្តិធម៌ ដែលស្ថិតក្រោមការត្រួតពិនិត្យផ្ទាល់របស់ព្រះរាជអាជ្ញា។ ដូច្នេះ មន្ត្រីនគរបាលយុត្តិធម៌ដែលបានឃាត់ខ្លួនជនសង្ស័យនោះត្រូវតែរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា ហើយការរាយការណ៍នេះមិនអាចពន្យារពេលបានទេ លើកលែងតែមានកាលៈទេសៈដែលមិនអាចជំនះបាន។

រយៈពេលនៃការឃាត់ខ្លួនគឺ ៤៨ ម៉ោង ដោយគិតចាប់ពីម៉ោងដែលសាមីខ្លួនមកដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ។ ការពន្យាពេលនៃការឃាត់ខ្លួនចំនួន ២៤ ម៉ោងទៀតដោយមិនគិតពីថិរវេលាចាំបាច់ក្នុងការដឹកជញ្ជូន អាចធ្វើទៅបានលុះត្រាតែមានលក្ខខណ្ឌដូចតទៅ:

- មានតម្រុយបង្ហាញឱ្យឃើញថា មានពិរុទ្ធភាពលើបុគ្គលដែលឃាត់ខ្លួនជានីតិជនក្នុងបទឧក្រិដ្ឋ
- ការពន្យារពេលជាវិធានការចាំបាច់ ដើម្បីឱ្យការស៊ើបអង្កេតប្រព្រឹត្តទៅបានល្អ
- ការអនុញ្ញាតដោយព្រះរាជអាជ្ញាជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ។

ចំពោះការឃាត់ខ្លួនអនីតិជនអាចធ្វើទៅបានចំពោះតែអនីតិជនអាយុចាប់ពី ១៤ ឆ្នាំឡើងទៅប៉ុណ្ណោះ ហើយរយៈពេលនៃការឃាត់ខ្លួនប្រែប្រួលទៅតាមប្រភេទនៃបទល្មើសៈ

[25] មាត្រា ១០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[26] មាត្រា ៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

❖ **ចំពោះបទឧក្រិដ្ឋ**

- អនីតិជនដែលមានអាយុពី ១៤ ឆ្នាំដល់ក្រោម ១៦ ឆ្នាំ: មិនហួសពី ៣៦ ម៉ោង។
- អនីតិជនដែលមានអាយុពី ១៦ ឆ្នាំដល់ក្រោម ១៨ ឆ្នាំ: មិនហួសពី ៤៨ ម៉ោង។

❖ **ចំពោះបទមជ្ឈិម**

- អនីតិជនដែលមានអាយុពី ១៤ ឆ្នាំដល់ក្រោម ១៦ ឆ្នាំ: មិនហួសពី ២៤ ម៉ោង។
- អនីតិជនដែលមានអាយុពី ១៦ ឆ្នាំដល់ក្រោម ១៨ ឆ្នាំ: មិនហួសពី ៣៦ ម៉ោង។

ក្នុងរយៈពេលនៃការឃាត់ខ្លួន បុគ្គលដែលឃាត់ខ្លួនមានសិទ្ធិសុំសន្ទនាជាមួយមេធាវី ឬជាមួយជនណាម្នាក់ដែលខ្លួនជ្រើសរើស លើកលែងតែជននោះមានការទាក់ទិននៅក្នុងរឿងជាមួយគ្នា។ ទំនាក់ទំនងនេះអាចធ្វើបានក្នុងរយៈពេល ២៤ ម៉ោងបានកន្លងផុតទៅតាំងពីពេលផ្ដើមនៃការឃាត់ខ្លួនមក ហើយការសន្ទនាមានរយៈពេល ៣០ នាទីដោយជននោះអាចចូលក្នុងកន្លែងឃាត់ខ្លួនក្នុងលក្ខខណ្ឌធានាការសម្ងាត់នៃការសន្ទនា ក្រោយពីការសន្ទនាជននោះអាចធ្វើកំណត់សម្គាល់ជាលាយលក្ខណ៍អក្សរដែលត្រូវភ្ជាប់ជាមួយសំណុំរឿង[27]។

ក្រៅពីនេះ ការទទួលជំនួយពីគ្រូពេទ្យក្នុងពេលឃាត់ខ្លួនក៏អាចធ្វើបានដែរ គឺតាមការស្នើសុំរបស់ព្រះរាជអាជ្ញាដើម្បីផ្ទៀងផ្ទាត់មើលថា តើស្ថានភាពសុខភាពនៃបុគ្គលឃាត់ខ្លួននេះសមស្របនឹងការឃាត់ខ្លួនដែរ ឬទេ។ ប្រសិនបើគ្រូពេទ្យយល់ឃើញថាមិនសមស្របនឹងការឃាត់ខ្លួនទេនោះមន្ត្រីនគរបាលយុត្តិធម៌រាយការណ៍ជាបន្ទាន់ដល់ព្រះរាជអាជ្ញា។ គ្រូពេទ្យចេញវិញ្ញាបនប័ត្របញ្ជាក់ពីសុខភាពដែលត្រូវភ្ជាប់ជាមួយសំណុំរឿង ហើយមន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសលើកំណត់ហេតុពីឈ្មោះគ្រូពេទ្យ និងថ្ងៃ ខែ ឆ្នាំ ម៉ោងនៃការពិនិត្យសុខភាព។ ករណីនេះព្រះរាជអាជ្ញាអាចចុះមកកាន់ទីកន្លែងផ្ទាល់ ដើម្បីផ្ទៀងផ្ទាត់លក្ខខណ្ឌនៃការឃាត់ខ្លួន[28]។

ចំណែកការឃាត់ខ្លួនអនីតិជន មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនព័ត៌មានតាមគ្រប់មធ្យោបាយដល់ឪពុកម្ដាយ អ្នកតំណាងស្របច្បាប់ ឬអ្នកទទួលភារកិច្ចលើអនីតិជននេះ[29]។

[27] មាត្រា ៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[28] មាត្រា ៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[29] មាត្រា ១០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

### ២.៣ ការបញ្ជូនកំណត់ហេតុ ភស្តុតាង និងបុគ្គលដែលត្រូវបញ្ជូនទៅដល់ព្រះរាជអាជ្ញា

ក្នុងអំឡុងពេលស៊ើបអង្កេតនោះ គ្រប់កិច្ចទាំងអស់ត្រូវកត់ត្រានៅនឹងកន្លែងក្នុងកំណត់ហេតុដោយមន្ត្រីនគរបាលយុត្តិធម៌ដែលដឹកនាំការស៊ើបអង្កេត។ កាលបើការស៊ើបអង្កេតត្រូវបានបញ្ចប់ កំណត់ហេតុ និងភស្តុតាងនឹងត្រូវធ្វើការបញ្ជូនទៅឱ្យព្រះរាជអាជ្ញា បើពុំដូច្នោះទេនឹងនាំឱ្យមានការមោឃភាពនៃនីតិវិធី។ កាលណាបុគ្គលណាមួយនឹងត្រូវបញ្ជូនទៅឱ្យព្រះរាជអាជ្ញា នោះការបញ្ជូនកំណត់ហេតុ និងវត្ថុតាងទាំងអស់ត្រូវធ្វើជាមួយការបញ្ជូនខ្លួនបុគ្គលនោះផងដែរ[30]។

ប្រសិនបើមានបុគ្គលដែលត្រូវបានឃាត់ខ្លួន នៅពេលដែលផុតកំណត់រយៈពេលឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌សុំសេចក្តីសម្រេចពីព្រះរាជអាជ្ញា ថាតើត្រូវបញ្ជូនខ្លួនជននោះទៅឱ្យព្រះរាជ-អាជ្ញា ឬដោះលែងឱ្យមានសេរីភាពឡើងវិញ[31]។ ប្រសិនបើព្រះរាជអាជ្ញាសម្រេចថាឱ្យបញ្ជូន នោះមន្ត្រីនគរបាលយុត្តិធម៌នឹងបញ្ជូនខ្លួនបុគ្គលនោះ ទៅព្រះរាជអាជ្ញាក្នុងរយៈពេលដ៏ឆាប់បំផុតតាមការដែលអាចធ្វើទៅបាន។ ប្រសិនបើមានការលំបាកក្នុងការដឹកជញ្ជូន ឬចម្ងាយនៃការដឹកជញ្ជូន រយៈពេលបន្ថែមអាចត្រូវបានផ្តល់បន្ថែមដោយព្រះរាជអាជ្ញា[32]។

## ផ្នែកទី២ ការស៊ើបអង្កេតបឋម

សញ្ញាណជាក់ស្តែងនៃការស៊ើបអង្កេតបឋម ឃើញថានៅពុំទាន់បានកំណត់និយមន័យក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៅឡើយទេ។ ទោះជាយ៉ាងនេះក្តី ក៏ឃើញថាមាននិយមន័យដែលស្តីពីការស៊ើបអង្កេតបឋមផងដែរ ដោយបានកំណត់ថាការស៊ើបអង្កេតបឋមគឺជានីតិវិធីមួយដែលមានទម្រង់សាមញ្ញ និងផ្តល់ឱ្យអ្នកស៊ើបអង្កេតនូវអំណាចមួយដែលមានកម្រិត។ ការស៊ើបអង្កេតបឋម គឺជានីតិវិធីរួមមួយដែលត្រូវបានប្រើដោយមន្ត្រីនគរបាលយុត្តិធម៌នៅក្នុងករណីដែលមិនអាច ឬមិនចង់ប្រើនីតិវិធីស៊ើបអង្កេតជាក់ស្តែង ឬការមិនបានចាត់ឱ្យស៊ើបសួរជំនួស[33]។

ការស៊ើបអង្កេតបឋមអាចដំណើរការបានដោយការផ្តួចផ្តើមរបស់មន្ត្រីនគរបាលយុត្តិធម៌ ឬតាមការសុំរបស់ព្រះរាជអាជ្ញា[34]។ ការស៊ើបអង្កេតបឋមដំណើរការនៅក្នុងករណីដែលបទឧក្រិដ្ឋ ឬ

[30] មាត្រា ១០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[31] មាត្រា ១០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[32] មាត្រា ១០៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[33] សៀវភៅនីតិវិធីព្រហ្មទណ្ឌសម្រាប់នគរបាលឆ្នាំ ២០០៩ ទំព័រ៦០

[34] មាត្រា ១១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

បទមជ្ឈិមមិនជាក់ស្តែង ឬបទលហុ ឬក៏ក្នុងករណីដែលថិរវេលានៃការស៊ើបអង្កេតករណីជាក់ស្តែងបានកន្លងហួសផុតទៅ ដោយមាត្រា ១០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌកំណត់ថិរវេលាសម្រាប់ការស៊ើបអង្កេតជាក់ស្តែងតែចំនួន ៧ (ប្រាំពីរ) ថ្ងៃប៉ុណ្ណោះគិតចាប់ពីថ្ងៃប្រព្រឹត្តបទល្មើស។

ផ្ទុយពីការស៊ើបអង្កេតបទល្មើសជាក់ស្តែងជាគោលការណ៍ការស៊ើបអង្កេតបឋមមិនត្រូវបានកំណត់ពីថិរវេលាទេ។

អំណាច និងកាតព្វកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតបឋមមានលក្ខណៈប្រហាក់ប្រហែលនឹងអំណាច និងកាតព្វកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតករណីជាក់ស្តែងផងដែរ គ្រាន់តែបទបញ្ញត្តិយោងមានភាពខុសគ្នាតែប៉ុណ្ណោះ។ វិធានទាក់ទិននឹងការស៊ើបអង្កេតបឋម គឺឃើញមានចែងចាប់ពីមាត្រា ១១១ ដល់មាត្រា ១១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ទាក់ទិននឹងដំណើរការនៃការស៊ើបអង្កេតបឋម មាត្រា ១១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់អំពីកិច្ចស៊ើបសួរដែលមានចែងយ៉ាងលម្អិតក្នុងការស៊ើបអង្កេតជាក់ស្តែង តែត្រូវបានយកមកអនុវត្តដែរចំពោះការស៊ើបអង្កេតបឋម។ ក្នុងក្របខ័ណ្ឌការស៊ើបអង្កេតនេះ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការពិនិត្យបច្ចេកទេស ឬវិទ្យាសាស្ត្រដោយត្រូវធ្វើការពិនិត្យកត់ត្រាដែលមានប្រយោជន៍ និងធ្វើកំណត់ហេតុ។ លើសពីនេះ នៅចុងបញ្ចប់នៃការស៊ើបអង្កេតបឋមមន្ត្រីនគរបាលយុត្តិធម៌ក៏ត្រូវបញ្ជូនកំណត់ហេតុ និងវត្ថុតាងនានាទៅព្រះរាជអាជ្ញា។

ចំណុចដែលខុសប្លែកគ្នាខ្លាំងរវាងការស៊ើបអង្កេតករណីជាក់ស្តែង និងការស៊ើបអង្កេតបឋមនោះគឺទាក់ទិននឹងអំណាចនៃការឆែកឆេរ ដោយកាលណាការស៊ើបអង្កេតជាបឋមនោះទាក់ទងនឹងបទឧក្រិដ្ឋ ឬបទមជ្ឈិម មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរ និងចាប់យកវត្ថុតាង។ មន្ត្រីនគរ-បាលយុត្តិធម៌ ជាបឋមត្រូវទទួលការយល់ព្រមច្បាស់លាស់ និងពិតប្រាកដពីអ្នកកាន់កាប់ទីកន្លែង ហើយការយល់ព្រមនោះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ គឺសរសេរដោយផ្ទាល់ដៃរបស់អ្នកកាន់កាប់ទីកន្លែង។ ប្រសិនបើអ្នកកាន់កាប់ទីកន្លែងមិនចេះអក្សរទេនោះត្រូវសរសេរឱ្យបានច្បាស់លាស់ក្នុងកំណត់ហេតុថា អ្នកកាន់កាប់ទីកន្លែងនោះមិនចេះអក្សរ ហើយយល់ព្រមឱ្យឆែកឆេរ[35]។

[35] មាត្រា ១១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ក្នុងករណីដែលអ្នកកាន់កាប់ទីកន្លែងអវត្តមាន ឬបដិសេធការឆែកឆេរ ប្រធានសាលាដំបូងដែលមានសមត្ថកិច្ចដែនដី អាចចេញដីកាអនុញ្ញាតឱ្យឆែកឆេរតាមការសុំរបស់ព្រះរាជអាជ្ញាហើយព្រះរាជអាជ្ញាត្រូវដឹកនាំដោយផ្ទាល់នូវការឆែកឆេរនេះ។ ការឆែកឆេរត្រូវធ្វើនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេត្រូវធ្វើនៅចំពោះមុខសាក្សីពីរនាក់។ សាក្សីនោះត្រូវចាត់តាំងដោយព្រះរាជអាជ្ញា ហើយសាក្សីមិនអាចជានគរបាល ឬកងរាជអាវុធហត្ថដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះឡើយ។ ការឆែកឆេរមិនអាចផ្ដើមមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចឡើយ។

បទប្បញ្ញត្តិនៃមាត្រា ៩២ (ការបិទស្លាកបោះត្រាលើវត្ថុតាង) នៃក្រមនីតិវិធីព្រហ្មទណ្ឌត្រូវយកមកអនុវត្តក្នុងការចាប់យកវត្ថុតាង។

ក្រៅពីនេះ ចំពោះការបញ្ជាឱ្យចូលខ្លួន ការធ្វើកំណត់ហេតុស្រង់ចម្លើយក្នុងការស៊ើបអង្កេតបឋម ក៏ត្រូវបានអនុវត្តនីតិវិធីដូចគ្នាទៅនឹងការស៊ើបអង្កេតករណីជាក់ស្ដែងផងដែរ។ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឃាត់ខ្លួនក្នុងករណីការស៊ើបអង្កេតបឋមធ្វើឡើងចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម។ បទប្បញ្ញត្តិដែលចែងសម្រាប់អនុវត្តក្នុងក្របខ័ណ្ឌការស៊ើបអង្កេតជាក់ស្ដែងត្រូវអនុវត្តទាំងស្រុង[36]។

កំណត់ហេតុ និងរបាយការណ៍ស៊ើបអង្កេតដែលពិនិត្យបទឧក្រិដ្ឋ ឬបទមជ្ឈិម ឬបទលហុមានតម្លៃត្រឹមតែជាព័ត៌មានធម្មតាប៉ុណ្ណោះ[37]។ ប៉ុន្តែ កំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវទុកជាបន្ទាល់ "ឯកសារដើម" មានន័យថាត្រូវទុកជាឯកសារដែលត្រូវជឿរហូតដល់មានភស្តុតាងផ្ទុយ។ ភស្តុតាងផ្ទុយអាចជូនមកចៅក្រមបានដោយសេរីតាមគ្រប់មធ្យោបាយត្រឹមត្រូវតាមច្បាប់។ ចៅក្រមអាចធ្វើមូលវិចារណ៍ដោយសេរីលើកំណត់ហេតុ ដែលធ្វើដោយមន្ត្រីនគរបាលយុត្តិធម៌ក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតបឋម។

[36] មាត្រា ១១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[37] មាត្រា ១១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

# ជំពូកទី៣
# ដំណាក់កាលការចោទប្រកាន់ក្នុងរឿងក្តីព្រហ្មទណ្ឌ

នៅពេលដែលយល់ឃើញថាការស៊ើបអង្កេតជាបឋមក្តី ឬការស៊ើបអង្កេតករណីជាក់ស្តែងក្តី ត្រូវបានបញ្ចប់នោះមន្រ្តីនគរបាលយុត្តិធម៌ និងភ្នាក់ងារទាំងនោះនឹងត្រូវប្រគល់នីតិវិធីទាំងមូលទៅអយ្យការ។ ក្រោយពីទទួលនីតិវិធីព្រះរាជអាជ្ញាធ្វើការសិក្សាវាយតម្លៃស្ថានការណ៍ គឺមានន័យថាភាពជាក់លាក់ និងភាពសមហេតុផលរបស់ភស្តុតាងដែលទទួលបាន និងលទ្ធភាពស្របច្បាប់ដែលនីតិវិធីផ្តល់ឱ្យក្រោមរូបភាពជាបណ្តឹង។

ចំពោះបទល្មើសព្រហ្មទណ្ឌបានបង្កើតឱ្យមានបណ្តឹងពីរប្រភេទផ្សេងគ្នា គឺបណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី។ បណ្តឹងអាជ្ញា គឺជាបណ្តឹងដើម្បីផលប្រយោជន៍ទូទៅដែលមានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឱ្យឃើញពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជននោះតាមច្បាប់កំណត់។ ឯបណ្តឹងរដ្ឋប្បវេណីវិញ ជាបណ្តឹងដើម្បីជួសជុលការខូចខាតដែលបណ្តាលមកពីបទល្មើសដល់ភាគីរងគ្រោះ[38]។

ព្រះរាជអាជ្ញាមានតួនាទីយ៉ាងសំខាន់ក្នុងការធ្វើឱ្យបណ្តឹងមានចលនា មានន័យថាត្រូវចោទប្រកាន់អំពីបទល្មើសណាមួយ។ ការចោទប្រកាន់នោះអាចធ្វើតាមរយៈបណ្តឹងអាជ្ញា។

## ផ្នែកទី១៖ លក្ខខណ្ឌនៃការចោទប្រកាន់

ក្រោយពីការទទួលបណ្តឹងទាមទារ ឬបណ្តឹងបរិហារពីជនណាម្នាក់ ឬទទួលរបាយការណ៍ពីមន្រ្តីនគរបាលយុត្តិធម៌ អយ្យការអាចមិនទាន់ធ្វើការចោទប្រកាន់ ប្រសិនបើយល់ឃើញថាពុំទាន់មានភស្តុតាងគ្រប់គ្រាន់ដើម្បីធ្វើការចោទប្រកាន់នៅឡើយ។ អយ្យការអាចបង្គាប់ឱ្យមន្រ្តីនគរបាលយុត្តិធម៌ស្វែងរកភស្តុតាងបន្ថែម ឬបើកការស៊ើបអង្កេតបឋមបាន[39]។

ដោយហេតុថាព្រះរាជអាជ្ញាជាម្ចាស់ដើមបណ្តឹងអាជ្ញា គាត់អាចទទួលពាក្យបណ្តឹងពីរឿងព្រហ្មទណ្ឌណាមួយបាន។ ពាក្យបណ្តឹងនោះអាចធ្វើឡើងដោយជនរងគ្រោះ ឬសាច់ញាតិរបស់ជនរងគ្រោះ មន្រ្តីនគរបាលយុត្តិធម៌ មន្រ្តីផ្សេងទៀតដែលមានសមត្ថកិច្ចចាត់ការរឿងព្រហ្មទណ្ឌ ឬក៏តតិយជនដែលដឹងលឺពីបទល្មើសឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ។

[38] មាត្រា ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[39] មាត្រា ៤០ កថាខណ្ឌទី២ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

**១. ការពិនិត្យទៅលើគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់**

គោលការណ៍កាលានុវត្តភាព ជាគោលការណ៍មួយដែលផ្តល់ឱ្យព្រះរាជអាជ្ញានូវសេរីភាពក្នុងការវាយតម្លៃថាគួរតែដាក់ពាក្យបណ្តឹងអាជ្ញា ឬមិនដាក់ដោយផ្អែកលើទម្ងន់ទោសនៃបទល្មើស កាលៈទេសៈនៃការប្រព្រឹត្ត ភាពរីករាលដល់សណ្តាប់ធ្នាប់សាធារណៈ និងធាតុដែលប្រមូលបានក្នុងពេលស៊ើបអង្កេត។

ជាដំបូងព្រះរាជអាជ្ញាត្រូវធានាឱ្យបានច្បាស់ថា ធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌគឺមានសព្វគ្រប់ហើយ ត្រូវវាយតម្លៃកំណត់បទល្មើសសមស្របទៅនឹងអំពើដោយពិនិត្យទៅលើធាតុផ្សំសត្យានុម័ត ធាតុផ្សំអត្តនោម័ត ពិនិត្យថាតើករណីនេះមានអភ័យឯកសិទ្ធិដែរឬទេ ហើយជនល្មើសត្រូវចោទប្រកាន់ក្នុងនាមជាអ្វី ថាតើជាចារី ឬជាអ្នកសមគំនិត ឬជាសហចារីជាដើម។

ក្រៅពីនេះព្រះរាជអាជ្ញាក៏ត្រូវពិនិត្យទៅលើបញ្ហាទម្រង់មួយចំនួនដូចជា ករណីរំលត់បណ្តឹងអាជ្ញា បញ្ហាសមត្ថកិច្ច ឬករណីនេះចាំបាច់ត្រូវមានបណ្តឹងពីជនរងគ្រោះដែរឬទេ។

ក្រមនីតិវិធីព្រហ្មទណ្ឌថ្មីឆ្នាំ ២០០៧ បានជ្រើសរើសយកគោលការណ៍នៃកាលានុវត្តភាពនៃការចោទប្រកាន់ ដោយមានសភាពផ្ទុយពីគោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់ដូចមានចែងក្នុងច្បាប់នីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ និងការអនុវត្តក្នុងបណ្តាប្រទេសមួយចំនួនដែលតម្រូវឱ្យព្រះរាជអាជ្ញាធ្វើការចោទប្រកាន់រាល់ពេលដែលខ្លួនដឹងថាមានបទល្មើស។ ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៤០ កថាខណ្ឌទី២ បានចែងថាព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ។ បទប្បញ្ញត្តិនេះ ជាបទប្បញ្ញត្តិគោលមួយដែលនាំឱ្យមានការបកស្រាយថាក្រមនីតិវិធីព្រហ្មទណ្ឌប្រកាន់យកគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់។

**២. សេរីភាពក្នុងការសម្រេចរបស់ព្រះរាជអាជ្ញា**

ជាគោលការណ៍ ព្រះរាជអាជ្ញាមានសេរីភាពពេញលេញក្នុងការសម្រេចពីការចោទប្រកាន់ ឬមិនធ្វើការចោទប្រកាន់។ ប៉ុន្តែដោយហេតុថា ព្រះរាជអាជ្ញាស្ថិតក្នុងអង្គដែលមានឋានានុក្រម ដូច្នេះព្រះរាជអាជ្ញាត្រូវធ្វើតាមបង្គាប់របស់ថ្នាក់លើតាមឋានានុក្រមរបស់ខ្លួន ដែលបង្គាប់បញ្ជាឱ្យធ្វើការចោទប្រកាន់លើអំពើអ្វីមួយ ទោះបីជាព្រះរាជអាជ្ញាសាមីខ្លួនផ្ទាល់យល់ឃើញថាមិនគួរត្រូវចោទប្រកាន់ក៏ដោយ។ គួរបញ្ជាក់ផងដែរថា មានតែការបញ្ជាឱ្យចោទប្រកាន់ប៉ុណ្ណោះដែលព្រះរាជអាជ្ញាត្រូវអនុវត្តតាម ផ្ទុយទៅវិញប្រសិនបើមានបញ្ជាមិនឱ្យចោទប្រកាន់ ប៉ុន្តែព្រះរាជអាជ្ញាបានធ្វើការ

ចោទប្រកាន់រួចទៅហើយនោះព្រះរាជអាជ្ញាគ្មានសិទ្ធិអាចដកហូតការចោទប្រកាន់របស់ខ្លួនបានវិញនោះទេ។

ទន្ទឹមនឹងនេះដែរ ត្រូវគូសបញ្ជាក់ផងដែរថាពេលខ្លះការចោទប្រកាន់ទាមទារចាំបាច់ឱ្យមានជាមុននូវ[40]៖

- បណ្តឹងរបស់ជនរងគ្រោះ ឧទាហរណ៍: បទជិត (តាមច្បាប់ស្តីពីឯកពន្ធភាព)។
- ការអនុញ្ញាតពិសេស ឧទាហរណ៍: ជនមានអភ័យឯកសិទ្ធិសភា។

## ផ្នែកទី២៖ សេចក្តីសម្រេចរបស់អយ្យការ

ក្រោយពីបានពិនិត្យឯកសារសំណុំរឿងរួចចប់សព្វគ្រប់ហើយ អង្គការអយ្យការត្រូវធ្វើការសម្រេចសេចក្តីថាត្រូវចោទប្រកាន់ ឬមិនចោទប្រកាន់។

### ១. ការតម្កល់រឿងទុកឥតចាត់ការ

ប្រសិនបើព្រះរាជអាជ្ញាយល់ថា អំពើដែលគេប្តឹងមកជារឿងរដ្ឋប្បវេណីមិនមែនជាបទល្មើសព្រហ្មទណ្ឌ មានន័យថាអំពើប្រព្រឹត្តមិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុដែលច្បាប់កំណត់ផ្តន្ទាទោស ឬគ្មានពិរុទ្ធភាពគ្រប់គ្រាន់សម្រាប់ធ្វើការចោទប្រកាន់ ឬគ្មានភស្តុតាងណាដែលគួរឱ្យជឿថាពិតជាមានបទល្មើសកើតឡើងមែននោះ ព្រះរាជអាជ្ញានឹងចេញដីកាតម្កល់រឿងទុកឥតចាត់ការដោយមានទាំងសំអាងច្បាប់ និងទាំងសំអាងហេតុ។ ចំពោះការតម្កល់រឿងទុកឥតចាត់ការនេះ ព្រះរាជអាជ្ញា ត្រូវឱ្យដំណឹងដល់អ្នកប្តឹងអំពីសេចក្តីសម្រេចរបស់ខ្លួននៅក្នុងរយៈពេលយ៉ាងខ្លីបំផុត ហើយយ៉ាងយូរបំផុតរយៈពេល ២ (ពីរ) ខែ គិតចាប់ពីថ្ងៃចុះពាក្យប្តឹងក្នុងបញ្ជីនៃពាក្យប្តឹង។ ដីកាតម្កល់រឿងទុកឥតចាត់ការ អាចប្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ក្នុងរយៈពេល ២(ពីរ) ខែ គិតចាប់ពីថ្ងៃទទួលដំណឹងពីសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការនេះ អ្នកប្តឹងតវ៉ាអាចធ្វើជាបណ្តឹងសាមញ្ញ ដោយធ្វើការដាក់ពាក្យមកកាន់អង្គការអយ្យការពាក់ព័ន្ធ ហើយតំណាងអយ្យការអមសាលាដំបូងនឹងបញ្ជូននូវសំណុំរឿងភ្លាមជូនទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ ករណីដែលអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ បានយល់ឃើញថាការតវ៉ានោះប្រកបដោយមូលហេតុត្រឹមត្រូវ អគ្គព្រះរាជអាជ្ញានឹងធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរទៅព្រះរាជអាជ្ញា

[40] សៀវភៅមេរៀននីតិវិធីព្រហ្មទណ្ឌ លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត

អមសាលាដំបូងធ្វើការចោទប្រកាន់។ ករណីផ្ទុយពីនេះ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អាចធ្វើការតម្កល់សេចក្តីសម្រេចរបស់ព្រះរាជអាជ្ញាអមសាលាដំបូងទុកជាបានការ ហើយអគ្គព្រះរាជ-អាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនៃការតម្កល់សេចក្តីសម្រេចនេះជូនទៅដល់អ្នកប្តឹងតវ៉ាវិញ[41]។

ទោះជាយ៉ាងណាសេចក្តីសម្រេចនេះពុំមានអាជ្ញាអស់ជំនុំទេ ដោយព្រះរាជអាជ្ញាអាចសើរើកែប្រែសេចក្តីសម្រេចរបស់ខ្លួនវិញនៅពេលដែលបណ្តឹងអាជ្ញាមិនទាន់រលត់។

**២. ការចោទប្រកាន់**

នៅពេលដែលមានភស្តុតាងធនល្មមអាចជឿបានថា ជនសង្ស័យអាចនឹងប្រព្រឹត្តអំពើដែលគេប្តឹងមកនោះមែន ព្រះរាជអាជ្ញានឹងចាប់ផ្តើមធ្វើការចោទប្រកាន់។

ក្នុងករណីដែលមន្រ្តីរាជការណាម្នាក់ត្រូវបានតុលាការធ្វើការចោទប្រកាន់ ព្រះរាជអាជ្ញាត្រូវជូនដំណឹងអំពីការចោទប្រកាន់នេះទៅប្រធានស្ថាប័នសាមី ក្នុងរយៈពេល ៧២ ម៉ោងយ៉ាងយូរ[42]។

ការចាប់ផ្តើមចោទប្រកាន់ចំពោះអនីតិជនត្រូវជូនដំណឹងទៅអនីតិជនជាប់សង្ស័យ និងឪពុកម្តាយ ឬអាណាព្យាបាលរបស់អនីតិជននោះ។ ទាក់ទងនឹងអនីតិជនដែលជាជនជាប់សង្ស័យសេចក្តីណែនាំអំពីការអនុវត្តគោលការណ៍នានាក្នុងច្បាប់ជាតិ និងអន្តរជាតិដែលកំពុងនៅចូលជាធរមានទាក់ទងនឹងយុត្តិធម៌អនីតិជនចេញដោយរដ្ឋមន្រ្តីក្រសួងយុត្តិធម៌ ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ២០០៥ បានកំណត់ថា ប្រសិនបើមានភាពមិនច្បាស់លាស់អំពីអាយុរបស់អនីតិជនដែលជាប់សង្ស័យនោះ ព្រះរាជអាជ្ញាគប្បីធ្វើការស៊ើបអង្កេតបន្ថែម ដើម្បីស្វែងរកការពិតនៃអាយុរបស់អនីតិជនដែលជាប់សង្ស័យនោះ។

- ប្រសិនបើលទ្ធផលនៃការស៊ើបអង្កេតបឋមបង្ហាញឱ្យឃើញថា អាយុរបស់អនីតិជនជាប់សង្ស័យតិចជាង ១៣ ឆ្នាំ ព្រះរាជអាជ្ញាគប្បីចេញដីកាតម្កល់រឿងទុកឥតចាត់ការ ហើយផ្តល់ដំណឹងឱ្យទៅភាគីដើមបណ្តឹងរដ្ឋប្បវេណី។
- ប្រសិនបើលទ្ធផលនៃការស៊ើបអង្កេតបឋមបង្ហាញឱ្យឃើញថា អាយុរបស់អនីតិជនជាប់សង្ស័យនោះចាប់ពី ១៤ ឆ្នាំ ឡើងទៅតែតិចជាង ១៨ ឆ្នាំ ព្រះរាជអាជ្ញាអាចផ្តើមចោទប្រកាន់បាន។

[41] មាត្រា ៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[42] មាត្រា ៥១ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្រ្តីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៤

- ប្រសិនបើរកមិនឃើញអាយុពិតប្រាកដរបស់អនីតិជន ព្រះរាជអាជ្ញាត្រូវធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដើម្បីឱ្យចៅក្រមស៊ើបសួរពីបញ្ហាអាយុ។

ការចោទប្រកាន់របស់ព្រះរាជអាជ្ញានៅក្នុងរឿងក្តីព្រហ្មទណ្ឌអាចធ្វើទៅតាមរយៈ ការប្តឹងទៅយុត្តាធិការស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ការប្តឹងទៅយុត្តាធិការជំនុំជម្រះតាមរយៈការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬការធ្វើកំណត់ហេតុបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម[43]។

### ២.១ ការបើកការស៊ើបសួរ

ការស៊ើបសួរត្រូវបានបើកតាមដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ដែលធ្វើឡើងដោយព្រះរាជអាជ្ញាប្តឹងទៅចៅក្រមស៊ើបសួរ ឱ្យធ្វើការស៊ើបសួរទៅលើអង្គហេតុដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ការស៊ើបសួរអាចបើកប្រឆាំងលើបុគ្គលម្នាក់ ឬច្រើននាក់ដោយមានចង្អុលប្រាប់ឈ្មោះ ឬប្រឆាំងទៅលើអញ្ញាតជន។ ក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរតម្រូវឱ្យមាននិទ្ទេសដូចជា[44]៖

- សេចក្តីសង្ខេបនៃអង្គហេតុ
- ការកំណត់ឈ្មោះបទល្មើស
- ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស
- ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន (ក្នុងករណីមិនអាចកំណត់បាន អាចបើកការស៊ើបសួរប្រឆាំងនឹងអញ្ញាតជន ពោលគឺជនមិនស្គាល់)
- ចុះកាលបរិច្ឆេទ និងហត្ថលេខា។

ចំពោះទម្រង់ការនេះមានលក្ខណៈដាច់ខាតត្រូវតែគោរព បើពុំដូច្នោះទេដីកាបញ្ជូនរឿងឱ្យស៊ើបសួរនេះត្រូវទុកជាមោឃៈ។

ករណីដែលព្រះរាជអាជ្ញាមានកាតព្វកិច្ច ធ្វើដីកាបញ្ជូនរឿងឱ្យស៊ើបសួរឲ្យចៅក្រមស៊ើបសួរមានដូចជា៖

- ករណីបទល្មើសឧក្រិដ្ឋជាក់ស្តែង ឬមិនជាក់ស្តែង
- ករណីបទល្មើសមជ្ឈិមដែលព្រះរាជអាជ្ញាយល់ឃើញថាត្រូវបើកការស៊ើបសួរ។

[43] មាត្រា ៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[44] មាត្រា ៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ចៅក្រមស៊ើបសួរអាចធ្វើការស៊ើបសួរតែអំពីហេតុ ដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរតែប៉ុណ្ណោះ។ ម្យ៉ាងទៀត បើព្រះរាជអាជ្ញាទទួលដំណឹងពីហេតុថ្មីៗដែលពាក់ព័ន្ធទៅនឹងបទល្មើសដែលលើកឡើងដំបូងគេបង្អស់នោះ ព្រះរាជអាជ្ញាអាចពង្រីកបណ្តឹងទៅចៅក្រមស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបន្ថែម។ នៅក្នុងដីកាសន្និដ្ឋានបន្ថែម ក៏ត្រូវមាននិទ្ទេសដូចគ្រប់កិច្ចអនុវត្តបណ្តឹងអាជ្ញាដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដែរ ដូចដែលមានចែងក្នុងមាត្រា ៨៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

មូលហេតុដែលនៅក្នុងដីកាតម្រូវឱ្យមានចុះកាលបរិច្ឆេទ និងហត្ថលេខា ដោយហេតុថាការចុះកាលបរិច្ឆេទនេះ វាបានផ្តល់ភាពងាយស្រួលសម្រាប់ការផ្ទៀងផ្ទាត់ថាបណ្តឹងអាជ្ញាមិនទាន់ផុតអាជ្ញាយុកាល ថាចៅក្រមស៊ើបសួរមិនបានធ្វើការស៊ើបសួរមុនពេលទទួលបណ្តឹង។ ចំណែកការចុះហត្ថលេខាវិញ វាជាហត្ថលេខារបស់ព្រះរាជអាជ្ញាដែលបានចេញដីកានោះដែលបញ្ជាក់ពីឆន្ទៈរបស់អង្គការអយ្យការក្នុងការចោទប្រកាន់។

### ២.២ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់

ការបញ្ជូនទៅជំនុំជម្រះផ្ទាល់នេះ អាចធ្វើទៅបានតាមរយៈដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់។ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់អាចធ្វើបានតែចំពោះបទល្មើសមជ្ឈិម[45] និងបទល្មើសលហុ[46] តែប៉ុណ្ណោះ។

ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ វាគឺជានីតិវិធីមួយដែលព្រះរាជអាជ្ញាធ្វើការសម្រេចចោទប្រកាន់ទៅជនជាប់សង្ស័យពីរឿងព្រហ្មទណ្ឌ និងជាបញ្ជាឱ្យជនជាប់ចោទចូលបង្ហាញខ្លួននៅមុខតុលាការជាន់ដំបូង ដែលសម្រេចពីរឿងក្តីព្រហ្មទណ្ឌ[47]។

ចំពោះទម្រង់នៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ នៅដើមនៃដីកាត្រូវមានការចុះនូវកាលបរិច្ឆេទ ទីកន្លែងកំណើត និងទីលំនៅឋានរបស់ជនជាប់ចោទ ព្រមទាំងមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយព្រះរាជអាជ្ញា[48]។ នៅក្នុងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ត្រូវចុះនូវៈ

[45] មាត្រា ៨៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[46] មាត្រា ៨៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[47] មាត្រា ៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[48] មាត្រា ៨៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

- អត្តសញ្ញាណនៃជនជាប់ចោទ
- សេចក្តីសង្ខេបនៃអង្គហេតុ
- ឈ្មោះបទល្មើស
- អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស
- ការចង្អុលបង្ហាញប្រាប់ពីតុលាការ ព្រមទាំងទីកន្លែង កាលបរិច្ឆេទ និងម៉ោងពេលនៃដំណើរការសវនាការ
- ការបញ្ជាក់ថាជនជាប់ចោទអាចពឹងមេធាវីឱ្យអមខ្លួនបាន។

ចំពោះរយៈពេលដែលត្រូវគោរពរវាង ការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ឱ្យដល់ជនជាប់ចោទ និងថ្ងៃកំណត់ឱ្យចូលបង្ហាញខ្លួននៅមុខតុលាការត្រូវកំណត់ដូចតទៅ[49]៖

- ថិរវេលានៃការបញ្ជូនដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ មុនកាលបរិច្ឆេទនៃសវនាការ ១៥ (ដប់ប្រាំ) ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដីនៃទីស្នាក់ការរបស់តុលាការជាន់ដំបូង
- ថិរវេលានៃការបញ្ជូនដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ មុនកាលបរិច្ឆេទនៃសវនាការ ២០ (ម្ភៃ) ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែងមួយផ្សេងទៀតក្នុងដែនដីជាតិ
- ថិរវេលានៃការបញ្ជូនដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ មុនកាលបរិច្ឆេទនៃសវនាការ ២ (ពីរ) ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងរដ្ឋមួយជាប់ព្រំដែនព្រះរាជាណាចក្រកម្ពុជា
- ថិរវេលានៃការបញ្ជូនដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ មុនកាលបរិច្ឆេទនៃសវនាការ ៣ (បី) ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែងដទៃផ្សេងទៀត។

ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ អាចត្រូវបានប្រគល់ឱ្យជនជាប់ចោទដោយផ្ទាល់ដៃដោយព្រះរាជអាជ្ញា ឬដោយអាជ្ញាសាលា។ ប្រសិនបើលិខិតត្រូវបានប្រគល់ឱ្យដោយអាជ្ញាសាលា នោះអាជ្ញាសាលាត្រូវបង្ហាញថាលិខិតនេះបានប្រគល់ឱ្យដល់ជនជាប់ចោទ ឬដល់បុគ្គលដែលមានវត្តមាននៅលំនៅឋានរបស់ជនជាប់ចោទ ដោយបុគ្គលនោះត្រូវតែប្រគល់ដីកានេះក្នុងរយៈពេលខ្លីបំផុតឱ្យដល់ជនជាប់ចោទ។

ម្យ៉ាងទៀត អាជ្ញាសាលាអាចនឹងប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ឱ្យមេឃុំ ឬ

---

[49] មាត្រា ៤៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ចៅសង្កាត់ ឬជំទប់ ឬចៅសង្កាត់រង នៅក្នុងករណីដែលជនជាប់ចោទមិនព្រមទទួលដីកាកោះហៅ បញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬគ្មានបុគ្គលណាម្នាក់មានវត្តមាននៅក្នុងលំនៅឋានរបស់ជនជាប់ចោទ ឬ គ្មានបុគ្គលណាម្នាក់ដែលមានវត្តមាននៅក្នុងលំនៅឋានរបស់ជនជាប់ចោទ យល់ព្រមទទួលដីកាកោះទេ។ បុគ្គលដែលទទួលដីកាក៏ត្រូវសន្យាថានឹងប្រគល់ដីកានេះក្នុងរយៈពេលខ្លីបំផុតឱ្យដល់ជនជាប់ចោទ[50]។

ប៉ុន្តែ ដីកាកោះនេះក៏អាចត្រូវប្រគល់ឱ្យដោយក្រឡាបញ្ជី តាមផ្លូវរដ្ឋបាល ដោយប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ប្រសិនបើជនជាប់ចោទត្រូវបានឃុំខ្លួនពីបទល្មើសផ្សេងទៀត ឬជាចុងក្រោយតាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ។

**២.៣ នីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម**

ប្រសិនបើលក្ខខណ្ឌនៃមាត្រា ៤៧ និងមាត្រា ៣០៤នៃក្រមនីតិវិធីព្រហ្មទណ្ឌត្រូវបានបំពេញ ព្រះរាជអាជ្ញាអាចប្រើប្រាស់នីតិវិធីនេះបាន ដោយគ្រាន់តែធ្វើកំណត់ហេតុតែប៉ុណ្ណោះពុំមានចេញជាដីកាសន្និដ្ឋានអ្វីនោះទេ។ នីតិវិធីនេះអនុញ្ញាតឲ្យព្រះរាជអាជ្ញាអាចបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទចូលបង្ហាញខ្លួនភ្លាមនៅមុខតុលាការជាន់ដំបូង បន្ទាប់ពីបញ្ចប់ការឃាត់ខ្លួន។ វិធាននៃនីតិវិធីបែបនេះមិនត្រូវបានអនុវត្តចំពោះបទឧក្រិដ្ឋ និងបទលហុទេ។ វិធាននេះអាចអនុវត្តបានលុះត្រាតែគោរពលក្ខខណ្ឌមួយចំនួនដូចជា[51]៖

- ប្រភេទចំណាត់ការសំនុំរឿងនេះអាចធ្វើបានតែក្នុងករណីបទមជ្ឈិមជាក់ស្តែងប៉ុណ្ណោះ
- បទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច ១ (មួយ) ឆ្នាំ និងយ៉ាងច្រើន ៥ (ប្រាំ) ឆ្នាំ
- បទល្មើសប្រព្រឹត្តដោយនីតិជន
- សំណុំរឿងត្រូវស្ថិតក្នុងស្ថានភាពដែលអាចបញ្ជូនទៅជំនុំជម្រះបាន មានន័យថាបន្ទុកដែលប្រមូលបានមានលក្ខណៈគ្រប់គ្រាន់ល្មម។

ពេលបញ្ចប់ការឃាត់ខ្លួន បុគ្គលដែលឃាត់ខ្លួនត្រូវបញ្ជូនដោយមានកងកម្លាំងការពារដើម្បីឱ្យចូលបង្ហាញខ្លួននៅចំពោះមុខព្រះរាជអាជ្ញា។ មាត្រា ៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌមានចែងអំពីនីតិវិធីនៃការបង្ហាញខ្លួនភ្លាម ដោយកាលណាសម្រេចថាត្រូវប្រើនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម

[50] មាត្រា ៤៥៨ ដល់មាត្រា ៤៦៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[51] មាត្រា ៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ព្រះរាជអាជ្ញាត្រូវៈ

- ពិនិត្យអត្តសញ្ញាណបុគ្គលដែលគេបញ្ជូនមកឱ្យខ្លួន
- ជូនដំណឹងដល់ជននោះអំពីរឿងរ៉ាវដែលចោទប្រកាន់ និងឈ្មោះបទល្មើស
- ទទួលចម្លើយរបស់បុគ្គលនោះប្រសិនបើសាមីខ្លួនចង់និយាយ
- ធ្វើកំណត់ហេតុស្តីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម។

ព្រះរាជអាជ្ញាក៏ត្រូវប្រាប់ទៅជនជាប់ចោទថា ជននេះនឹងត្រូវជំនុំជម្រះនៅក្នុងថ្ងៃនោះតែម្តង ដោយធ្វើនៅសាលាដំបូង ហើយជននេះមានសិទ្ធិសុំពឹងមេធាវីតាមការជ្រើសរើសរបស់ខ្លួន ឬចាត់តាំងឡើងដោយអនុលោមតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។ ចំពោះមេធាវីដែលត្រូវបានជ្រើសរើស ឬចាត់តាំងត្រូវទទួលបានដំណឹងភ្លាម ដើម្បីឱ្យមេធាវីអាចធ្វើការពិនិត្យសំណុំរឿង និងទាក់ទងជាមួយជនជាប់ចោទបាន។

តុលាការជាន់ដំបូងត្រូវបានទទួលបណ្តឹងតាមកំណត់ហេតុស្តីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម។ បន្ទាប់ពីនោះ តុលាការត្រូវផ្ទៀងផ្ទាត់មើលអត្តសញ្ញាណរបស់ជនជាប់ចោទ និងធ្វើរបាយ-ការណ៍សង្ខេបរឿងរ៉ាវដែលបានចោទប្រកាន់ និងត្រូវប្រាប់ដល់ជនជាប់ចោទថាសាមីខ្លួនអាចមានរយៈពេលដើម្បីរៀបចំការពារខ្លួន។ ប្រសិនបើជនជាប់ចោទសុំរយៈពេល ឬប្រសិនបើតុលាការយល់ឃើញថារឿងក្តីនេះមិនទាន់អាចធ្វើការជំនុំជម្រះភ្លាមៗបានទេនោះ សំណុំរឿងត្រូវលើកទៅពេលសវនាការក្រោយទៀត។ ករណីនេះ តុលាការអាចបង្គាប់ឱ្យឃុំខ្លួនជនជាប់ចោទជាបណ្តោះអាសន្ន ដោយសាលក្រមដែលមានបញ្ជាក់ពីសំអាងហេតុ។ សាលក្រមលើអង្គសេចក្តី ត្រូវតែប្រកាសក្នុងរយៈពេលដែលមិនអាចលើសពី ២ (ពីរ) សប្តាហ៍ គិតចាប់ពីថ្ងៃចូលទៅបង្ហាញខ្លួននៅមុខតុលាការ ហើយការឃុំខ្លួនបណ្តោះអាសន្ននឹងត្រូវតែបញ្ឈប់ដោយពេញច្បាប់ ក្រោយពីផុតរយៈពេល ២ (ពីរ) សប្តាហ៍។ ប៉ុន្តែ ប្រសិនបើតុលាការដែលបានទទួលបណ្តឹងតាមនីតិវិធីបង្គាប់ឱ្យបង្ហាញខ្លួនភ្លាម យល់ឃើញថាលក្ខខណ្ឌនៃការបង្ហាញខ្លួនភ្លាមមិនបានបំពេញទេ ឬក៏ដោយសារតែភាពសាំញ៉ាំនៃសំណុំរឿងដែលតម្រូវជាចាំបាច់ឱ្យធ្វើការស្រាវជ្រាវបន្ថែម និងច្បាស់លាស់ជាងមុន តុលាការត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីបើកការស៊ើបសួរ។ ជនជាប់ចោទត្រូវតែនាំទៅបង្ហាញខ្លួននៅថ្ងៃនោះតែម្តងនៅចំពោះមុខចៅក្រមស៊ើបសួរ បើពុំដូច្នោះទេជនជាប់ចោទត្រូវតែដោះលែងឱ្យមានសេរីភាពវិញដោយឯកឯង។

# ជំពូកទី៤
# ដំណាក់កាលការស៊ើបសួរក្នុងរឿងក្តីព្រហ្មទណ្ឌ

## ផ្នែកទី១៖ ការចាប់ផ្តើមបើកការស៊ើបសួរ និងការបិទការស៊ើបសួរ

### ១. ការបើកការស៊ើបសួរ

ការស៊ើបសួរពុំមានលក្ខណៈចាប់បង្ខំដាច់ខាតក្នុងករណីបទមជ្ឈិមនោះទេ ពោលគឺអាចធ្វើការស៊ើបសួរក៏បាន ឬមិនធ្វើក៏បាន។ ប៉ុន្តែផ្ទុយទៅវិញ ការស៊ើបសួរត្រូវតែធ្វើឡើយដោយខានមិនបានចំពោះបទឧក្រិដ្ឋ[52]។

#### ១.១ បែបបទនៃការស៊ើបសួរ

##### ១.១.១ កិច្ចសម្ងាត់នៃការស៊ើបសួរ

ការស៊ើបសួរ ត្រូវតែជាការសម្ងាត់។ ចំពោះបុគ្គលទាំងឡាយដែលចូលរួមក្នុងការស៊ើបសួរជាពិសេសចៅក្រម មេធាវី ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ មន្ត្រីរាជការ អ្នកជំនាញ អ្នកបកប្រែ គ្រូពេទ្យ និងបុគ្គលដែលមានសមត្ថកិច្ចដូចមានចែងក្នុងមាត្រា ៩៥ (ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ) នៃក្រមនីតិវិធីព្រហ្មទណ្ឌសុទ្ធតែត្រូវរក្សាការសម្ងាត់នៃវិជ្ជាជីវៈ។

ប៉ុន្តែការគោរពនូវការសម្ងាត់វិជ្ជាជីវៈ មិនអាចជាឧបសគ្គដល់ការប្រើសិទ្ធិនៃការការពារខ្លួនឡើយ។ ករណីបើមានការបំពានលើការសម្ងាត់នៃការស៊ើបសួរ នោះនឹងត្រូវចាត់ទុកថាបានប្រព្រឹត្តបទល្មើសដែលត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន។

ម្យ៉ាងទៀត ព្រះរាជអាជ្ញាអាចធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈកាលណាខ្លួនយល់ឃើញថាព័ត៌មានដែលផ្សព្វផ្សាយពីរឿងណាមួយនោះជាព័ត៌មានមិនពិត[53]។

##### ១.១.២ វិសាលភាពនៃការស៊ើបសួរ

###### ក. សមត្ថកិច្ចតាមសាច់រឿង

ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌពុំទទួលស្គាល់ថា ចៅក្រមស៊ើបសួរទាំងឡាយអាចប្តឹងមកខ្លួនឯងហើយខ្លួនឯងផ្ទាល់ជាអ្នកស៊ើបសួរ ឬវិនិច្ឆ័យបទល្មើសព្រហ្មទណ្ឌឡើយ ទោះបីជាចៅក្រមស៊ើបសួរបានដឹងដោយខ្លួនឯងផ្ទាល់នូវបទល្មើសក៏ដោយ។ ដូច្នេះ ចៅក្រមស៊ើបសួរអាចស៊ើបសួរបាន លុះ-ត្រាតែត្រូវបានប្តឹងពីរឿងមួយដោយព្រះរាជអាជ្ញា ឬដោយជនរងគ្រោះ ដែលអាចបើកការស៊ើបសួរ

[52] មាត្រា ១២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[53] មាត្រា ១២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ដោយតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទៅចៅក្រមស៊ើបសួរ។ ប៉ុន្តែ ការស៊ើបសួរមិនមានលក្ខណៈចាំបាច់ចំពោះការវិនិច្ឆ័យបទល្មើសនោះទេ។

ថ្វីត្បិតតែចៅក្រមស៊ើបសួរមានសមត្ថកិច្ចចំពោះបទល្មើសទាំងបីប្រភេទក្តី តែសមត្ថកិច្ចដាច់ខាតដែលមិនអាចខានបានក្នុងការអន្តរាគមន៍នោះ គឺមានតែចំពោះបទឧក្រិដ្ឋតែប៉ុណ្ណោះ។ ចំពោះបទមជ្ឈិម និងបទលហុ ការអន្តរាគមន៍របស់ចៅក្រមស៊ើបសួរអាចធ្វើ ឬមិនធ្វើក៏បាន។

**ខ. សមត្ថកិច្ចតាមដែនដី**

ចៅក្រមដែលមានសមត្ថកិច្ចតាមដែនដីគឺៈ

- ចៅក្រមស៊ើបសួរនាទីកន្លែងបទល្មើស
- ចៅក្រមស៊ើបសួរនាទីលំនៅឋាន ឬទីសំណាក់របស់បុគ្គលដែលបានសង្ស័យថាមានប្រព្រឹត្តបទល្មើស
- ចៅក្រមស៊ើបសួរនាទីកន្លែងចាប់ខ្លួនបុគ្គលដែលសង្ស័យថា បានប្រព្រឹត្តបទល្មើស។

ក្នុងករណីដែលមានទំនាស់រវាងចៅក្រមស៊ើបសួរច្រើនរូបនៅសាលាដំបូងខុសៗគ្នា ហើយទទួលបណ្តឹងទាំងអស់គ្នាអំពីរឿងព្រហ្មទណ្ឌតែមួយដូចគ្នា ទំនាស់នេះត្រូវបញ្ជូនទៅប្រធានសភាស៊ើបសួរដើម្បីសម្រេច។ ប៉ុន្តែ បើករណីវិវាទសមត្ថកិច្ចដែនដីរវាងសភាស៊ើបសួរច្រើនត្រូវសម្រេចដោយប្រធានតុលាការកំពូល ហើយការសម្រេចនេះបិទផ្លូវតវ៉ា[54]។

ចៅក្រមស៊ើបសួរស្ថិតនៅសាលាដំបូង ដូចនេះគាត់មានសមត្ថកិច្ចក្នុងដែនសមត្ថកិច្ចរបស់តុលាការ ដោយគាត់មានសមត្ថកិច្ចចំពោះគ្រប់បទល្មើសទាំងអស់ដែលបានកើតឡើងនៅក្នុងដែនសមត្ថកិច្ចនោះ។ ចៅក្រមស៊ើបសួរអាចចុះដល់ទីកន្លែងជាមួយក្រឡាបញ្ជីរបស់ខ្លួននៅលើវិសាលភាពនៃសមត្ថកិច្ចដែនដីនៃសាលាដំបូង ដើម្បីបំពេញកិច្ចស៊ើបសួរដែលខ្លួនយល់ថាមានប្រយោជន៍ជាអាទិ៍ ការពិនិត្យសម្ភារៈ ការឆែកឆេរ និងការចាប់យកវត្ថុតាង។ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងទៅព្រះរាជអាជ្ញាអំពីការចុះទៅពិនិត្យនេះ ហើយព្រះរាជអាជ្ញាក៏អាចរួមដំណើរជាមួយផងដែរ[55]។

ម្យ៉ាងវិញទៀត បើករណីការស៊ើបសួរតម្រូវចាំបាច់ ចៅក្រមអាចចុះទៅកាន់ទីកន្លែងជាមួយក្រឡាបញ្ជីនៅលើវិសាលភាពដែនដីជាតិទាំងមូលដើម្បីបំពេញកិច្ចចាំបាច់នានារបស់ខ្លួន។ ករណី

---

[54] មាត្រា ១២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[55] មាត្រា ១៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

នេះចៅក្រមត្រូវជូនដំណឹងជាមុនដល់ព្រះរាជអាជ្ញាអមសាលាដំបូងរបស់ខ្លួន និងព្រះរាជអាជ្ញាអម-សាលាដំបូងនៅក្នុងដែនដីដែលខ្លួនធ្វើដំណើរទៅកាន់នោះ។

ដោយហេតុនៅក្នុងសាលាដំបូងមានចៅក្រមស៊ើបសួរច្រើន ដូច្នេះការបែងចែករឿងក្តីត្រូវធ្វើឡើងដោយប្រធានតុលាការ[56]។ កាលបើចៅក្រមស៊ើបសួរណាម្នាក់ ពុំអាចបំពេញមុខងាររបស់ខ្លួនបានទេ ដោយសារការឈប់សម្រាក ឬមានជម្ងឺ ឬមូលហេតុផ្សេងទៀត ចៅក្រមស៊ើបសួរផ្សេងទៀតនៃតុលាការត្រូវបានចាត់តាំងជាបណ្តោះអាសន្ន ដោយប្រធានតុលាការដើម្បីបំពេញមុខងារស៊ើបសួរ ហើយប្រធានតុលាការនឹងចេញដីកាចាត់តាំងមួយដែលបិទផ្លូវតវ៉ា[57]។

### ១.២ មូលហេតុនៃការបើកការស៊ើបសួរ

តាមស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌ ការបើកការស៊ើបសួរត្រូវបានបើកតាមរយៈមធ្យោបាយពីរយ៉ាងគឺការបើកការស៊ើបសួរដោយអយ្យការ (តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ) និងការបើកការស៊ើបសួរដោយភាគីជនរងគ្រោះ (តាមរយៈទទួលពាក្យបណ្តឹងពីជនរងគ្រោះដោយការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី)។

#### ១.២.១ ការបញ្ជូនរឿងឱ្យស៊ើបសួររបស់អយ្យការ

ការស៊ើបសួរ ត្រូវបានបើកដោយដីកាបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា[58]។ នៅក្នុងន័យខាងលើបានបង្ហាញពីការស៊ើបសួរ ត្រូវបានបើកតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដែលត្រូវប្តឹងទៅចៅក្រមស៊ើបសួរ។ ការស៊ើបសួរអាចបើកប្រឆាំងទៅលើបុគ្គលម្នាក់ ឬច្រើននាក់ដោយមានចង្អុលបង្ហាញប្រាប់ឈ្មោះ (ជនដែលគេស្គាល់ឈ្មោះ) ឬប្រឆាំងទៅលើអញ្ញាតជន (ជនដែលគេមិនស្គាល់អត្តសញ្ញាណ) វាគឺជាវិធានដែលត្រូវតែគោរពបើពុំដូចនោះទេនឹងមានមោឃភាពនៃនីតិវិធី។ ដូច្នេះដីកាសន្និដ្ឋាននេះ គឺជាលិខិតដែលបើកឱ្យមានបណ្តឹងអាជ្ញាដែលព្រះរាជអាជ្ញាប្តឹងទៅចៅក្រមស៊ើបសួរឱ្យគាត់ស៊ើបសួររឿងរ៉ាវមួយជាកំណត់ ដែលយល់ថាអាចត្រូវបានផ្តន្ទាទោសព្រហ្មទណ្ឌ។

នៅក្នុងវិសាលភាពនៃការប្តឹងនេះដែរ ចៅក្រមស៊ើបសួរទទួលបណ្តឹងអំពីអង្គហេតុដែលមាន

[56] មាត្រា ៥២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[57] មាត្រា ៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[58] មាត្រា ១២៤ កថាខណ្ឌ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដោយព្រះរាជអាជ្ញា[59]។ មានន័យថា ចៅក្រមស៊ើបសួរមានសមត្ថកិច្ចធ្វើការស៊ើបសួរតែចំពោះអង្គហេតុ ដែលមាននៅក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរនោះតែប៉ុណ្ណោះ។ ករណីដែលចៅក្រមស៊ើបសួរធ្វើការស៊ើបសួរ ហើយមានលេចនូវអង្គហេតុថ្មីដែលជាធាតុផ្សំសំខាន់នៅក្នុងរឿងក្ដីព្រហ្មទណ្ឌ ឬជាបទល្មើសព្រហ្មទណ្ឌនោះ ករណីនេះចៅក្រមស៊ើបសួរត្រូវជូននូវព័ត៌មានពីអង្គហេតុនេះទៅព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាអាចធ្វើការស៊ើបសួរអំពីអង្គហេតុថ្មីនោះតាមរយៈដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទៅចៅក្រមស៊ើបសួរ។ នៅក្នុងករណីនេះចៅក្រមមិនអាចធ្វើការស៊ើបសួរលើអង្គហេតុថ្មីនោះ ដោយគ្មានដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់ព្រះរាជអាជ្ញាបានឡើយ។

ប៉ុន្តែចៅក្រមស៊ើបសួរ ពុំចាំបាច់ធ្វើការស្នើសុំដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពីព្រះរាជអាជ្ញាទេប្រសិនបើអង្គហេតុថ្មីនោះជាស្ថានទម្ងន់ទៅលើអង្គហេតុ ដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដំបូងដែលចៅក្រមស៊ើបសួរកំពុងធ្វើការស៊ើបសួរនោះ។

### ១.២.២ ការទទួលពាក្យបណ្ដឹងពីជនរងគ្រោះ

នេះគឺជាជម្រើសទីពីរដែលអាចបើកស៊ើបសួរបាន ដោយយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌបានផ្ដល់សិទ្ធិឱ្យជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម អាចដាក់ពាក្យប្ដឹងជូនចៅក្រមស៊ើបសួរមានសមត្ថកិច្ចដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី[60]។ ករណីដែលជនរងគ្រោះមិនសរសេរនូវពាក្យប្ដឹងបានដោយខ្លួនឯងនោះ មេធាវីដែលបានតំណាងឱ្យជនរងគ្រោះមានសិទ្ធិដាក់នូវពាក្យបណ្ដឹងនៅក្នុងនាមជនរងគ្រោះបាន។

ចំពោះចំណាត់ការនៅលើពាក្យបណ្ដឹង កាលណាបានទទួលនូវពាក្យបណ្ដឹងដែលប្ដឹងដោយតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនោះ ចៅក្រមស៊ើបសួរនឹងត្រូវធ្វើការកត់សម្គាល់នូវការដាក់ពាក្យបណ្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីតាមដីកា។ បន្ទាប់ពីពិនិត្យថាមានលក្ខណៈត្រឹមត្រូវហើយ ចៅក្រមស៊ើបសួរនឹងធ្វើការបញ្ជូនពាក្យបណ្ដឹងនោះទៅព្រះរាជអាជ្ញាដើម្បីពិនិត្យ។ បន្ទាប់ពីព្រះរាជអាជ្ញាបានពិនិត្យនូវពាក្យបណ្ដឹងរួចរាល់ហើយនោះ ព្រះរាជអាជ្ញាត្រូវប្ដឹងទៅចៅក្រមស៊ើបសួរឱ្យបើកការស៊ើបសួរ តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ នៅក្នុងការចេញដីកា

---

[59] មាត្រា ១២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[60] មាត្រា ១៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

សន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះ អាចធ្វើប្រឆាំងនឹងអញ្ញាតជនទោះបីបណ្តឹងដោយតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចោទទៅលើបុគ្គលម្នាក់ ឬច្រើននាក់ក៏ដោយ។ ករណីពាក្យបណ្តឹងដែលប្តឹងទៅក្នុងនាមដើមបណ្តឹងរដ្ឋប្បវេណី នៅពេលដែលព្រះរាជអាជ្ញាធ្វើការពិនិត្យហើយឃើញថាបណ្តឹងអាជ្ញាត្រូវបានរលត់ហើយ ឬពាក្យបណ្តឹងនោះមិនមានធាតុផ្សំបទល្មើសគ្រប់គ្រាន់ដែលជាធាតុផ្សំសំខាន់សម្រាប់ធ្វើការចោទប្រកាន់ទេនោះ ព្រះរាជអាជ្ញាមានសិទ្ធិស្នើសុំឱ្យចៅក្រមស៊ើបសួរមិនឱ្យស៊ើបសួរបាន។ ករណីនេះ ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថាសម្រេចមិនធ្វើការស៊ើបសួរទេ ចៅក្រមស៊ើបសួរត្រូវចេញនូវដីកាសម្រេចដែលមានសំអាងហេតុ ហើយត្រូវជូនដំណឹងជាបន្ទាន់ទៅដើមបណ្តឹងរដ្ឋប្បវេណី។ ប៉ុន្តែនៅក្នុងករណីដែលចៅក្រមស៊ើបសួរនៅតែសម្រេចធ្វើការស៊ើបសួរដដែលនោះ ចៅក្រមស៊ើបសួររូបនេះត្រូវចេញដីកាសម្រេចដែលមានសំអាងហេតុ ហើយត្រូវជូនដំណឹងជាបន្ទាន់ទៅព្រះរាជអាជ្ញាឱ្យបានជ្រាបពីករណីនេះ[61]។

ទន្ទឹមនឹងការបើកការស៊ើបសួរដោយតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះដែលជាម្ចាស់បណ្តឹងនឹងត្រូវបង់ប្រាក់តម្កល់ទុកដោយផ្អែកទៅលើធនធានរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងទៅលើការលំបាកនៃរឿងដែលអាចមើលឃើញជាមុន ចៅក្រមស៊ើបសួរកំណត់តាមដីកាសម្រេចនូវចំនួនទឹកប្រាក់ដែលដើមបណ្តឹងរដ្ឋប្បវេណីត្រូវបង់ ព្រមទាំងរយៈពេលដែលត្រូវបង់ប្រាក់នេះផង។

ករណីដែលដើមបណ្តឹងបណ្តឹងរដ្ឋប្បវេណី ពុំមានលទ្ធភាពអាចបង់ប្រាក់តម្កល់ទុកបានទេ ចៅក្រមស៊ើបសួរអាចលើកលែងមិនឱ្យដើមបណ្តឹងរដ្ឋប្បវេណីមិនឱ្យបង់នូវប្រាក់តម្កល់នេះបាន[62]។ ដីកាសម្រេចនេះត្រូវជូនដំណឹងជាបន្ទាន់ដល់ដើមបណ្តឹងរដ្ឋប្បវេណី។ ម្យ៉ាងទៀត ក្នុងករណីដែលដើមបណ្តឹងរដ្ឋប្បវេណីមាននូវលទ្ធភាពបង់នូវប្រាក់តម្កល់នោះ នៅពេលដែលបានបង់ប្រាក់តម្កល់រួចហើយ ដើមបណ្តឹងរដ្ឋប្បវេណីនឹងទទួលបាននូវបង្កាន់ដៃដែលមានចុះហត្ថលេខាដោយប្រធានតុលាការ ព្រះរាជអាជ្ញា និងក្រឡាបញ្ជី។ ផ្ទុយទៅវិញ បើប្រាក់តម្កល់ដែលដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានបង់នៅក្នុងរយៈពេលដែលបានកំណត់ដោយចៅក្រមស៊ើបសួរទេ ពាក្យបណ្តឹងដែលប្តឹងដោយតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវប្រកាសថាមិនអាចទទួលបានដោយចៅក្រមស៊ើបសួរ ហើយចៅក្រមស៊ើបសួរនឹងត្រូវធ្វើការសម្រេចតាមដីកាដែលត្រូវបញ្ជូនដំណឹងនេះជាបន្ទាន់ទៅដល់

[61] មាត្រា ១៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[62] មាត្រា ១៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ដើមបណ្តឹងរដ្ឋប្បវេណី។

ក្រោយនីតិវិធីត្រូវបានបញ្ចប់ ប្រាក់តម្កល់នឹងត្រូវបង្វិលទៅឱ្យសាមីខ្លួន លើកលែងតែមានការប្តឹងដោយការបំពាន ឬបណ្តឹងដោយអូសបន្លាយនូវពេលវេលាដែលធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីនោះ។ ក្នុងករណីដែលការស៊ើបសួរត្រូវបានបើកបន្ទាប់ពីមានពាក្យប្តឹង ដោយសារមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នឹងត្រូវបានបិទតាមរយៈដីកាលើកលែងចោទប្រកាន់ ហើយប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថានីតិវិធីបានធ្វើឡើងដោយរំលោភ ឬដោយអូសបន្លាយនូវពេលវេលានោះ ចៅក្រមស៊ើបសួរអាចចេញដីកាសម្រេចឱ្យដើមបណ្តឹងរដ្ឋប្បវេណីបង់ប្រាក់ពិន័យរដ្ឋប្បវេណីបាន តែចំនួនប្រាក់ដែលត្រូវពិន័យមិនអាចមានចំនួនលើសចំនួនប្រាក់ដែលដើមបណ្តឹងរដ្ឋប្បវេណីបានដាក់តម្កល់នោះបានឡើយ។ ចំពោះករណីនេះ ដីកាសម្រេចដែលឱ្យបង់នូវប្រាក់ពិន័យនោះ ត្រូវជូនដំណឹងជាបន្ទាន់ដល់ដើមបណ្តឹងរដ្ឋប្បវេណីដែលជាម្ចាស់បណ្តឹង។

ទន្ទឹមនឹងច្បាប់បានចែងពីសិទ្ធិរបស់ជនរងគ្រោះ ដែលអាចបើកការស៊ើបសួរដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះ បុគ្គលដែលមានឈ្មោះនៅក្នុងពាក្យប្តឹង(បុគ្គលដែលគេប្តឹង) អាចមានសិទ្ធិប្តឹងសុំជួសជុលនូវការខូចខាតពីអ្នកដែលបានប្តឹងពីខ្លួនវិញបាន នៅក្នុងករណីដែលដីកាសម្រេចលើកលែងនូវការចោទប្រកាន់របស់ចៅក្រមស៊ើបសួរបានចូលជាស្ថាពរនោះដោយការចេញនូវដីកាសម្រេចនេះ មានមូលហេតុដោយសំអាងលើនីតិវិធីធ្វើឡើងដោយការរំលោភ ឬអូសបន្លាយពេលវេលា។ ចំពោះនីតិវិធីនៃការដាក់ពាក្យបណ្តឹងវិញ បុគ្គលនោះអាចយកពាក្យបណ្តឹងទៅដាក់ជូនទៅតុលាការជាន់ដំបូងដែលបានបើកការស៊ើបសួរនូវពាក្យបណ្តឹងដែលបានប្តឹងខ្លួននោះ។

## ២. ការបិទការស៊ើបសួរ

### ២.១ ការជូនដំណឹងដល់គូភាគី

កាលណាចៅក្រមស៊ើបសួរយល់ឃើញថា ការស៊ើបសួរបានបញ្ចប់ ចៅក្រមស៊ើបសួរជូនព័ត៌មាននេះដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវី[63]។

២ (ពីរ) ថ្ងៃក្រោយមក ចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿងឲ្យព្រះរាជអាជ្ញាពិនិត្យ។ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថាចាំបាច់ត្រូវធ្វើកិច្ចស៊ើបសួរថ្មីទៀតនោះ ព្រះរាជអាជ្ញាក៏អាចធ្វើការស្នើសុំ

[63] មាត្រា ២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ឱ្យចៅក្រមស៊ើបសួរបំពេញកិច្ច ស៊ើបសួរដែលខ្លួនយល់ឃើញថាមានប្រយោជន៍[64]។ ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាទេនោះ ចៅក្រមរូបនោះត្រូវតែចេញដីកាបដិសេធនៅក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ។ ដីកានេះត្រូវមានសំអាងហេតុ និងត្រូវតែជូនដំណឹងដល់ព្រះរាជអាជ្ញាក្នុងចិរវេលាយ៉ាងឆាប់បំផុត។ ករណីបើសិនចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃទេ ព្រះរាជអាជ្ញាអាចប្តឹងដោយផ្ទាល់តាមរយៈពាក្យសុំទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។

ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ប្រសិនបើជនត្រូវចោទត្រូវឃុំខ្លួន ១ (មួយ) ខែ ក្នុងករណីដែលជនត្រូវចោទនៅក្រៅឃុំ ព្រះរាជអាជ្ញាបង្វិលនូវសំណុំរឿងទៅចៅក្រមស៊ើបសួរវិញដោយមានដីកាសន្និដ្ឋានស្ថាពរភ្ជាប់ជាមួយផង។ ចិរវេលានេះត្រូវគិតពីថ្ងៃដែលព្រះរាជអាជ្ញាបានទទួលសំណុំរឿងពីចៅក្រមស៊ើបសួរ ប៉ុន្តែក្រមនិតីវិធីព្រហ្មទណ្ឌពុំមានចែងពីទោសបញ្ញត្តិក្នុងករណីបើមិនគោរពចិរវេលានេះឡើយ។

កម្មវត្ថុនៃចិរវេលា ២ (ពីរ) ថ្ងៃ ដែលបែងចែកការប្រកាសបិទការស៊ើបសួរដល់ភាគី និងការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ពុំឃើញមានការបញ្ជាក់ឱ្យច្បាស់លាស់នៅក្នុងក្រមនិតិវិធីព្រហ្មទណ្ឌនោះទេ។ ប៉ុន្តែ វាហាក់បីដូចជាមានបំណងទុកពេលឱ្យភាគីធ្វើពាក្យសុំឱ្យធ្វើកិច្ចស៊ើបសួរទៅចៅក្រមស៊ើបសួរ។ ដូចដែលបានបង្ហាញរួចមកហើយ លទ្ធភាពនេះត្រូវបានផ្តល់ឱ្យព្រះរាជអាជ្ញាបន្ទាប់ពីផុតចិរវេលា។ ករណីនេះមានសំណួរមួយអាចចោទសួរឡើងបានថា តើការប្រកាសបិទការស៊ើបសួររបស់ចៅក្រមស៊ើបសួរនឹងទៅជាយ៉ាងណា បើសិនមានភាគីណាមួយដាក់ពាក្យសុំធ្វើកិច្ចស៊ើបសួរមុនពេលបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ? យើងឃើញថា បើចៅក្រមស៊ើបសួរយល់ស្របនឹងពាក្យសុំ ហើយធ្វើឡើងនូវកិច្ចស៊ើបសួរដូចការសុំរបស់គូភាគី នោះនឹងនាំឱ្យការប្រកាសរបស់ចៅក្រមស៊ើបសួរនឹងក្លាយជាមោឃៈ។

បន្ទាប់ពីបំពេញកិច្ចស៊ើបសួរដែលសុំដោយគូភាគី ចៅក្រមស៊ើបសួរត្រូវធ្វើការជូនដំណឹងសារជាថ្មីនៅពេលខ្លួនយល់ឃើញថាការស៊ើបសួរត្រូវបានបញ្ចប់។ ការជូនដំណឹងនេះធ្វើឱ្យចិរវេលា ២ (ពីរ) ថ្ងៃ មុខការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញានឹងត្រូវចាប់ផ្តើមសារឡើងវិញជាថ្មីម្តងទៀត។

[64] មាត្រា ១៣២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ករណីមួយផ្សេងទៀតដោយយើងអាចចោទជាសំណួរថា ប្រសិនបើចៅក្រមស៊ើបសួរបានបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា តើគូភាគីអាចសុំឱ្យចៅក្រមស៊ើបសួរបំពេញកិច្ចស៊ើបសួរបានឬទេ ? ដោយយោងតាមមាត្រា ២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងច្បាស់ពីចំណុចនេះ គឺមានតែព្រះរាជអាជ្ញាតែប៉ុណ្ណោះ ដែលមានសិទ្ធិស្នើសុំឱ្យចៅក្រមស៊ើបសួរបំពេញកិច្ចស៊ើបសួរនៅក្រោយពេលដែលចៅក្រមស៊ើបសួរបានបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ដូច្នេះករណីនេះគូភាគីមិនអាចស្នើសុំឱ្យចៅក្រមស៊ើបសួរធ្វើកិច្ចស៊ើបសួរបានឡើយ។

ស្របគ្នានេះដែរបន្ទាប់ពីទទួលសំណុំរឿង ប្រសិនព្រះរាជអាជ្ញាសុំឱ្យមានកិច្ចស៊ើបសួរ និងត្រូវបានយល់ព្រមដោយចៅក្រមស៊ើបសួរ ឯចៅក្រមស៊ើបសួរត្រូវធ្វើការជូនដំណឹងពីការបញ្ចប់ការស៊ើបសួរជាថ្មីម្តងទៀតនៅពេលដែលកិច្ចស៊ើបសួរនោះត្រូវបានចប់សព្វគ្រប់ និងបានចុះលេខក្នុងសំណុំរឿង។ ទោះជាយ៉ាងណា ការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាមិនដកសមត្ថកិច្ចពីចៅក្រមស៊ើបសួរទេ ព្រោះគាត់នៅតែអាចបន្តការស៊ើបសួររហូតដល់ថ្ងៃចេញដីកាដំណោះស្រាយលើពាក្យសុំឱ្យដោះលែងជនត្រូវចោទដែលជាប់ឃុំជាដើម។

ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញដូចចៅក្រមស៊ើបសួរដែរថា ការស៊ើបសួរត្រូវបញ្ចប់នោះព្រះរាជអាជ្ញាធ្វើដីកាសន្និដ្ឋានស្ថាពរជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ។ ព្រះរាជអាជ្ញាអាចប្តឹងសុំឱ្យចៅក្រមស៊ើបសួរសម្រេចបញ្ជូនខ្លួនជនត្រូវចោទទៅកាន់តុលាការជំនុំជម្រះ ឬក៏លើកលែងការចោទប្រកាន់។ ទោះជាយ៉ាងណា សេចក្តីសន្និដ្ឋានស្ថាពរនេះមិនមានអានុភាពចងចៅក្រមស៊ើបសួរទេ ព្រោះគាត់ត្រូវធ្វើសេចក្តីសម្រេចតែម្នាក់ឯងតាមរយៈដីកាដំណោះស្រាយ។

### ២.២ ការចេញដីកាដំណោះស្រាយ

ចៅក្រមស៊ើបសួរបិទការស៊ើបសួរតាមរយៈដីកាដំណោះស្រាយ ដែលត្រូវជូនដំណឹងអំឡុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវី ។ ដីកានេះអាចជាដីកាបញ្ជូនទៅជំនុំជម្រះ ឬក៏លើកលែងការចោទប្រកាន់។

#### ២.២.១ ដីកាលើកលែងការចោទប្រកាន់

ចៅក្រមស៊ើបសួរអាចធ្វើការសម្រេចថាមិនប្តឹង និងមិនបញ្ជូនជនត្រូវចោទឱ្យទៅចំពោះមុខសាលាវិនិច្ឆ័យនៅក្នុងករណីដូចខាងក្រោម៖

- អំពើប្រព្រឹត្តមិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ

- ជនដែលប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់
- គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ[65]។

ការលើកលែងចោទប្រកាន់របស់ចៅក្រមស៊ើបសួរអាចត្រូវបានលើកលែងចោទប្រកាន់ទាំងស្រុង ឬដោយផ្នែក។ ម្យ៉ាងទៀត ដីកាលើកលែងចោទប្រកាន់ជាដីកាដកសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរពីសំណុំរឿង បញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការ និងការឃុំខ្លួនបណ្ដោះអាសន្ន។

ដើមបណ្ដឹងរដ្ឋប្បវេណី អាចធ្វើបណ្ដឹងឧទ្ធរណ៍ពីដីកាលើកលែងចោទប្រកាន់[66]។ ចំណែកព្រះរាជអាជ្ញាក៏ដូចជាអគ្គព្រះរាជអាជ្ញាដែរ គឺមានអំណាចក្នុងការធ្វើបណ្ដឹងឧទ្ធរណ៍ពីគ្រប់ដីការបស់ចៅក្រមស៊ើបសួរ[67]។ ប្រសិនបើព្រះរាជអាជ្ញាប្ដឹងឧទ្ធរណ៍ពីដីកាលើកលែងចោទប្រកាន់ ជនត្រូវចោទដែលបានជាប់ឃុំ នឹងត្រូវរក្សាទុកនៅក្នុងពន្ធនាគារបន្តរហូតដល់ពេលដែលសភាស៊ើបសួរសម្រេចពីបណ្ដឹងឧទ្ធរណ៍នេះ។ ប្រសិនបើសភាស៊ើបសួរយល់ស្របនឹងដីកា ជនត្រូវចោទនឹងត្រូវដោះលែងឱ្យមានសេរីភាព។ ផ្ទុយទៅវិញ បើសភាស៊ើបសួរចេញដីកាបញ្ជូនទៅជំនុំជម្រះ សភាស៊ើបសួរត្រូវសម្រេចអំពីការរក្សាទុកក្នុងឃុំ។ ប៉ុន្តែ បើសភាស៊ើបសួរទទួលបន្ទុកការស៊ើបសួរ និងដឹកនាំនីតិវិធីដោយខ្លួនឯងផ្ទាល់ នោះដីកាលើកលែងចោទប្រកាន់ដែលចេញដោយសភាស៊ើបសួរនឹងមានអានុភាពដោះលែងជនត្រូវចោទដែលជាប់ឃុំភ្លាម[68]។

ចំពោះសេចក្ដីសម្រេចលើកលែងចោទប្រកាន់ មិនមានអានុភាពរំលត់បណ្ដឹងអាជ្ញានោះទេ ព្រោះថាប្រសិនការលើកលែងចោទប្រកាន់មានហេតុផលមកពី អវត្តមាននៃបន្ទុកគ្រប់គ្រាន់ប្រឆាំងនឹងជនត្រូវចោទ ឬមកពីការពុំស្គាល់ចារីនោះ កាលណាមានលេចចេញនូវបន្ទុកថ្មីអនុញ្ញាតឱ្យបើកការស៊ើបសួរទៅលើអង្គហេតុតែមួយជាថ្មីម្ដងទៀតបាន តាមការផ្ដើមគំនិតរបស់ព្រះរាជអាជ្ញា[69]។

### ២.២.២ ដីកាបញ្ជូនខ្លួនជនត្រូវចោទទៅជំនុំជម្រះ

ដីកាបញ្ជូនខ្លួនជនត្រូវចោទទៅជំនុំជម្រះនឹងត្រូវបានចេញដោយចៅក្រមស៊ើបសួរក្នុងករណីចៅក្រមស៊ើបសួរយល់ឃើញថាអំពើនោះជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ចៅក្រមស៊ើបសួរនឹង

[65] មាត្រា ២៤៧ កថាខណ្ឌ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[66] មាត្រា ២៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[67] មាត្រា ២៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[68] មាត្រា ២៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[69] មាត្រា ២៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

សម្រេចបញ្ជូនជនត្រូវចោទទៅមុខតុលាការជំនុំជម្រះ។ ដីកាសម្រេចនេះត្រូវមានរៀបរាប់អំពើដែលត្រូវបានចោទប្រកាន់ ព្រមទាំងឈ្មោះបទល្មើសតាមច្បាប់ដែលបានកំណត់[70]។

ប្រសិនបើ ចៅក្រមស៊ើបសួរបានសម្រេចចេញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ចៅក្រមស៊ើបសួរត្រូវតែបញ្ជូនសំណុំរឿងជាបន្ទាន់ទៅប្រធានតុលាការ ដើម្បីកំណត់ពេលសវនាការជំនុំជម្រះ[71]។

ដីកាបញ្ជូនសំណុំរឿងមិនខុសពីដីកាលើកលែងចោទប្រកាន់ទេ ដោយដីកានេះជាដីកាដកសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរពីសំណុំរឿង បញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការ និងការឃុំខ្លួនជាបណ្ដោះអាសន្ន។ ទោះជាយ៉ាងណា តាមសេចក្ដីសម្រេចដោយឡែកនៃដីកាដំណោះស្រាយ និងក្រោមលក្ខខណ្ឌមួយចំនួន ចៅក្រមស៊ើបសួរអាចសម្រេចរក្សាជនត្រូវចោទឱ្យនៅជាប់ឃុំបណ្ដោះ-អាសន្នរហូតដល់ពេលចូលបង្ហាញខ្លួននៅមុខតុលាការ ឬរក្សាទុកជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ រហូតដល់ពេលចូលបង្ហាញខ្លួននៅចំពោះមុខតុលាការបាន។ សេចក្ដីសម្រេចរក្សាទុកជនត្រូវចោទក្នុងឃុំជាបណ្ដោះអាសន្នលែងមានអានុភាពក្នុងរយៈពេល ៤ (បួន) ខែ ប្រសិនបើជនត្រូវចោទមិនបានចូលទៅបង្ហាញខ្លួននៅមុខតុលាការក្នុងរយៈពេល ៤(បួន) ខែនោះទេ ជនត្រូវចោទត្រូវបានដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្នដោយឯកឯង ពោលគឺពុំចាំបាច់មានការស្នើសុំឡើយ[72]។

នៅក្នុងដីកាដំណោះស្រាយជានិច្ចកាលត្រូវតែមានសំអាងហេតុ។ ចៅក្រមស៊ើបសួរមិនត្រូវជាប់កាតព្វកិច្ចត្រូវគោរពតាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាទេ មានន័យថាអំណាចនៃដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា មិនមានសិទ្ធិចាប់បង្ខំឱ្យចៅក្រមស៊ើបសួរត្រូវតែធ្វើតាមនោះទេ។ ម្យ៉ាងទៀត ក្នុងដីកាដំណោះស្រាយចៅក្រមស៊ើបសួរសម្រេចអំពីការប្រគល់សងទៅឱ្យម្ចាស់ដើមវិញនូវវត្ថុដែលបានចាប់យក។ ករណីនេះ ព្រះរាជអាជ្ញាមានសមត្ថកិច្ចបង្គាប់ឱ្យប្រគល់វត្ថុដែលចាប់បាននៅក្នុងពេលស៊ើបអង្កេតទៅម្ចាស់ដើមវិញ ប្រសិនបើវត្ថុទាំងនោះពុំមានប្រយោជន៍សម្រាប់ការសំដែងការពិតទេនោះ ហើយប្រសិនបើកម្មសិទ្ធិលើវត្ថុនោះគ្មានការជំទាស់អ្វីពិតប្រាកដប្រជាទេ។

[70] មាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[71] មាត្រា ២៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[72] មាត្រា ២៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ផ្ទុយទៅវិញ ចំពោះវត្ថុដែលមានគ្រោះថ្នាក់ចំពោះមនុស្ស ឬចំពោះទ្រព្យសម្បត្តិ ដូចជាអាវុធ ឬជាតិផ្ទុះ ព្រមទាំងវត្ថុដែលត្រូវបានកាន់កាប់ដោយខុសច្បាប់មិនអាចប្រគល់ឱ្យវិញបានទេ។ វត្ថុទាំងនោះត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ ឬត្រូវបំផ្លាញចោល។ ក្នុងករណីមិនព្រមប្រគល់សងវិញទេ អ្នកប្តឹងមានសិទ្ធិតវ៉ាទៅអគ្គព្រះរាជអាជ្ញាបាន។ ព្រះរាជអាជ្ញា ឬអគ្គព្រះរាជអាជ្ញា គ្មានសមត្ថកិច្ចក្នុងការប្រគល់ទេកាលណាមានការចោទប្រកាន់ធ្វើឡើងនៅចំពោះមុខយុត្តាធិការស៊ើបសួរ ឬយុត្តាធិការជំនុំជម្រះ ប៉ុន្តែព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញានៅតែមានសមត្ថកិច្ច កាលណាការស៊ើបសួរត្រូវបានបញ្ចប់ដោយសេចក្តីសម្រេចលើកលែងចោទប្រកាន់ជាស្ថាពរ[73]។

## ផ្នែកទី២៖ ដំណើរការនៃការស៊ើបសួរ

### ១. អំណាចបង្ខំរបស់ចៅក្រម

#### ១.១ អំណាចក្នុងការចេញដីកា

នៅក្នុងការបំពេញនូវកិច្ចស៊ើបសួររបស់ខ្លួន ដើម្បីស្វែងរកឱ្យឃើញនូវការពិតនោះ ចៅក្រមស៊ើបសួរមានសិទ្ធិធ្វើការកោះអញ្ជើញនូវបុគ្គលណាមួយ ដែលមិនព្រមឆ្លើយតបតាមការកោះរបស់ខ្លួនដោយប្រើប្រាស់សិទ្ធិក្នុងការចេញនូវដីកាដែលជាវិធានការនិរន្តរាយមួយចំនួនដូចខាងក្រោម៖

##### ១.១.១ ដីកាបង្គាប់ឱ្យចូលខ្លួន

ដីកាបង្គាប់ឱ្យចូលខ្លួន គឺជាបញ្ជាដល់បុគ្គលណាម្នាក់ឱ្យចូលទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ។ មិនតែប៉ុណ្ណោះ ចៅក្រមស៊ើបសួរក៏អាចចេញដីកានេះទៅលើជនត្រូវចោទ ឬទៅលើបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព[74]។

ដីកាបង្គាប់ឱ្យចូលខ្លួននេះមាននិទ្ទេសដូចតទៅ[75]៖

- អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ
- បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ
- ថ្ងៃ ខែ ឆ្នាំ ម៉ោង និងទីកន្លែងដែលត្រូវចូលបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា

[73] មាត្រា ១១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[74] មាត្រា ១៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[75] មាត្រា ១៨៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

មិនតែប៉ុណ្ណោះ ដីកាបង្គាប់ឱ្យចូលខ្លួនត្រូវមានចុះនូវកាលបរិច្ឆេទ និងចុះហត្ថលេខាដោយថៅក្រមស៊ើបសួរ ព្រមទាំងមានបោះត្រាផង។

បន្ទាប់ពីថៅក្រមស៊ើបសួរបានចេញនូវដីកាបង្គាប់ឱ្យចូលខ្លួន ត្រូវឱ្យដំណឹងដល់បុគ្គលដែលពាក់ព័ន្ធ ដោយមន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬអាជ្ញាសាលា។ នៅពេលដែលបុគ្គលដែលពាក់ព័ន្ធទទួលនូវចុងដីកា ហើយត្រូវចុះហត្ថលេខានៅលើដើមដីកា ហើយត្រូវបង្វិលជូនថៅក្រមស៊ើបសួរវិញ។ ករណីដែលអនុវត្តនូវបេសកកម្មនេះ ប្រសិនបើជួបប្រទះនូវការលំបាកនោះ មន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬអាជ្ញាសាលាត្រូវរាយការណ៍ពីបញ្ហាលំបាកទាំងនេះជូនទៅថៅក្រមស៊ើបសួរ[76]។

**១.១.២ ដីកាបង្គាប់ឱ្យនាំខ្លួន**

ដីកាបង្គាប់ឱ្យនាំខ្លួន គឺជាបញ្ជាដល់កងកម្លាំងសាធារណៈឱ្យចាប់ និងនាំខ្លួនបុគ្គលណាម្នាក់ទៅចំពោះមុខថៅក្រមស៊ើបសួរ។ ដីកានេះអាចត្រូវចេញទៅលើជនត្រូវចោទ ឬទៅលើបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព[77]។

ដីកាបង្គាប់ឱ្យនាំខ្លួននេះមាននិទ្ទេសដូចតទៅ[78]៖

- អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ
- បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ
- ឈ្មោះ និងឋានៈរបស់ថៅក្រមដែលចេញដីកា។

មិនតែប៉ុណ្ណោះ ដីកាបង្គាប់ឱ្យនាំខ្លួនត្រូវមានចុះនូវកាលបរិច្ឆេទ និងចុះហត្ថលេខាដោយថៅក្រមស៊ើបសួរ ព្រមទាំងមានបោះត្រាផង។

ចំពោះនីតិវិធីនៃការអនុវត្ត ដីកាបង្គាប់ឱ្យនាំខ្លួនត្រូវប្រគល់ឱ្យទៅមន្ត្រីនគរបាលយុត្តិធម៌។ តែនៅក្នុងករណីបន្ទាន់ដីកាបង្គាប់ឱ្យនាំខ្លួនត្រូវធ្វើការផ្សព្វផ្សាយដល់អង្គភាពនគរបាល ឬកងរាជអាវុធតាមគ្រប់មធ្យោបាយដែលអាចធ្វើបាន។ ក្នុងពេលបំពេញបេសកកម្មនេះ ដើមដីកាត្រូវប្រគល់ជាបន្ទាន់ដល់មន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបន្ទុកអនុវត្តដីកានេះ។ មន្ត្រីនគរបាលយុត្តិធម៌មិន

[76] មាត្រា ១៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[77] មាត្រា ១៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[78] មាត្រា ១៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

អាចចូលទៅក្នុងលំនៅឋានរបស់បុគ្គលដែលពាក់ព័ន្ធមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨(ដប់ប្រាំបី) ល្ងាចបានឡើយ។ ប្រសិនបើជួបប្រទះនូវការលំបាកនោះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ពីបញ្ហាលំបាកទាំងនោះជូនចៅក្រមស៊ើបសួរដែលជាអ្នកចេញដីកាបង្គាប់ឱ្យនាំខ្លួន[79]។

នៅពេលអនុវត្តបេសកកម្ម មន្ត្រីនគរបាលយុត្តិធម៌ត្រូវនាំខ្លួនបុគ្គលដែលពាក់ព័ន្ធទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ។ ប្រសិនបើមានមូលហេតុនៃកាលៈទេសៈមានដូចជា លំបាកក្នុងការដឹកជញ្ជូន បុគ្គលដែលពាក់ព័ន្ធមិនអាចនាំទៅបង្ហាញខ្លួនដល់ចៅក្រមស៊ើបសួរក្រោយពេលចាប់ខ្លួនបានភ្លាមៗនោះ បុគ្គលនេះត្រូវតែនាំខ្លួនទៅក្នុងអង្គភាពនគរបាល ឬកងរាជអាវុធហត្ថក្នុងមណ្ឌលឃុំខ្លួន ឬទៅក្នុងពន្ធនាគារ។ បុគ្គលនេះត្រូវតែនាំខ្លួនទៅបង្ហាញខ្លួនយ៉ាងយូរបំផុតថ្ងៃបន្ទាប់ដល់ចៅក្រមស៊ើបសួរ ឬអ្នកជំនួស ករណីដែលការបង្ហាញខ្លួនមិនបានប្រព្រឹត្តទៅនៅថ្ងៃបន្ទាប់ទេ បុគ្គលពាក់ព័ន្ធត្រូវបានដោះលែងឱ្យមានសេរីភាពវិញ[80]។ ម្យ៉ាងទៀត កាលណាបុគ្គលម្នាក់ដែលត្រូវបានចាប់ខ្លួនដោយអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួនត្រូវបានឃុំខ្លួននោះ ចិរវេលានៃការឃុំខ្លួននេះត្រូវរាប់បញ្ចូលទៅក្នុងចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នប្រសិនបើមាន[81]។

### ១.១.៣ ដីកាបង្គាប់ឱ្យចាប់ខ្លួន

ដីកាបង្គាប់ឱ្យចាប់ខ្លួន គឺជាដីកាដែលបញ្ជាដល់កងកម្លាំងប្រដាប់អាវុធឱ្យស្រាវជ្រាវរកចាប់ និងឱ្យនាំខ្លួនបុគ្គលនោះទៅក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។ ម្យ៉ាងទៀត ជាការបញ្ជាដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឱ្យទទួល និងឃុំខ្លួនបុគ្គលនោះ។

ដីកាបង្គាប់ឱ្យចាប់ខ្លួន ជាដីកាដែលអាចចេញទៅលើជនត្រូវចោទ ឬបុគ្គលណាដែលមានតម្រុយពិរុទ្ធភាព។ ករណីនេះ លក្ខខណ្ឌដែលចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យចាប់ខ្លួនបានលុះត្រាតែ[82]៖

- បទល្មើសដែលចោទប្រកាន់ជាបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ
- បុគ្គលដែលពាក់ព័ន្ធ ហើយបានគេចខ្លួនមិនដឹងស្ថិតនៅទីកន្លែងណា ឬស្ថិតនៅក្រៅដែនដី

[79] មាត្រា ១៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[80] មាត្រា ១៩៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[81] មាត្រា ១៩៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[82] មាត្រា ១៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

នៃព្រះរាជាណាចក្រកម្ពុជា។

មុននឹងចេញដីកាបង្គាប់ឱ្យចាប់ខ្លួន ចៅក្រមស៊ើបសួរត្រូវតែទទួលយោបល់ពីព្រះរាជអាជ្ញា។ ចៅក្រមស៊ើបសួរត្រូវចេញដីកានេះដោយមានមូលហេតុច្បាស់លាស់ ក្រោយពីបានទទួលយោបល់ពីព្រះរាជអាជ្ញា[83]។ ព្រះរាជអាជ្ញាធានារ៉ាប់រងនូវការផ្សព្វផ្សាយដីកាបង្គាប់ឱ្យចាប់ខ្លួននេះ រីឯនិទ្ទេសដែលមានចុះក្នុងដីកាបង្គាប់ឱ្យចាប់ខ្លួន ត្រូវចុះនូវព័ត៌មានដូចខាងក្រោម[84]៖

- អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ
- បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា។

ដីកាបង្គាប់ឱ្យចាប់ខ្លួនត្រូវមានចុះកាលបរិច្ឆេទ និងហត្ថលេខាដោយចៅក្រមស៊ើបសួរ និងត្រូវមានបោះត្រាផង។

ចំពោះនីតិវិធីអនុវត្ត ដីកាបង្គាប់ឱ្យចាប់ខ្លួនត្រូវប្រគល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌។ ក្នុងករណីបន្ទាន់ដីកាបង្គាប់ឱ្យចាប់ខ្លួន ត្រូវផ្សព្វផ្សាយទៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថតាមគ្រប់មធ្យោបាយ។ ដើមដីកាត្រូវប្រគល់ក្នុងរយៈពេលខ្លីបំផុតឱ្យដល់មន្ត្រីនគរបាលយុត្តិធម៌ ដែលទទួលបន្ទុកនូវដីកាបង្គាប់ឱ្យចាប់ខ្លួន។ ករណីនេះមន្ត្រីនគរបាលយុត្តិធម៌ មិនអាចចូលទៅក្នុងលំនៅឋានរបស់បុគ្គលដែលពាក់ព័ន្ធមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចបានទេ នៅគ្រប់ការលំបាករបស់ខ្លួននៅពេលអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការរាយការណ៍ជូនចៅក្រមស៊ើបសួរ[85]។ ក្នុងករណីចាំបាច់ ដីកាបង្គាប់ឱ្យចាប់ខ្លួនអាចផ្សព្វផ្សាយជាអន្តរជាតិតាមរយៈក្រសួងយុត្តិធម៌ ដោយប្រើយន្តការនានាដែលមានប្រសិទ្ធភាព[86]។ ម្យ៉ាងទៀត ការបង្ហាញដីកាបង្គាប់ឱ្យចាប់ខ្លួន គឺជាបញ្ជាឱ្យប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ត្រូវទទួល និងឃុំខ្លួនជនត្រូវចោទដែលជាកម្មវត្ថុនៃដីកាបង្គាប់ឱ្យចាប់ខ្លួន។

[83] មាត្រា ១៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[84] មាត្រា ១៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[85] មាត្រា ១៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[86] មាត្រា ២០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនរក្សាទុកនូវដើមដីកា ឬចុងដីកាដែលមានបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម[87]។

នៅពេលដែលចាប់ខ្លួនបុគ្គលដែលពាក់ព័ន្ធបាន មន្ត្រីនគរបាលយុត្តិធម៌ត្រូវនាំជននោះទៅបង្ហាញដល់ចៅក្រមស៊ើបសួរ ឬអ្នកជំនួសក្នុងរយៈពេលយ៉ាងខ្លីបំផុត ប្រសិនស្ថិតក្នុងដំណាក់កាលនៅឡើយ។ ប្រសិនបើការនាំខ្លួនទៅបង្ហាញ តម្រូវឱ្យមានការផ្ទេរបុគ្គលពាក់ព័ន្ធទៅពន្ធនាគារ ឬទៅមណ្ឌលឃុំខ្លួនមួយផ្សេង ការផ្ទេរនេះត្រូវចាត់ចែងដោយអយ្យការ។ ផ្ទុយទៅវិញ ប្រសិនបើបុគ្គលពាក់ព័ន្ធមិនត្រូវបានគេនាំខ្លួនទៅបង្ហាញដល់ចៅក្រមស៊ើបសួរ ឬអ្នកជំនួសចៅក្រមស៊ើបសួរនៅថ្ងៃបន្ទាប់ពីការចាប់ខ្លួន បុគ្គលនេះត្រូវបានព្រះរាជអាជ្ញានាទីកន្លែងឃុំខ្លួនស្តាប់ចម្លើយ ហើយត្រូវធ្វើកំណត់ហេតុស្តីពីការស្តាប់ចម្លើយ រួចបញ្ជូនទៅចៅក្រមស៊ើបសួរ។ កាលណាបុគ្គលម្នាក់ត្រូវបានចាប់ខ្លួនត្រូវបានឃុំខ្លួននោះថិរវេលានៃការឃុំខ្លួន ត្រូវរាប់បញ្ចូលក្នុងថិរវេលានៃការឃុំខ្លួនបណ្ដោះ-អាសន្នប្រសិនបើមាន[88]។

### ១.១.៤ ដីកាបង្គាប់ឱ្យឃុំខ្លួន

ដីកាបង្គាប់ឱ្យឃុំខ្លួន គឺជាបញ្ជាដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឱ្យទទួល និងឱ្យឃុំខ្លួនជនត្រូវចោទ[89]។ ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យឃុំខ្លួនបាន លុះត្រាតែជនត្រូវចោទជាកម្មវត្ថុនៃដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន។

ដីកាបង្គាប់ឱ្យឃុំខ្លួនមានចុះនិទ្ទេសដូចតទៅ[90]៖

- អត្តសញ្ញាណនៃជនត្រូវចោទ
- បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា។

មិនតែប៉ុណ្ណោះ ដីកាបង្គាប់ឱ្យឃុំខ្លួនត្រូវមានចុះនូវកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ ព្រមទាំងមានបោះត្រាផង។

---

[87] មាត្រា ២០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[88] មាត្រា ២០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[89] មាត្រា ២២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[90] មាត្រា ២២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ចំពោះនីតិវិធីនៃការអនុវត្តដីកាបង្គាប់ឱ្យឃុំខ្លួនវិញ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនត្រូវតែទទួល និងឃុំខ្លួនបុគ្គលដែលមានដីកាបង្គាប់ឱ្យឃុំខ្លួនរហូតទាល់តែបានទទួលការឱ្យដំណឹងអំពីការដោះលែងឱ្យមានសេរីភាពវិញ[91]។ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនរក្សាទុកដើមដីកាបង្គាប់ឱ្យឃុំខ្លួន ឬចុងដីកានេះដែលបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម។

**១.២ ការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ**

**១.២.១ បុគ្គលដែលអាចដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ**

បុគ្គលដែលអាចត្រូវបានចៅក្រមស៊ើបសួរដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ គឺសំដៅទៅលើបុគ្គលដែលមានការចង្អុលបង្ហាញប្រាប់ឈ្មោះយ៉ាងច្បាស់លាស់ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា[92]។

ម្យ៉ាងវិញទៀត ចៅក្រមស៊ើបសួរក៏នៅមានអំណាចក្នុងការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យនូវបុគ្គលគ្រប់រូប ដែលមានតម្រុយច្បាស់លាស់ ហើយស៊ីចង្វាក់គ្នាយ៉ាងខ្លាំងថាបានចូលរួមប្រព្រឹត្តបទល្មើសទោះបីគ្មានការចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក៏ដោយ។

ចៅក្រមស៊ើបសួរអាចដាក់បុគ្គលនោះឱ្យស្ថិតនៅក្រោមការពិនិត្យក្នុងឋានៈ ជាចារី ជាអ្នកផ្តើមគំនិត ឬជាអ្នកសមគំនិត។

**១.២.២ បែបបទនៃការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ**

នៅក្នុងមាត្រា ១៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌមានកំណត់ពីបែបបទនៃការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យដោយមាត្រានេះបានកំណត់ថា នៅពេលដែលជនត្រូវចោទចូលបង្ហាញខ្លួនលើកដំបូង ចៅក្រមស៊ើបសួរត្រូវពិនិត្យអត្តសញ្ញាណរបស់ជនត្រូវចោទ និងប្រាប់ជននោះឱ្យដឹងរឿងរ៉ាវដែលចោទប្រកាន់ ព្រមទាំងឈ្មោះបទល្មើសដែលកំណត់ដោយច្បាប់។ ចៅក្រមស៊ើបសួរត្រូវប្រាប់ជនត្រូវចោទថាគាត់មានសេរីភាពក្នុងការឆ្លើយ ឬមិនឆ្លើយ ហើយក្នុងកំណត់ហេតុត្រូវមាននិទ្ទេសពីរឿងរ៉ាវ ការប្រាប់ និងឈ្មោះបទល្មើស។

ជនត្រូវចោទត្រូវទទួលដំណឹងពីសិទ្ធិទទួលជំនួយពីមេធាវី ដែលជ្រើសរើសពីសាមីខ្លួនផ្ទាល់ ឬការសុំឱ្យចាត់តាំងមេធាវីឱ្យខ្លួន ដោយអនុវត្តតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។ ផ្ទុយទៅវិញ ចំពោះ

---

[91] មាត្រា ២២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[92] មាត្រា ១២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ជនត្រូវចោទដែលជាអនីតិជនដាច់ខាតត្រូវតែមានមេធាវីអមជានិច្ច។

ចៅក្រមស៊ើបសួរត្រូវតែទទួលចម្លើយភ្លាម កាលណាបើជនត្រូវចោទយល់ព្រមក្នុងការផ្តល់នូវចម្លើយ។ បើមានភាពចាំបាច់ ចៅក្រមស៊ើបសួរអាចហៅរកអ្នកបកប្រែ ដោយអ្នកបកប្រែត្រូវស្បថស្របតាមសាសនា ឬជំនឿរបស់ខ្លួនថានឹងជួយដល់តុលាការ និងបកប្រែឱ្យបានត្រឹមត្រូវតាមចម្លើយទាំងឡាយ។ ក្នុងករណីណាក៏ដោយ អ្នកបកប្រែមិនអាចត្រូវជ្រើសរើសក្នុងចំណោមចៅក្រម ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ ភាគី ឬសាក្សីនោះទេ[93]។

## ១.៣ ការរក្សាជនត្រូវចោទឱ្យនៅក្រោមការចាត់ចែងរបស់តុលាការ

### ១.៣.១ ការឃុំខ្លួនបណ្តោះអាសន្ន

ការឃុំខ្លួនបណ្តោះអាសន្នអាចអនុវត្តបានតែក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលច្បាប់កំណត់ផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១(មួយ) ឆ្នាំ។

#### ក. មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន

ការឃុំខ្លួនបណ្តោះអាសន្នអាចត្រូវបានបង្គាប់ដោយមូលហេតុដូចខាងក្រោម[94]៖

- ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី
- ដើម្បីរារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត
- ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ
- ដើម្បីធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី
- ដើម្បីការពារសន្តិសុខឱ្យជនត្រូវចោទ
- ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈមិនឱ្យមានការច្របូកច្របល់ ដែលបណ្តាលមកពីបទល្មើស។

ទាំងនេះជាលក្ខខណ្ឌដែលអាចធ្វើការឃុំខ្លួនបណ្តោះអាសន្នបាន ទោះបីចៅក្រមស៊ើបសួរធ្វើការជ្រើសរើសយកនូវលក្ខខណ្ឌណាមួយ ក្នុងចំណោមលក្ខខណ្ឌទាំងនេះក៏ដោយសុទ្ធតែអាចជាមូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្នបានទាំងអស់។

---

[93] មាត្រា ១៨៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[94] មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

### ខ. ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន

ប្រសិនបើចៅក្រមស៊ើបសួរសម្រេចថាឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្ន ការឃុំខ្លួននេះត្រូវស្ថិតក្នុងថិរវេលាដែលកំណត់ដោយច្បាប់។ ឯថិរវេលានេះប្រែប្រួលទៅតាមប្រភេទនៃបទល្មើសចោទប្រកាន់ និងអាយុរបស់ជនត្រូវចោទឃុំខ្លួន។

ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នត្រូវបានកំណត់ដូចខាងក្រោមៈ

❖ **ប្រសិនបើជាប់ចោទពីបទល្មើសឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋប្រល័យពូជសាសន៍ ឬបទឧក្រិដ្ឋសង្គ្រាម** ការឃុំខ្លួនមិនអាចលើសពី ១ (មួយ) ឆ្នាំបានទេចំពោះបទល្មើសនីមួយៗ។ ប៉ុន្តែនៅពេលផុតថិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យារការឃុំខ្លួនបណ្ដោះអាសន្នម្ដងបាន ១ (មួយ) ឆ្នាំដោយដីកាមានសំអាងហេតុ ហើយការពន្យារពេលនេះអាចធ្វើបានតែពីរដងគត់[95]។

❖ **ប្រសិនបើជាប់ចោទពីបទឧក្រិដ្ឋ**

- **ជនត្រូវចោទជានីតិជនៈ** រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្នគឺ ៦ (ប្រាំមួយ) ខែ អាចពន្យារពេលបាន ៦ (ប្រាំមួយ) ខែទៀត ចំនួនពីរដង[96]។

- **ជនត្រូវចោទជាអនីតិជនអាយុចាប់ពី ១៤ ឆ្នាំដល់ក្រោម ១៦ ឆ្នាំៈ** រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤ (បួន) ខែបានទេ[97]។

- **ជនត្រូវចោទជាអនីតិជនអាយុចាប់ពី ១៦ ឆ្នាំដល់ក្រោម ១៨ ឆ្នាំៈ** រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៦ (ប្រាំមួយ) ខែបានទេ។

❖ **ប្រសិនបើជាប់ចោទពីបទមជ្ឈិម**

- **ជនត្រូវចោទជានីតិជនៈ** រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្នគឺ ៤ (បួន) ខែ ហើយអាចពន្យារពេលបាន ២(ពីរ) ខែទៀតតែម្ដងគត់ទោះជាយ៉ាងណារយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ននេះពុំអាចលើសពីពាក់កណ្ដាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់ឡើយ[98]។

- **ជនត្រូវចោទជាអនីតិជនអាយុចាប់ពី ១៤ ឆ្នាំដល់ក្រោម ១៦ ឆ្នាំៈ** រយៈពេលនៃការឃុំខ្លួន

---

[95] មាត្រា ២១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[96] មាត្រា ២០៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[97] មាត្រា ២១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[98] មាត្រា ២០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

បណ្ដោះអាសន្នមិនអាចលើសពី ២ (ពីរ) ខែបានទេ ហើយទោះជាយ៉ាងណារយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ននេះ ពុំអាចលើសពីពាក់កណ្ដាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់ទេ។

- **ជនត្រូវចោទជាអនីតិជនអាយុចាប់ពី ១៦ ឆ្នាំដល់ក្រោម ១៨ ឆ្នាំ:** រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤ (បួន) ខែបានទេ[99] ហើយទោះជាយ៉ាងណារយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ននេះ ពុំអាចលើសពីពាក់កណ្ដាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់ទេ។

### គ. ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ

ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំអាចធ្វើឡើងបានតាមរយៈ ៣ វិធីរួមមាន តាមរយៈការសម្រេចរបស់ចៅក្រមស៊ើបសួរ តាមរយៈបណ្ដឹងរបស់ព្រះរាជអាជ្ញា និងតាមរយៈបណ្ដឹងរបស់ជនត្រូវចោទ។

❖ **តាមរយៈការសម្រេចរបស់ចៅក្រមស៊ើបសួរ**

នៅក្នុងករណីដែលចៅក្រមស៊ើបសួរយល់ឃើញថា ធាតុផ្សំបទល្មើសមិនមានលក្ខណៈគ្រប់គ្រាន់ដើម្បីធ្វើការចោទប្រកាន់ទេនោះ ចៅក្រមស៊ើបសួរនឹងបង្គាប់ឱ្យដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំបានគ្រប់ពេល[100]។ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញា មុននឹងចេញដីកាដោះលែងជនត្រូវចោទដើម្បីសុំយោបល់រួមទាំងបញ្ជូនសំណុំរឿងឱ្យដល់ព្រះរាជអាជ្ញាពិនិត្យ ដោយព្រះរាជអាជ្ញាត្រូវផ្ដល់យោបល់នៅក្នុងរយៈពេលខ្លីបំផុត។ ឯចៅក្រមស៊ើបសួរត្រូវសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ ករណីបន្ទាន់ចៅក្រមអាចបង្គាប់ឱ្យដោះលែងជនត្រូវចោទភ្លាមដោយមិនរង់ចាំយោបល់ព្រះរាជអាជ្ញា គឺគ្រាន់តែចៅក្រមស៊ើបសួរត្រូវចង្អុលប្រាប់មូលហេតុនៃការបន្ទាន់នេះក្នុងដីកាសម្រេចរបស់ខ្លួន។

❖ **តាមរយៈបណ្ដឹងរបស់ព្រះរាជអាជ្ញា**

ព្រះរាជអាជ្ញាក៏អាចសុំឱ្យដោះលែងជនត្រូវចោទ បានគ្រប់ពេលវេលាដូចនឹងចៅក្រមស៊ើបសួរដែរ។ ករណីនេះចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ បើមិនគោរពតាមរយៈពេលនេះទេ ព្រះរាជអាជ្ញាអាចប្ដឹងសុំតាមរយៈពាក្យសុំទៅសភាស៊ើបសួរដែលអាចសម្រេចជំនួស

[99] មាត្រា ២១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[100] មាត្រា ២១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ចៅក្រមស៊ើបសួរបាន។ ផ្ទុយទៅវិញ ករណីមិនព្រមដោះលែងត្រូវមានសំអាងហេតុ[101]។

❖ **តាមរយៈបណ្ដឹងរបស់ជនត្រូវចោទ**

ករណីដែលជនត្រូវចោទត្រូវបានឃុំខ្លួន ជននោះក៏មានសិទ្ធិដាក់ពាក្យសុំឱ្យដោះលែងខ្លួននៅក្រៅឃុំបានគ្រប់ពេលវេលាផងដែរ។ កាលណាពាក្យបណ្ដឹងត្រូវបានដាក់ទៅចៅក្រមស៊ើបសួរ ចៅក្រមនោះឃុំបានគ្រប់ពេលវេលាផងដែរ។ កាលណាចៅក្រមស៊ើបសួរបានទទួលពាក្យសុំហើយ ចៅក្រមនោះត្រូវបញ្ជូនពាក្យសុំទៅព្រះរាជអាជ្ញាភ្លាមដើម្បីពិនិត្យ និងផ្ដល់យោបល់ក្នុងរយៈពេលខ្លីបំផុត។ ឯចៅក្រមស៊ើបសួរត្រូវសម្រេចយ៉ាងយូរបំផុតរយៈពេល ៥ (ប្រាំ) ថ្ងៃបន្ទាប់ពីបានបញ្ជូនពាក្យបណ្ដឹងទៅព្រះរាជអាជ្ញា។ កាលណាជនត្រូវចោទត្រូវបានបដិសេធមិនឱ្យនៅក្រៅឃុំ ជនត្រូវចោទមានសិទ្ធិដាក់ពាក្យសុំនៅក្រៅឃុំសារជាថ្មីម្ដងទៀតទៅចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរក្នុងរយៈពេល ១ (មួយ) ខែ បន្ទាប់ពីមានសេចក្ដីបដិសេធពាក្យសុំមុនករណីនេះ ចៅក្រមស៊ើបសួរ និងសភាស៊ើបសួរត្រូវសម្រេចលើពាក្យស្នើសុំនេះនៅក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃក្រោយពីបានទទួលពាក្យស្នើសុំ[102]។

### ១.៣.២ ការត្រួតពិនិត្យតាមផ្លូវតុលាការ

ការត្រួតពិនិត្យតាមផ្លូវតុលាការ គឺជាវិធានការដែលកាត់បន្ថយនូវសេរីភាពមួយចំនួនដោយឱ្យជនត្រូវចោទនៅក្រៅឃុំ ត្រូវគោរពកាតព្វកិច្ចមួយ ឬច្រើននៃមាត្រា ២២៣ (កាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ) ដោយមិនមានកំណត់នូវពេលវេលាណាមួយជាក់លាក់នោះទេ គឺអាស្រ័យទៅលើចៅក្រមស៊ើបសួរជាអ្នកកែប្រែ ឬលុបចោលបានគ្រប់ពេលវេលា។

#### ក. មូលហេតុនៃការត្រួតពិនិត្យតាមផ្លូវតុលាការ

ចៅក្រមស៊ើបសួរអាចប្រើនូវវិធានការដាក់ជនជាប់ចោទ ឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបាន លុះត្រាតែបទល្មើសដែលត្រូវបានចោទប្រកាន់នោះត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារ។

ការដាក់ឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដើម្បីបង្គាប់ជនត្រូវចោទដែលនៅក្រៅឃុំឱ្យគោរពកាតព្វកិច្ចមួយ ឬច្រើនដូចតទៅ៖

- មិនត្រូវចេញក្រៅព្រំប្រទល់ដែនដីកំណត់ដោយចៅក្រមស៊ើបសួរ

[101] មាត្រា ២១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[102] មាត្រា ២១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

- មិនត្រូវផ្លាស់ប្តូរលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ
- មិនត្រូវទៅកាន់ទីកន្លែងខ្លះដែលកំណត់ដោយចៅក្រមស៊ើបសួរ
- ត្រូវចូលបង្ហាញខ្លួនតាមការកំណត់នៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថដែលចាត់តាំងដោយចៅក្រមស៊ើបសួរ
- ត្រូវឆ្លើយតបនឹងការកោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ
- ប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជី គ្រប់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ
- មិនត្រូវបើកបររថយន្ត
- មិនត្រូវទទួល ឬជួបបុគ្គលមួយចំនួន ដែលចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ
- ដាក់ប្រាក់ធានាដែលចំនួនប្រាក់ធានា និងចិរវេលាបង់ប្រាក់គឺត្រូវបានកំណត់ដោយចៅក្រមស៊ើបសួរដោយផ្អែកទៅលើធនធានរបស់ជនត្រូវចោទ
- មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ។ ត្រូវប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីនូវអាវុធដែលជនត្រូវចោទកាន់កាប់
- ត្រូវប្រគល់ខ្លួនឱ្យពេទ្យដើម្បីពិនិត្យព្យាបាល និងជាយថាហេតុ ដាក់ឱ្យស្ថិតនៅក្រោមរបបព្យាបាលរោគក្នុងមន្ទីរពេទ្យ
- មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈខ្លះ[103]។

ដើម្បីអនុវត្តចំណុចទី១២ខាងលើ ចៅក្រមស៊ើបសួរមិនអាចហាមឃាត់ការអនុវត្តនូវអាណត្តិបោះឆ្នោត ឬសកម្មភាពខាងសហជីពបានទេ។

ផ្អែកតាមកាតព្វកិច្ចទាំងដប់ពីរចំណុចខាងលើ ឃើញថាការត្រួតពិនិត្យតាមផ្លូវតុលាការមានគោលដៅសំខាន់ៗ ៤ គឺ៖

- ដើម្បីធានាឱ្យជនត្រូវចោទមកបង្ហាញខ្លួននៅចំពោះមុខតុលាការ
- បន្ថយសេរីភាពមួយចំនួន កុំឱ្យកើតមានបទល្មើសបន្តទៀត
- ដាក់កំហិតនូវការព្យាបាលផ្នែកសង្គម ឬផ្នែកវិជ្ជសាស្រ្ត
- ដាក់ប្រាក់ធានាដើម្បីទុកសងការខូចខាតដល់ជនរងគ្រោះ។

---

[103] មាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

### ខ. បែបបទនៃការត្រួតពិនិត្យតាមផ្លូវតុលាការ

កាលណាចៅក្រមស៊ើបសួរ ធ្វើការសម្រេចដោយត្រូវដាក់ជនត្រូវចោទឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនោះ ការសម្រេចនេះអាចជាគំនិតផ្តួចផ្តើមរបស់ខ្លួន ឬតាមសេចក្តីសន្និដ្ឋានសរុបរបស់ព្រះរាជអាជ្ញា។ ករណីនេះ ចៅក្រមស៊ើបសួរត្រូវមានបញ្ជាក់ពីកាតព្វកិច្ចដែលតម្រូវទៅលើជនត្រូវចោទ។

ដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ត្រូវធ្វើការជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទដោយចៅក្រមស៊ើបសួរ។

ជាមួយគ្នានេះ ក្នុងករណីដែលចៅក្រមស៊ើបសួរទទួលពាក្យបណ្តឹងពីសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ដោយធ្វើការសុំឱ្យដាក់ជនត្រូវចោទស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការតែចៅក្រមស៊ើបសួរមិនព្រមតាមការសុំនោះ ចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ហើយដីកាសម្រេចបដិសេធនេះត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា។ ផ្ទុយទៅវិញករណីដែលចៅក្រមស៊ើបសួរមិនបានសម្រេចនៅក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃទេ ព្រះរាជអាជ្ញាអាចធ្វើពាក្យប្តឹងទៅសភាស៊ើបសួរដែលមានសិទ្ធិសម្រេចជំនួសចៅក្រមស៊ើបសួរបាន[104]។

ទោះជាយ៉ាងណា អនីតិជនអាយុតិចជាង ១៤ (ដប់បួន) ឆ្នាំ មិនអាចត្រូវដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនោះទេ[105]។

### គ. បុគ្គលដែលអាចកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការ

❖ **ចៅក្រមស៊ើបសួរ**

ចៅក្រមស៊ើបសួរអាចកែប្រែខ្លឹមសារនៃកាតព្វកិច្ច អាចលុបចោល អាចបញ្ចូល ឬបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលាតាមដីកា ដែលត្រូវជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ[106]។

❖ **តាមបណ្តឹងសុំរបស់ព្រះរាជអាជ្ញា**

ព្រះរាជអាជ្ញាអាចសុំឱ្យលើកលែង ឬកែប្រែនូវការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេល

---

[104] មាត្រា ២២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[105] មាត្រា ២២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[106] មាត្រា ២២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

វេលាទៅចៅក្រមស៊ើបសួរ ដែលត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ។ ដីកាសម្រេចនេះត្រូវជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា។ ប្រសិនចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេលនេះទេ ព្រះរាជអាជ្ញាអាចធ្វើពាក្យសុំទៅកាន់សភាស៊ើបសួរដែលអាចធ្វើសេចក្ដីសម្រេចជំនួសចៅក្រមស៊ើបសួរ។ ដីកាបដិសេធការប្ដឹងសុំរបស់ព្រះរាជអាជ្ញាត្រូវតែមានសំអាងហេតុ[107]។

❖ **តាមបណ្ដឹងសុំរបស់ជនត្រូវចោទ**

ជនត្រូវចោទអាចធ្វើពាក្យសុំទៅចៅក្រមស៊ើបសួរឱ្យលើកលែង ឬកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា។ ចៅក្រមស៊ើបសួរត្រូវបញ្ជូនពាក្យសុំនេះ និងសំណុំរឿងភ្លាមទៅឱ្យព្រះរាជអាជ្ញាពិនិត្យ ដើម្បីសុំយោបល់។ ចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃគិតពីថ្ងៃបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ ដីកាសម្រេចនេះ ត្រូវជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ[108]។

**ឃ. អានុភាពនៃការត្រួតពិនិត្យតាមផ្លូវតុលាការ**

ប្រសិនបើជនត្រូវចោទមិនបានអនុវត្តន៍ ឬបំពានទៅលើកាតព្វកិច្ចចៅក្រមស៊ើបសួរអាចឃុំខ្លួនជននោះបណ្ដោះអាសន្នបាន ដោយមិនចាំបាច់យោងមាត្រា ២០៤ (ករណីនៃការឃុំខ្លួនបណ្ដោះអាសន្ន) និងមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន) ព្រមទាំងមិនគិតពីបទល្មើសអ្វីទាំងអស់ ហើយទោះបីជាការឃុំខ្លួននោះអស់រយៈពេលអតិបរមានៃទោសដែលមានចែងក្នុងច្បាប់ក៏ដោយ។ ការសម្រេចនេះត្រូវធ្វើតាមដីកាដោយមានសំអាងហេតុ ហើយត្រូវជូនដំណឹងភ្លាមជូនទៅដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ ព្រមទាំងមេធាវីបើសិនជាមាន[109]។

ការឃុំខ្លួនបណ្ដោះអាសន្នដែលសម្រេចតាមករណីនេះ ចំពោះនីតិជនមិនឱ្យលើស ៤ (បួន) ខែ ឯចំពោះអនីតិជនអាយុពី ១៤ (ដប់បួន) ឆ្នាំទៅ ១៨ (ដប់ប្រាំបី) ឆ្នាំ មិនឱ្យលើស ២ (ពីរ) ខែ។

**២. អំណាចស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ**

**២.១ ការសួរចម្លើយជនត្រូវចោទ**

ចៅក្រមស៊ើបសួរមានសិទ្ធិគ្រប់គ្រាន់ក្នុងការសួរចម្លើយជនត្រូវចោទ តែការសួរចម្លើយនោះ

---

[107] មាត្រា ២២៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[108] មាត្រា ២២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[109] មាត្រា ២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

អាចធ្វើឡើងបានតែនៅចំពោះមុខមេធាវីអមរបស់ជនត្រូវចោទតែប៉ុណ្ណោះ ដោយមុននឹងសួរចម្លើយ ចៅក្រមស៊ើបសួរត្រូវកោះហៅមេធាវីយ៉ាងតិចបំផុត ៥(ប្រាំ) ថ្ងៃ ដើម្បីទុកពេលវេលាដល់មេធាវីអាចធ្វើការពិនិត្យមើលសំណុំរឿងនៃនីតិវិធី[110]។ ផ្ទុយទៅវិញ ចៅក្រមស៊ើបសួរក៏អាចសួរចម្លើយជនត្រូវចោទបានដោយគ្មានវត្តមានរបស់មេធាវី ក្នុងករណីដែលមេធាវីនោះត្រូវបានកោះហៅយ៉ាងត្រឹមត្រូវតែបែរជាមិនចូលបង្ហាញខ្លួននៅថ្ងៃ និងម៉ោងកំណត់ ហើយនៅក្នុងកំណត់ហេតុសួរចម្លើយជនត្រូវចោទនឹងត្រូវចុះនិទ្ទេសអំពីអវត្តមាននេះផងដែរ។

ករណីពិសេសពីរយ៉ាង ចៅក្រមស៊ើបសួរអាចសួរចម្លើយជនត្រូវចោទបានដោយមិនចាំបាច់កោះហៅមេធាវី។ ករណីទីមួយគឺ ជនត្រូវចោទសម្រេចចិត្តយ៉ាងជាក់លាក់ថាខ្លួននឹងបោះបង់ចោលនូវវត្តមានរបស់មេធាវីខ្លួន ហើយការបោះបង់នេះត្រូវចុះនៅក្នុងកំណត់ហេតុមួយដាច់ដោយឡែកពីកំណត់ហេតុសួរចម្លើយដោយត្រូវចុះហត្ថលេខារបស់ជនត្រូវចោទ។ ករណីទីពីរគឺ ក្នុងករណីបន្ទាន់ដែលបណ្តាលមកពីគ្រោះថ្នាក់ដល់ស្លាប់ ឬបណ្តាលពីការភ័យខ្លាចបាត់បង់នូវតម្រុយនៃភស្តុតាង ហើយក្នុងកំណត់ហេតុត្រូវតែចុះនិទ្ទេសនូវប្រភេទនៃភាពបន្ទាន់។

ក្នុងពេលសួរចម្លើយជនត្រូវចោទ ព្រះរាជអាជ្ញា និងមេធាវីក៏អាចលើកសំណួរបានដែរដោយមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ[111]។

ចំពោះរយៈពេលអប្បបរមានៃការសួរចម្លើយ កាលណាថិរវេលា ៤ (បួន) ខែ បានកន្លងផុតទៅដោយគិតចាប់ពីពេលសួរចម្លើយនៅពេលបង្ហាញខ្លួនលើកដំបូង បើជនត្រូវចោទមិនត្រូវបានសួរចម្លើយ ឬសួរតទល់ទេ ចៅក្រមស៊ើបសួរត្រូវទទួលចម្លើយប្រសិនបើជនត្រូវចោទបានស្នើសុំ។ តែបើចៅក្រមស៊ើបសួរមិនបានកោះហៅជនត្រូវចោទក្នុងថិរវេលា ១ (មួយ) ខែ ដោយគិតចាប់ពីថ្ងៃស្នើសុំរបស់ជនត្រូវចោទទេនោះ ជនត្រូវចោទអាចធ្វើការប្តឹងដោយផ្ទាល់ទៅសភាស៊ើបសួរនៃសាលា-ឧទ្ធរណ៍ដែលត្រូវទទួលចម្លើយនេះដោយខ្លួនឯង ឯកំណត់ហេតុត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរ[112]។

ទន្ទឹមនឹងនេះដែរ មេធាវីរបស់ជនត្រូវចោទដែលជាប់ឃុំអាចធ្វើប្រាស្រ័យទាក់ទងដោយសេរីជាមួយកូនក្តីរបស់ខ្លួននៅក្នុងពន្ធនាគារ ឬនៅក្នុងមណ្ឌលឃុំខ្លួន។ ការសន្ទនារវាងមេធាវី និងជន-

[110] មាត្រា ១៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[111] មាត្រា ១៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[112] មាត្រា ១៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ត្រូវចោទមិនអាចត្រូវគេស្តាប់ ឬថតបានទេ។ មេធាវីអាចអានលិខិតនៃសំណុំរឿងឱ្យកូនក្តីខ្លួនស្តាប់ ផ្ទុយទៅវិញ មេធាវីមិនអាចឱ្យលិខិតថតចម្លងពីលិខិតនៃសំណុំរឿងដល់កូនក្តីរបស់ខ្លួនឡើយ[113]។

**២.២ ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី**

ស្រដៀងគ្នាទៅនឹងការសួរចម្លើយជនត្រូវចោទដែរ ចៅក្រមស៊ើបសួរមានសិទ្ធិគ្រប់គ្រាន់ក្នុងការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែការស្តាប់ចម្លើយអាចធ្វើឡើងបានចំពោះមុខមេធាវីអមរបស់ដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ ដោយមុននឹងស្តាប់ចម្លើយចៅក្រមស៊ើបសួរត្រូវកោះហៅមេធាវីយ៉ាងតិចបំផុត ៥ (ប្រាំ) ថ្ងៃ ដើម្បីទុកពេលវេលាដល់មេធាវីអាចធ្វើការពិនិត្យមើលសំណុំរឿងនៃនីតិវិធី[114]។ ផ្ទុយទៅវិញ ចៅក្រមស៊ើបសួរក៏អាចស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីបានដោយគ្មានវត្តមានរបស់មេធាវី ក្នុងករណីដែលមេធាវីនោះត្រូវបានកោះហៅយ៉ាងត្រឹមត្រូវ ហើយមិនចូលបង្ហាញខ្លួននៅថ្ងៃ និងម៉ោងកំណត់ ដូចនេះនៅក្នុងកំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីនឹងត្រូវចុះនិទ្ទេសអំពីអវត្តមាននេះផងដែរ។

ក្នុងករណីពិសេសពីរយ៉ាង ដែលចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីបានដោយមិនចាំបាច់កោះហៅមេធាវី។ ករណីទីមួយគឺ ដើមបណ្តឹងរដ្ឋប្បវេណីបោះបង់ចោលយ៉ាងជាក់លាក់នូវវត្តមានរបស់មេធាវីខ្លួន ការបោះបង់នេះនឹងត្រូវចុះក្នុងកំណត់ហេតុមួយដោយឡែកពីកំណត់ហេតុស្តាប់ចម្លើយដោយត្រូវចុះហត្ថលេខារបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ករណីទីពីរគឺ ក្នុងករណីបន្ទាន់ដែលបណ្តាលមកពីគ្រោះថ្នាក់ដល់ស្លាប់ ឬបណ្តាលពីការភ័យខ្លាចបាត់បង់នូវតម្រុយនៃភស្តុតាង ហើយក្នុងកំណត់ហេតុត្រូវតែចុះនិទ្ទេសនូវប្រភេទនៃភាពបន្ទាន់។

ក្នុងពេលដែលចៅក្រមស៊ើបសួរកំពុងស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ព្រះរាជអាជ្ញា និងមេធាវីក៏អាចលើកសំណួរបានដែរដោយមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ [115]។ កាលបើពុំមានការអនុញ្ញាតឱ្យលើកជាសំណួរពីចៅក្រមស៊ើបសួរទេ ករណីនេះនឹងត្រូវនិទ្ទេសក្នុងកំណត់ហេតុ។

**២.៣ ការស្តាប់ចម្លើយសាក្សី**

តាមស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌដើម្បីជាជំនួយដល់ការស៊ើបសួរ ចៅក្រមស៊ើបសួរអាច

[113] មាត្រា ១៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[114] មាត្រា ១៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[115] មាត្រា ១៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ស្តាប់ចម្លើយបុគ្គលគ្រប់រូប ដែលខ្លួនគិតថាវាមានអត្ថប្រយោជន៍ដល់ការស្រាវជ្រាវស្វែងរកឱ្យឃើញនូវការពិត[116]។ នៅក្នុងការស្តាប់ចម្លើយ ចៅក្រមស៊ើបសួរនឹងស្តាប់ចម្លើយសាក្សីដាច់ពីគ្នាដោយគ្មានវត្តមានជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។ ករណីខ្លះចៅក្រមស៊ើបសួរក៏អាចសួរតទល់រវាងជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីបានដែរ។

បុគ្គលគ្រប់រូបដែលត្រូវបានចៅក្រមស៊ើបសួរកោះហៅនៅក្នុងឋានៈជាសាក្សី ត្រូវតែចូលមកបង្ហាញខ្លួន។ បើបុគ្គលនោះរឹងទទឹងមិនព្រមចូលមកបង្ហាញខ្លួនទេ ចៅក្រមស៊ើបសួរអាចស្នើសុំឱ្យកងកម្លាំងសាធារណៈបង្ខំសាក្សីឱ្យចូលមកបង្ហាញខ្លួនបាន។ ចៅក្រមស៊ើបសួរជាអ្នកចេញបញ្ជាឱ្យចូលបង្ហាញខ្លួន ដោយបញ្ជានោះត្រូវមានអត្តសញ្ញាណរបស់សាក្សី កាលបរិច្ឆេទ ហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង។

ប្រសិនបើសាក្សីមានជម្ងឺ ឬមិនអាចធ្វើដំណើរបាន ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជីអាចចុះទៅកាន់លំនៅឋាន ឬទីកន្លែងដែលសាក្សីនៅដើម្បីទទួលបាននូវចម្លើយ[117]។

មុននឹងឆ្លើយទៅនឹងសំណួរ សាក្សីម្នាក់ៗតម្រូវឱ្យស្បថស្របតាមសាសនា ឬជំនឿរបស់ខ្លួនថានិយាយតែការពិត[118]។ ទោះជាយ៉ាងណា សាក្សីមួយចំនួនច្បាប់មិនតម្រូវឱ្យធ្វើសម្បថទេ ក្នុងនោះរួមមានសាក្សីដូចជា[119]៖

- ឪពុក ម្តាយ និងបុព្វជនគ្រប់រូបរបស់ជនត្រូវចោទ
- កូនប្រុស កូនស្រី និងបច្ឆាជនគ្រប់រូបរបស់ជនត្រូវចោទ
- បង ប្អូនប្រុស ស្រីរបស់ជនត្រូវចោទ
- បង ប្អូនថ្លៃប្រុស ស្រីរបស់ជនត្រូវចោទ
- ប្តី ឬប្រពន្ធរបស់ជនត្រូវចោទ ទោះបីលែងលះគ្នាហើយក៏ដោយ
- កុមារអាយុតិចជាង ១៤ ឆ្នាំ។

ក្នុងករណីចាំបាច់ ចៅក្រមស៊ើបសួរក៏អាចហៅរកអ្នកបកប្រែដើម្បីស្តាប់ចម្លើយសាក្សី។

---

[116] មាត្រា ១៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[117] មាត្រា ១៥៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[118] មាត្រា ១៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[119] មាត្រា ១៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ដើម្បីគោរពដល់សិទ្ធិការពារខ្លួន ចៅក្រមស៊ើបសួរមិនអាចស្តាប់ចម្លើយក្នុងឋានៈជាសាក្សីនូវបុគ្គលណាមួយ ដែលមានតម្រុយពិរុទ្ធភាពថាបានប្រព្រឹត្តបទល្មើសនោះទេ។ នៅក្នុងករណីនេះ ចៅក្រមស៊ើបសួរត្រូវយកនីតិវិធីនៃមាត្រា ១៨៣ (ការជូនដំណឹងអំពីការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ) នៃក្រមនីតិវិធីព្រហ្មទណ្ឌមកអនុវត្ត[120]។

**២.៤ ការឆែកឆេរ និងការចាប់យកវត្ថុតាង**

ចៅក្រមស៊ើបសួរអាចធ្វើការឆែកឆេរបាន ដោយការឆែកឆេរនោះចៅក្រមស៊ើបសួរត្រូវធ្វើនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេត្រូវធ្វើការឆែកឆេរនៅចំពោះមុខសាក្សី ២ (ពីរ) នាក់ ដែលចាត់តាំងដោយចៅក្រមស៊ើបសួរ ហើយសាក្សីដែលជ្រើសតាំងនោះមិនអាចជានគរបាល ឬកងរាជអាវុធហត្ថ ដែលជាកងកម្លាំងរួមប្រតិបត្តិការនៅក្នុងការឆែកឆេរឡើយ។ ចំពោះពេលវេលានៃការឆែកឆេរ ចៅក្រមស៊ើបសួរមិនអាចចាប់ផ្តើមមុនម៉ោង ៦(ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាច បានទេ លើកលែងតែមានករណីដូចខាងក្រោម[121]៖

- ករណីឆែកឆេរនៅទីកន្លែងដែលបើកចំហរដល់សាធារណៈជន
- ករណីឆែកឆេរនៅគ្រប់ទីកន្លែងដែលផលិត រក្សាទុក ដូញដូរ ចែកចាយ ប្រើប្រាស់គ្រឿងញៀន។

ចំពោះការឆែកឆេរនៅក្នុងការិយាល័យមេធាវី ចៅក្រមស៊ើបសួរអាចធ្វើការឆែកឆេរបាននៅចំពោះមុខប្រធានគណៈមេធាវី ឬប្រតិភូរបស់ប្រធានគណៈមេធាវី។ ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុស្តីពីការឆែកឆេរ ដោយមានហត្ថលេខារបស់ខ្លួន និងក្រឡាបញ្ជី រួមជាមួយនឹងអ្នកកាន់កាប់ទីកន្លែង ឬសាក្សីពីរនាក់។ កំណត់ហេតុត្រូវមានចុះនិទ្ទេសអំពីអត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬសាក្សីនីមួយៗ តែបើការឆែកឆេរនៅការិយាល័យមេធាវីវិញ កំណត់ហេតុត្រូវចុះនិទ្ទេសអំពីវត្តមានរបស់ប្រធានគណៈមេធាវី ឬប្រតិភូនៃប្រធានគណៈមេធាវី។

នៅក្នុងការឆែកឆេរ ចៅក្រមស៊ើបសួរក៏អាចចាប់យកវត្ថុតាងបានដោយបិទស្លាកបោះត្រាលើវត្ថុតាងនោះ។ បន្ទាប់ពីបានបង្ហាញវត្ថុតាងដែលបានចាប់យកនោះដល់អ្នកកាន់កាប់ទីកន្លែង ឬសាក្សីពីរនាក់រួច ចៅក្រមស៊ើបសួរនឹងធ្វើកំណត់ហេតុស្តីពីការចាប់យកវត្ថុតាង ដែលរួមមានបញ្ជី

[120] មាត្រា ១៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[121] មាត្រា ១៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

សារពើភ័ណ្ឌនៃវត្ថុដែលចាប់យក។ កំណត់ហេតុស្តីពីការចាប់វត្ថុតាង ត្រូវមានចុះហត្ថលេខារបស់ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី រួមជាមួយអ្នកកាន់កាប់ទីកន្លែង ឬសាក្សីពីរនាក់ ហើយត្រូវនិទ្ទេសពីអត្តសញ្ញាណនៃអ្នកកាន់កាប់ទីកន្លែង ឬសាក្សីនីមួយៗ[122]។

នៅពេលអនុវត្តន៍កិច្ចរបស់ខ្លួន ករណីចៅក្រមស៊ើបសួរបានចាប់យកនូវវត្ថុតាងហើយតែមិនទាន់ចេញដីកាដំណោះស្រាយរឿងនៅឡើយទេ ចៅក្រមស៊ើបសួរមានសមត្ថកិច្ចសងទៅឱ្យម្ចាស់ដើមវិញនូវវត្ថុដែលចាប់បាន កាលណាកម្មសិទ្ធិនេះគ្មានការជំទាស់អ្វីប្រាកដប្រជាទេ។ ក្រោយពីទទួលបានមតិពីព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរអាចសម្រេចតាមដីកាដែលមានសំអាងហេតុហើយត្រូវជូនដំណឹងជាបន្ទាន់ដល់អ្នកប្តឹង និងមេធាវីនៃអ្នកប្តឹងប្រសិនបើមាន[123]។

ក្នុងករណីវត្ថុដែលចាប់យកនោះជាវត្ថុមិនគួរប្រគល់សងទៅឱ្យអ្នកប្តឹងសុំវិញទេ កាលណាវិធានការនេះអាចបង្កជាឧបសគ្គដល់ការសំដែងឱ្យឃើញនូវការពិត។ ចំពោះវត្ថុមានគ្រោះថ្នាក់ដល់បុគ្គល ឬទ្រព្យសម្បត្តិដូចជា អាវុធ ឬជាតិផ្ទុះ ព្រមទាំងវត្ថុដែលការកាន់កាប់មិនស្របច្បាប់មិនអាចត្រូវបានប្រគល់សងទៅឱ្យសាមីខ្លួនទេ ដោយវត្ថុនោះត្រូវរឹបអូសជាកម្មសិទ្ធិរដ្ឋ។

### ២.៥ កោសលវិច័យ

ករណីបើមានបញ្ហាបច្ចេកទេសចោទឡើង ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យធ្វើកោសលវិច័យដោយឯកឯង ឬតាមពាក្យសុំរបស់ព្រះរាជអាជ្ញា ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈការចេញដីកាចាត់តាំងអ្នកជំនាញ ដោយនៅក្នុងដីកានោះត្រូវបញ្ជាក់ពីបេសកកម្មរបស់អ្នកជំនាញព្រមនឹងរយៈពេលបំពេញបេសកកម្ម[124]។ ផ្ទុយទៅវិញ កាលបើចៅក្រមស៊ើបសួរពុំយល់ព្រមធ្វើតាមពាក្យសុំធ្វើកោសលវិច័យទេ ចៅក្រមស៊ើបសួរអាចធ្វើការសម្រេចតាមដីកាដោយមានសំអាងហេតុក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ប្រសិនបើពាក្យសុំនោះចេញពីព្រះរាជអាជ្ញា និង ១ (ខែ) ខែ ប្រសិនបើពាក្យសុំនោះចេញពីជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី ដោយដីកាសម្រេចនោះត្រូវជូនដំណឹងដល់អ្នកប្តឹងសុំជាបន្ទាន់។

ជាទូទៅ ចៅក្រមស៊ើបសួរត្រូវតែជ្រើសរើសអ្នកជំនាញដែលបានចុះឈ្មោះនៅក្នុងបញ្ជីថ្នាក់

[122] មាត្រា ១៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[123] មាត្រា ១៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[124] មាត្រា ១៦៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ជាតិនៃអ្នកជំនាញដែលបានរៀបចំឡើងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌[125]។ ចៅក្រមស៊ើបសួរក៏អាចចាត់តាំងអ្នកជំនាញដែលមិនមានឈ្មោះក្នុងបញ្ជីថ្នាក់ជាតិបាន តាមដីកាដោយមាននូវសំអាងហេតុជាពិសេស តែអ្នកជំនាញត្រូវស្បថទៅតាមសាសនា ឬជំនឿរបស់ខ្លួន មុននឹងបំពេញបេសកកម្ម។

អ្នកជំនាញបំពេញបេសកកម្មរបស់ខ្លួន ដោយស្ថិតក្រោមការពិនិត្យរបស់ចៅក្រមស៊ើបសួរ ដូចនេះអ្នកជំនាញត្រូវតែជូនព័ត៌មានដល់ចៅក្រមស៊ើបសួរអំពីបេសកកម្មរបស់ខ្លួន[126]។ ក្នុងករណីត្រូវប្រគល់វត្ថុចាប់យកជូនអ្នកជំនាញ ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុស្តីពីការប្រគល់វត្ថុចាប់យក ដូចនេះអ្នកជំនាញអាចបំបែកស្លាកដែលបិទដើម្បីធ្វើកោសលវិច័យបាន។ ម្យ៉ាងទៀត ដើម្បីបំពេញបេសកកម្មរបស់ខ្លួន អ្នកជំនាញអាចស្តាប់ចម្លើយបុគ្គលគ្រប់រូបក្រៅពីជនត្រូវចោទដោយមិនចាំបាច់ស្បថនោះទេ[127]។ ប៉ុន្តែ បើអ្នកជំនាញយល់ឃើញថាចាំបាច់ក្នុងការស្តាប់ចម្លើយជនត្រូវចោទ អ្នកជំនាញអាចសុំការអនុញ្ញាតពីចៅក្រមស៊ើបសួរ។ ជនត្រូវចោទអាចសុំឱ្យអ្នកជំនាញស្តាប់ចម្លើយរបស់ខ្លួនចំពោះមុខមេធាវី តែករណីពិនិត្យវេជ្ជសាស្ត្រ ឬចិត្តសាស្ត្រនោះ ត្រូវធ្វើដោយគ្មានវត្តមានមេធាវី។

ក្រោយពីបញ្ចប់ការធ្វើកោសលវិច័យ អ្នកជំនាញត្រូវធ្វើរបាយការណ៍ដូចមានចែងក្នុងមាត្រា ១៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ កាលណារបាយការណ៍កោសលវិច័យត្រូវបានធ្វើរួចហើយនោះ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញា ហើយត្រូវកោះហៅជនត្រូវចោទ ដើមបណ្តឹង-រដ្ឋប្បវេណី មេធាវី ដើម្បីប្រាប់ឱ្យដឹងពីសេចក្តីសន្និដ្ឋាននៃកោសលវិច័យ[128]។ ក្រោយពីដឹងពីសេចក្តីសន្និដ្ឋាននោះរួច ព្រះរាជអាជ្ញា ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី អាចដាក់ពាក្យសុំឱ្យធ្វើនូវកោសលវិច័យបន្ថែម ឬប្រតិកោសលវិច័យ ក្នុងរយៈពេលមិនអាចតិចជាង ១០ (ដប់) ថ្ងៃទេ។

ចំពោះសោហ៊ុយក្នុងការធ្វើកោសលវិច័យជាបន្ទុករបស់អ្នកស្នើសុំ[129]។

ប៉ុន្តែ កាលបើការធ្វើកោសលវិច័យ កោសលវិច័យបន្ថែម ឬប្រតិកោសលវិច័យស្នើសុំដោយចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ នោះសោហ៊ុយជាបន្ទុករបស់រដ្ឋ។

[125] មាត្រា ១៦៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[126] មាត្រា ១៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[127] មាត្រា ១៦៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[128] មាត្រា ១៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[129] មាត្រា ១៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

### ២.៦ ការស្តាប់ទូរស័ព្ទ

ក្នុងករណីចាំបាច់ណាមួយដើម្បីស្វែងរកការពិត ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យស្តាប់ និងថតការសន្ទនាតាមទូរស័ព្ទ ឬតាមមធ្យោបាយគមនាគមន៍ដូចជា ការបញ្ជូនសារតាមទូរសារ ឬសារតាមអ៊ិនធើណែតបាន[130]។

ចៅក្រមស៊ើបសួរអាចស្នើសុំឱ្យគ្រប់អង្គភាពសាធារណៈ ឬគ្រប់មន្ត្រីរាជការជំនាញតាំងនូវឧបករណ៍បច្ចេកទេសដើម្បីធ្វើការថត ដោយចៅក្រមស៊ើបសួរត្រូវបញ្ជាក់អំពីទំនាក់ទំនងដែលត្រូវចាប់ និងរយៈពេលនៃបេសកកម្មនៅក្នុងដីកាសម្រេចរបស់ខ្លួន។ ករណីនេះ អង្គភាពសាធារណៈ ឬមន្ត្រីរាជការត្រូវចាត់តាំង ត្រូវបំពេញបេសកកម្មទៅតាមការស្នើរបស់ចៅក្រមស៊ើបសួរ ហើយត្រូវធ្វើសេចក្តីរាយការណ៍ព័ត៌មានដល់ចៅក្រមស៊ើបសួរ កាលបើជួបនូវការលំបាកណាមួយ។ ក្រោយពីបានបញ្ចប់បេសកកម្ម អង្គភាពសាធារណៈ ឬមន្ត្រីរាជការត្រូវយកសំឡេងដែលថតបានមកចម្លងជាលាយលក្ខណ៍អក្សរឱ្យបានត្រឹមត្រូវតាមសំឡេងដើម។ ចំណែកឯសំឡេងដែលថតបាន ត្រូវប្រគល់ជូនចៅក្រមស៊ើបសួរ និងត្រូវបិទស្លាក។ គ្រប់ពេលវេលាទាំងអស់ ចៅក្រមស៊ើបសួរមានសិទ្ធិចុះទៅកាន់ទីកន្លែងដែលធ្វើការចាប់ និងថតនោះបាន ដោយគ្មានមូលហេតុអ្វីអាចហាមឃាត់បានឡើយ។

### ២.៧ ការចាត់ឱ្យស៊ើបសួរជំនួស

ចៅក្រមស៊ើបសួរអាចប្រគល់នូវសិទ្ធិឱ្យចៅក្រមនៃតុលាការរបស់ខ្លួន ឬតុលាការផ្សេងទៀត មន្ត្រីនគរបាលយុត្តិធម៌ ឬអង្គភាពនគរបាលយុត្តិធម៌ដើម្បីបំពេញកិច្ចស៊ើបសួរបាន តាមរយៈដីកាចាត់ឱ្យស៊ើបសួរជំនួស[131]។ ដីកាចាត់ឱ្យស៊ើបសួរជំនួស ត្រូវតែមានទំនាក់ទំនងដោយផ្ទាល់ជាមួយបទល្មើសដែលបានចោទប្រកាន់ និងត្រូវណែនាំឱ្យបានច្បាស់លាស់ ពោលគឺចៅក្រមស៊ើបសួរត្រូវកំណត់ចិរវេលាដែលត្រូវអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស។ ដីកានេះត្រូវមានចុះកាលបរិច្ឆេទ ចុះហត្ថលេខារបស់ចៅក្រមស៊ើបសួរ និងមានបោះត្រាផងដែរ។ ទោះជាយ៉ាងណា ចៅក្រមស៊ើបសួរមានសិទ្ធិដកហូតដីកាចាត់ឱ្យស៊ើបសួរជំនួសបានគ្រប់ពេលវេលា[132]។

ជាទូទៅ រាល់កិច្ចការស៊ើបសួរទាំងអស់អាចជាកម្មវត្ថុនៃដីកាចាត់ឱ្យស៊ើបសួរជំនួស។ ប៉ុន្តែ

[130] មាត្រា ១៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[131] មាត្រា ១៧៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[132] មាត្រា ១៧៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ក្រមនីតិវិធីព្រហ្មទណ្ឌបានដាក់កម្រិតសម្រាប់ការប្រគល់សិទ្ធិឱ្យមន្ត្រីនគរបាលយុត្តិធម៌។ ចៅក្រមស៊ើបសួរមិនអាចប្រគល់សិទ្ធិការស៊ើបសួរជំនួសខ្លួនទាក់ទិននឹងការសួរចម្លើយជនត្រូវចោទ និងការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីដល់មន្ត្រីនគរបាលយុត្តិធម៌នោះទេ[133]។ មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយសាក្សី ដោយមុនឆ្លើយសំណួរសាក្សីត្រូវស្បថជាមុនសិន លើកលែងតែចំពោះរាល់នូវសាក្សីដែលមានចែងក្នុងមាត្រា ១៥៦ (សាក្សីដែលអនុញ្ញាតឱ្យរួចពីសម្បថ) នៃក្រមនីតិវិធីព្រហ្មទណ្ឌតែប៉ុណ្ណោះដែលមិនតម្រូវឱ្យស្បថនោះទេ។ កាលបើស្តាប់ចម្លើយសាក្សីណាម្នាក់បានលេចតម្រុយនៃពិរុទ្ធជនលើសាក្សីនោះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ឈប់ការស្តាប់ ហើយត្រូវរាយការណ៍ជូនចៅក្រមស៊ើបសួរ[134]។ ចំពោះការឃាត់ខ្លួនក្នុងក្របខ័ណ្ឌនៃការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស អំណាចដែលប្រគល់ឱ្យព្រះរាជអាជ្ញាដូចមានចែងក្នុងមាត្រា ៩៦ (ការឃាត់ខ្លួន) ដល់មាត្រា ១០២ (កំណត់ហេតុសរុបនៃការឃាត់ខ្លួន) ត្រូវប្រើប្រាស់ដោយចៅក្រមស៊ើបសួរ[135]។

[133] មាត្រា ១៨០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[134] មាត្រា ១៧៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[135] មាត្រា ១៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

# ជំពូកទី៥
# ដំណាក់កាលជំនុំជម្រះក្នុងរឿងក្តីព្រហ្មទណ្ឌ

ការជម្រះក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្រ្តខ្មែរតាមនីតិវិធី និងច្បាប់ជាធរមាន[136]។ ដំណាក់កាលជំនុំជម្រះ គឺជាដំណាក់កាលចុងក្រោយនៅក្នុងនីតិវិធីព្រហ្មទណ្ឌ កាលណាដំណាក់កាលស៊ើបសួរបានបញ្ចប់សព្វគ្រប់ហើយ រឿងក្តីនោះអាចត្រូវបានបញ្ចប់លុះត្រាតែឆ្លងកាត់នូវការជំនុំជម្រះរួចចេញនូវសេចក្តីសម្រេចហៅថា សាលក្រម។

## ផ្នែកទី១៖ ចំណាត់ការរបស់តុលាការមុនសវនាការ

### ១. ការកំណត់កាលបរិច្ឆេទសវនាការ

កាលបរិច្ឆេទនៃសវនាការត្រូវកំណត់ដោយប្រធានតុលាការ លើកលែងតែករណីនៃនីតិវិធីចូលបង្ហាញខ្លួនភ្លាម។ ករណីដែលតុលាការបានទទួលបណ្តឹង ដោយការបញ្ជូនទៅជំនុំជម្រះផ្ទាល់ដោយដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ប្រធានតុលាការត្រូវគិតគូរតាមរយៈពេលដែលចែងនៅក្នុងមាត្រា ៤៥៧ (រយៈពេលដែលត្រូវគោរពរវាងការប្រគល់ដីកាកោះហៅ បញ្ជូនទៅជំនុំជម្រះផ្ទាល់ និងការបង្គាប់ឱ្យចូលបង្ហាញខ្លួន) និងមាត្រា ៤៦៦ (រយៈពេលដែលត្រូវគោរពរវាងដីកាកោះហៅ និងការបង្គាប់ឱ្យចូលបង្ហាញខ្លួន) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីធ្វើការកំណត់នូវកាលបរិច្ឆេទបើកសវនាការ[137]។

កាលបរិច្ឆេទដែលបានកំណត់នោះ នឹងត្រូវជូនដំណឹងដោយផ្ទាល់មាត់ដល់ព្រះរាជអាជ្ញា។

### ២. ការកោះហៅភាគីឱ្យចូលសវនាការ

ក្នុងករណីដែលតុលាការបានទទួលបណ្តឹងដោយដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ដូចនេះព្រះរាជអាជ្ញាត្រូវធ្វើការកោះហៅនូវភាគីឱ្យចូលរួមក្នុងពេលសវនាការរួមមានដូចជា ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ (កាលណាជននេះមិនទាន់ត្រូវបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋ-ប្បវេណីនៅមុខចៅក្រម) សាក្សី អ្នកជំនាញ អ្នកបកប្រែ និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីតាមព័ត៌មានដែលផ្តល់ដោយជនជាប់ចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី[138] ។

[136] មាត្រា ១២៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
[137] មាត្រា ២៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧
[138] មាត្រា ២៩៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

## ២.១ ការកោះហៅជនជាប់ចោទឱ្យចូលសវនាការ

ក្នុងករណីនៃដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញាត្រូវកោះហៅជនជាប់ចោទឱ្យចូលសវនាការ។ ការកោះហៅនេះត្រូវធ្វើឡើងដោយដីកាកោះហៅជនជាប់ចោទឱ្យចូលសវនាការដែលត្រូវមាននិទ្ទេសដូចតទៅ[139]៖

- អត្តសញ្ញាណនៃជនជាប់ចោទ
- កាលបរិច្ឆេទ និងទីកន្លែងកំណើតនៃជនជាប់ចោទ
- លំនៅឋាននៃជនជាប់ចោទ
- ការយោងដីកា ឬសាលដីកាបញ្ជូន
- តុលាការដែលទទួលបណ្តឹងដើម្បីជំនុំជម្រះ
- ទីកន្លែង កាលបរិច្ឆេទ និងម៉ោងនៃសវនាការ
- កាលបរិច្ឆេទ និងហត្ថលេខារបស់ព្រះរាជអាជ្ញា។

ដីកាកោះហៅនេះក៏ត្រូវមានបញ្ជាក់ពីភាពអាចអមដោយមេធាវីរបស់ជនជាប់ចោទផងដែរ។ ចំណែករយៈពេលរវាងការប្រគល់ដីកាកោះហៅឱ្យជនជាប់ចោទ និងថ្ងៃកំណត់ឱ្យចូលបង្ហាញខ្លួននៅមុខតុលាការត្រូវកំណត់ដូចតទៅ[140]៖

- ១៥ (ដប់ប្រាំ) ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដីនៃតុលាការជាន់ដំបូង
- ២០ (ម្ភៃ) ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅទីកន្លែងមួយផ្សេងទៀតនៃដែនដីជាតិ
- ២ (ពីរ) ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងរដ្ឋមួយជាប់ព្រំដែនព្រះរាជាណាចក្រកម្ពុជា
- ៣ (បី) ប្រសិនបើជនជាប់ចោទរស់នៅទីកន្លែងមួយផ្សេងទៀត។

ប៉ុន្តែក្នុងករណីជនជាប់ចោទត្រូវឃុំខ្លួន គ្មានរយៈពេលណាមួយត្រូវបានទាមទារឡើយរវាងការប្រគល់ដីកាដល់ជនជាប់ចោទ និងថ្ងៃកំណត់ឱ្យចូលបង្ហាញខ្លួននៅមុខតុលាការ។

ដីកាកោះហៅជនជាប់ចោទឱ្យចូលសវនាការនេះ គឺអាចត្រូវប្រគល់ឱ្យជនជាប់ចោទដោយផ្ទាល់ដៃដោយព្រះរាជអាជ្ញា ឬអាជ្ញាសាលា។ ដីកាកោះនេះក៏អាចត្រូវប្រគល់ដោយក្រឡាបញ្ជី តាម

[139] មាត្រា ៤៦៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[140] មាត្រា ៤៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ផ្លូវរដ្ឋបាល ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនប្រសិនបើជនជាប់ចោទត្រូវឃុំពីរឿងមួយផ្សេងទៀត ឬតាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ។ ចំណែក ចុងដីកាកោះហៅអាចត្រូវបានប្រគល់ដោយអាជ្ញាសាលាដល់ជនជាប់ចោទករណីជួបប្រទះជនជាប់ចោទនៅលំនៅឋាន ឬនៅកន្លែងដទៃទៀត ឬអាជ្ញាសាលាអាចប្រគល់នូវចុងដីកាកោះដល់បុគ្គលនីតិជនទាំងឡាយដែលមានវត្តមាននៅលំនៅឋានករណីដែលអវត្តមានជនជាប់ចោទ ឬអាជ្ញាសាលាប្រគល់ដល់មេឃុំ ឬចៅសង្កាត់ ករណីជនជាប់ចោទមិនព្រមទទួលដីកាកោះ ឬគ្មានបុគ្គលណាមានវត្តមាននៅលំនៅឋានជនជាប់ចោទ ឬមានបុគ្គលដែលមានវត្តមានតែមិនព្រមទទួលដីកាកោះនោះ [141] ។ គ្រប់ចុងដីកាកោះទាំងអស់ត្រូវភ្ជាប់ជាមួយនឹងលិខិតចម្លងមួយច្បាប់នៃដីកាបញ្ជូនរឿងទៅតុលាការជំនុំជម្រះ[142]។

### ២.២ ការកោះហៅជនក្រៅពីជនជាប់ចោទឱ្យចូលសវនាការ

ជនក្រៅពីជនជាប់ចោទនៅត្រង់នេះគឺសំដៅទៅលើ ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី អ្នកជំនាញ អ្នកបកប្រែ និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី។ ជនទាំងនេះត្រូវបានកោះហៅឱ្យចូលសវនាការតាមរយៈដីកាកោះហៅ រួមមានដីកាកោះហៅដើមបណ្តឹងរដ្ឋប្បវេណី ដីកាកោះហៅជនរងគ្រោះ ដីកាកោះហៅសាក្សី ដីកាកោះហៅអ្នកជំនាញ ដីកាកោះហៅអ្នកបកប្រែ និងដីកាកោះហៅអ្នកទទួលខុសត្រូវរដ្ឋប្បវេណី។ ដីកាកោះហៅទាំងនេះមានចុះនិទ្ទេសដូចតទៅ[143]៖

- អត្តសញ្ញាណនៃដើមបណ្តឹងរដ្ឋប្បវេណី ឬជនរងគ្រោះ ឬសាក្សី ឬអ្នកជំនាញ ឬអ្នកបកប្រែ ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី
- លំនៅឋាននៃដើមបណ្តឹងរដ្ឋប្បវេណី ឬជនរងគ្រោះ ឬសាក្សី ឬអ្នកជំនាញ ឬអ្នកបកប្រែ ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី
- ឈ្មោះជនជាប់ចោទ និងបទល្មើសដែលចោទប្រកាន់
- តុលាការដែលត្រូវជំនុំជម្រះ
- ទីកន្លែង កាលបរិច្ឆេទ និងម៉ោងនៃសវនាការ
- កាលបរិច្ឆេទ និងហត្ថលេខារបស់ព្រះរាជអាជ្ញា។

---

141 មាត្រា ៤៦៧ ដល់ ៤៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

142 មាត្រា ៤៧៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

143 មាត្រា ៤៧៥ ដល់ ៤៨០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

## ផ្នែកទី២៖ នីតិវិធីក្នុងពេលសវនាការ

### ១. ការរៀបចំសណ្តាប់ធ្នាប់ក្នុងពេលសវនាការ

មុនចាប់ផ្តើមសវនាការ ក្រឡាបញ្ជីត្រូវធ្វើការផ្ទៀងផ្ទាត់ពីវត្តមានរបស់អ្នកដែលចូលរួមក្នុងសវនាការដើម្បីរាយការណ៍ជូនតុលាការ។ ក្រឡាបញ្ជីមានរយៈពេល ៥ (ប្រាំ) នាទី ក្នុងការអាននូវបទបញ្ជាផ្ទៃក្នុងនៃសវនាការឱ្យអ្នកចូលរួមបានស្តាប់ដើម្បីជានាទូវរបៀបរៀបរយក្នុងសវនាការ។ នាពេលដែលក្រឡាបញ្ជីបានអានរួចរាល់ហើយ ក្រឡាបញ្ជីនឹងត្រូវធ្វើការអញ្ជើញចៅក្រមជំនុំជម្រះ ឬក្រុមប្រឹក្សាជំនុំជម្រះឱ្យចូលរួមសវនាការ។ នៅពេលដែលចៅក្រមជំនុំជម្រះ ឬក្រុមប្រឹក្សាជំនុំជម្រះចូលមកកាន់បន្ទប់សវនាការ អ្នកចូលរួមក្នុងសវនាការទាំងអស់ត្រូវតែងើបឈរឡើងជាសញ្ញាគោរពអង្គតុលាការ បន្ទាប់មកចៅក្រមជំនុំជម្រះ ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះនឹងអនុញ្ញាតឱ្យអង្គុយដើម្បីសម្រួលឥរិយាបថ ហើយក្រឡាបញ្ជីនឹងធ្វើការអាននូវបញ្ជីវត្តមានរបស់ជនដែលចូលរួម។

#### ១.១ ការពិនិត្យ និងផ្ទៀងផ្ទាត់អត្តសញ្ញាណអ្នកចូលរួម

ក្នុងដំណាក់កាលនេះក្រឡាបញ្ជីធ្វើការហៅឈ្មោះជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី និងអ្នកជំនាញ ដើម្បីផ្ទៀងផ្ទាត់អត្តសញ្ញាណជនទាំងនោះថាពិតជាត្រឹមត្រូវ[144]។

កាលណាបើដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ត្រូវបានតំណាងដោយសហព័ទ្ធ ឬញាតិលោហិតផ្ទាល់នោះ ក្រឡាបញ្ជីពិនិត្យមើលអត្តសញ្ញាណនៃអ្នកតំណាង ព្រមទាំងសុពលភាពនៃការប្រគល់សិទ្ធិ។ ក្នុងករណីចាំបាច់ក្រឡាបញ្ជីត្រូវសុំយោបល់ប្រធានសវនាការ។

ក្រោយពីផ្ទៀងផ្ទាត់រួចរាល់ហើយនោះ ភាគីនីមួយៗត្រូវអង្គុយនៅតាមកន្លែងរៀងៗខ្លួននៅក្នុងបន្ទប់សវនាការ។ ជនជាប់ចោទមិនត្រូវទាក់ទងនឹងគ្នាទេ។ អ្នកជំនាញ និងសាក្សីថយខ្លួនទៅនៅក្នុងបន្ទប់រង់ចាំដែលទុកបម្រុងឱ្យខ្លួន ដោយមិនអាចមើលឃើញ ឬឮអ្វីដែលប្រព្រឹត្តទៅនៅក្នុងបន្ទប់សវនាការទេ។ ទោះនៅក្នុងពេលសវនាការ ឬក្នុងបន្ទប់រង់ចាំ សាក្សីមិនត្រូវទាក់ទងគ្នាទេ។

#### ១.២ ការដឹកនាំធ្វើសម្បថ

ប្រធានសវនាការសួរសាក្សីម្នាក់ៗថា តើជាញាតិលោកហិត ឬញាតិពន្ធរបស់ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ឬក៏ជាអ្នកស៊ីឈ្នួលបម្រើជនទាំងនោះឬទេ។

---

[144] មាត្រា ៣២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ប៉ុន្តែមុននឹងឆ្លើយទៅនឹងសំណួររបស់ប្រធានសវនាការ សាក្សីនីមួយៗត្រូវតែស្បថថាខ្លួននិយាយតែការពិតស្របតាមសាសនា ឬជំនឿរបស់ខ្លួន[145]។ ក្នុងករណីនេះ បទប្បញ្ញត្តិនៃមាត្រា ១៥៦ (សាក្សីដែលអនុញ្ញាតឱ្យរួចពីសម្បថ) នៃក្រមនីតិវិធីព្រហ្មទណ្ឌក៏ត្រូវបានយកមកអនុវត្តផងដែរ។ ក្រោយពេលឆ្លើយទៅនឹងសំណួររួចហើយ សាក្សីនីមួយៗត្រូវតែនៅបម្រុងខ្លួនសម្រាប់សេចក្តីត្រូវការរបស់តុលាការ។ តុលាការអាចអនុញ្ញាតឱ្យសាក្សីថយខ្លួន ប្រសិនបើវត្តមានរបស់សាក្សីលែងចាំបាច់។

ក្រៅពីសាក្សី ក៏នៅមានអ្នកបកប្រែផងដែរដែលតម្រូវឱ្យធ្វើសម្បថ។ នៅក្នុងករណីចាំបាច់ ប្រធានសវនាការអាចហៅរកអ្នកបកប្រែ ដោយអ្នកបកប្រែនេះត្រូវស្បថស្របតាមសាសនា ឬជំនឿរបស់ខ្លួនថា ខ្លួននឹងជួយដល់តុលាការ និងបកប្រែចម្លើយឱ្យបានស្មោះត្រង់។ នៅក្នុងករណីណាក៏ដោយ អ្នកបកប្រែមិនអាចត្រូវបានជ្រើសរើសក្នុងចំណោមចៅក្រម ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ គូភាគី ឬសាក្សីទេ[146]។

### ២. សមាសភាពនៃអង្គសវនាការ

សមាសភាពនៃសវនាការមានដូចតទៅ៖

- ចៅក្រមជំនុំជម្រះ ឬក្រុមប្រឹក្សាជំនុំជម្រះ (ចំពោះបទមជ្ឈិម និងបទលហុ ចៅក្រម ០១ រូប និងចំពោះបទឧក្រិដ្ឋ ចៅក្រម ០៣ រូប ដោយក្នុងចំណោមចៅក្រមទាំងបីរូបនេះ មានចៅក្រម ០១ រូប ជាប្រធាននៃក្រុមប្រឹក្សាជំនុំជម្រះ ចំណែកឯចៅក្រម ០២ រូប ទៀតជាចៅក្រមប្រឹក្សា ប៉ុន្តែចៅក្រមជំនុំជម្រះមិនអាចជាចៅក្រមដែលបានបំពេញកិច្ចស៊ើបសួរនៅក្នុងសំណុំរឿងក្តីតែមួយទេ)
- តំណាងអយ្យការ ០១ រូប (ដោយវត្តមានព្រះរាជអាជ្ញាមានភាពចាំបាច់ណាស់នៅក្នុងនីតិវិធីសវនាការ និងជាអ្នកតំណាងឱ្យសង្គម តាងនាមជាដើមបណ្តឹងអាជ្ញា)
- ក្រឡាបញ្ជី ០១ រូប (ក្រឡាបញ្ជីត្រូវអានបទបញ្ជាផ្ទៃក្នុង ពិនិត្យអត្តសញ្ញាណអ្នកចូលរួម និងធ្វើការកត់សម្គាល់ហេតុតាមការបង្គាញរបស់ចៅក្រម)
- មេធាវី (បទឧក្រិដ្ឋត្រូវតែមានមេធាវី បទមជ្ឈិមមានមេធាវីក៏បានអត់មេធាវីក៏បាន)
- ជនជាប់ចោទ (ជាកម្មវត្ថុនៃសវនាការ តែតុលាការអាចជម្រះក្តីដោយអវត្តមានជននេះបាន)

---

[145] មាត្រា ៣២៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[146] មាត្រា ៣៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

- ជនរងគ្រោះ ឬដើមបណ្ដឹងរដ្ឋប្បវេណី (ជាភាគីនៃការទាមទារក្នុងនីតិវិធីតុលាការ តែបើមានការអវត្តមានជននេះមិនមែនជាឧបសគ្គក្នុងការបើកសវនាការឡើយ)
- សាក្សី និងអ្នកជំនាញ
- អ្នកបកប្រែ (ករណីចាំបាច់តម្រូវឱ្យមានអ្នកបកប្រែ)
- សាធារណៈជន (រាល់សាធារណៈជនអាចចូលរួមក្នុងសវនាការបានដោយសេរី តែចំពោះសវនាការមួយចំនួនមិនអនុញ្ញាតឱ្យសាធារណៈជនចូលរួម ឬបើកជូនជាសាធារណៈឡើយ ប៉ុន្តែការប្រកាសសាលក្រមត្រូវតែធ្វើជាសាធារណៈជាដាច់ខាត)។

### ៣. កិច្ចពិភាក្សាដេញដោលក្នុងពេលសវនាការ

#### ៣.១ ការសួរដេញដោលរបស់តុលាការ

ប្រធានសវនាការដឹកនាំការពិភាក្សាដេញដោល[147]។ ការសួរដេញដោលនេះត្រូវតែប្រព្រឹត្តទៅនៅក្នុងសវនាការជាសាធារណៈ ដោយប្រធានសវនាការត្រូវរ៉ាប់រងឱ្យមានសណ្តាប់ធ្នាប់ល្អនៅពេលសវនាការ។ ដូច្នេះ ប្រធានសវនាការមានសិទ្ធិហាមឃាត់អនីតិជនខ្លះ ឬទាំងអស់មិនឱ្យចូលក្នុងបន្ទប់សវនាការ ឬបណ្តេញបុគ្គលគ្រប់រូបដែលបង្កភាពច្របូកច្របល់ដល់របៀបរៀបរយនៃការសួរដេញដោល។

ប៉ុន្តែកាលបើតុលាការយល់ឃើញថាសាធារណភាពបង្កឱ្យមានគ្រោះថ្នាក់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬទំនៀមទម្លាប់នោះ តុលាការតាមសេចក្តីសម្រេចមានសំអាងហេតុអាចបង្គាប់ឱ្យការពិភាក្សាដេញដោលទាំងស្រុង ឬមួយផ្នែកប្រព្រឹត្តទៅជាសម្ងាត់[148]។ សេចក្តីសម្រេចរបស់តុលាការដែលបង្គាប់ឱ្យធ្វើការពិភាក្សាដេញដោលជាសម្ងាត់ មិនអាចតវ៉ាទេ។

នៅក្នុងកិច្ចពិភាក្សាដេញដោលនេះ ប្រធានសវនាការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី និងអ្នកជំនាញ តាមលំដាប់លំដោយដែលខ្លួនយល់ឃើញថាមានប្រយោជន៍។ ម្យ៉ាងទៀត ប្រធានសវនាការអាចស្តាប់នូវចម្លើយមន្ត្រី និងភ្នាក់ងារនគរបាលយុត្តិដែលបានចូលរួមក្នុងការស៊ើបអង្កេតក្នុងឋានៈជាសាក្សី។ ចំពោះព្រះរាជអាជ្ញា មេធាវី

[147] មាត្រា ៣១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[148] មាត្រា ៣១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

និងភាគី អាចត្រូវបានអនុញ្ញាតឱ្យលើកសំណួរសួរ[149]។ គ្រប់ការលើកសំណួរទាំងអស់ត្រូវតែបានការអនុញ្ញាតពីប្រធានសវនាការ។ ក្រៅពីសំណួររបស់តំណាងអយ្យការ និងមេធាវី សំណួរផ្សេងៗនឹងត្រូវសួរដោយប្រធានសវនាការ។ បើមានការតវ៉ា ប្រធានសវនាការត្រូវសម្រេចដោយឥស្សរចិត្តថា តើសំណួរនេះត្រូវតែសួរឬទេ។

យ៉ាងណាមិញ ការសួរចម្លើយជនជាប់ចោទតម្រូវឱ្យប្រធានសវនាការប្រាប់ជនជាប់ចោទឱ្យបានដឹងពីអំពើដែលគេចោទប្រកាន់លើខ្លួន និងសួរចម្លើយជនជាប់ចោទគ្រប់សំណួរ ទាំងសំណួរដាក់បន្ទុក និងដោះបន្ទុក ដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់ការសម្តែងឱ្យឃើញការពិត។ ក្រោយពីប្រធានសវនាការសួរចម្លើយរួច ព្រះរាជអាជ្ញា មេធាវី និងភាគី អាចត្រូវបានអនុញ្ញាតលើកជាសំណួរសួរដល់ជនជាប់ចោទ ដោយមានការអនុញ្ញាតពីប្រធានសវនាការ[150]។ បើមានការតវ៉ា ប្រធានសវនាការត្រូវសម្រេចដោយឥស្សរចិត្តថា តើសំណួរនេះត្រូវតែសួរឬទេ។

ទោះជាយ៉ាងណា នៅក្នុងដំណាក់កាលសួរដេញដោលនេះមិនបានផ្តោតតែលើការពិភាក្សាសួរចម្លើយដើម្បីយកជាព័ត៌មានតែម្យ៉ាងនោះទេ ប៉ុន្តែការថ្លឹងថ្លែងដោយឥស្សរចិត្តអំពីតម្លៃភស្តុតាងដែលបានដាក់ជូនឱ្យពិនិត្យដោយជនណាម្នាក់ក៏ត្រូវបានធ្វើឡើងក្នុងដំណាក់កាលនេះផងដែរ[151]។

**៣.២ ការបិទកិច្ចពិភាក្សាដេញដោល**

បន្ទាប់ពីកិច្ចពិភាក្សាដេញដោល ប្រធានសវនាការបើកឱ្យភាគីទាំងអស់ដូចខាងក្រោមនេះនិយាយតាមលំដាប់លំដោយដូចតទៅ[152]៖

- ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនជាប់ចោទ ដើម្បីកត់សម្គាល់ខ្លីៗ
- មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីធ្វើសេចក្តីសន្និដ្ឋានការពារ
- ព្រះរាជអាជ្ញា ដើម្បីធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ
- មេធាវីរបស់អ្នកទទួលខុសត្រូវរដ្ឋប្បវេណី និងមេធាវីរបស់ជនជាប់ចោទ ដើម្បីធ្វើនូវសេចក្តីសន្និដ្ឋានការពារ។

---

[149] មាត្រា ៣២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[150] មាត្រា ៣២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[151] មាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[152] មាត្រា ៣៣៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ដើមបណ្តឹងរដ្ឋប្បវេណី និងព្រះរាជអាជ្ញា អាចឆ្លើយតបទៅវិញបាន។ ប៉ុន្តែ ជនជាប់ចោទ និងមេធាវីរបស់ខ្លួនត្រូវនិយាយក្រោយគេបង្អស់ជានិច្ច។ ការបំពេញទម្រង់ការនេះ ត្រូវតែកត់ត្រាទុកក្នុងកំណត់ហេតុសវនាការ និងក្នុងសាលក្រម។

រហូតទល់នឹងការបិទកិច្ចពិភាក្សាដេញដោល ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី អាចធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងជូនលិខិតស្នាមទាំងអស់ដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់ការសម្តែងឱ្យឃើញការពិត។ សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរត្រូវចុះទិដ្ឋាការដោយប្រធានសវនាការ និងក្រឡាបញ្ជី ហើយត្រូវភ្ជាប់ទៅក្នុងសំណុំរឿង[153]។

ប្រសិនការពិភាក្សាដេញដោលមិនបានបញ្ចប់នៅក្នុងពេលសវនាការនោះទេ តុលាការអាចបន្តនៅពេលសវនាការក្រោយតាមកាលបរិច្ឆេទដែលខ្លួនកំណត់[154]។

### ៣.៣ ការកត់កំណត់ហេតុសវនាការ

ក្រឡាបញ្ជី គឺជាអ្នកទទួលបន្ទុកក្នុងការកត់នូវកំណត់ហេតុនាពេលសវនាការ។ ដូចនេះ នៅពេលសវនាការក្រឡាបញ្ជីត្រូវសរសេរកំណត់ហេតុសវនាការ ដែលមានគោលដៅផ្តល់មធ្យោបាយដល់សាលាឧទ្ធរណ៍អាចធ្វើការពិនិត្យនីត្យានុកូលភាពនៃនីតិវិធី និងបានយល់ដឹងអំពីការពិភាក្សាដេញដោលផងដែរ។ ម្យ៉ាងទៀត ក្រឡាបញ្ជីត្រូវខិតខំរៀបរាប់ដោយយកចិត្តទុកដាក់អំពីការប្រព្រឹត្តទៅនៃសវនាការ និងកត់ត្រាឱ្យបានត្រឹមត្រូវតាមសំណួរដែលសួរ ព្រមទាំងចម្លើយរបស់ជនជាប់-ចោទ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញ[155]។

កំណត់ហេតុសវនាការត្រូវមានចុះហត្ថលេខាដោយក្រឡាបញ្ជី និងចុះទិដ្ឋាការក្រោយពីការផ្ទៀងផ្ទាត់ដោយប្រធានសវនាការក្នុងរយៈពេល ១០ (ដប់) ថ្ងៃ ក្រោយថ្ងៃប្រកាសសាលក្រម។

## ៤. ការប្រកាសសាលក្រម

ក្រោយពីបិទកិច្ចពិភាក្សាដេញដោល តុលាការនឹងថយខ្លួនចូលទៅក្នុងបន្ទប់ពិភាក្សាចំនួនប្រមាណជា ១៥ (ដប់ប្រាំ) ទៅ ៣០ (សាមសិប) នាទីដើម្បីធ្វើការពិភាក្សា។ គ្មានបណ្តឹងសុំណាមួយ

---

[153] មាត្រា ៣៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[154] មាត្រា ៣៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[155] មាត្រា ៣៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ដែលអាចត្រូវដាក់ជូនតុលាការបានទៀតទេ ព្រមទាំងគ្មានទឡ្ហីករណ៍ណាមួយអាចត្រូវបានលើកយកមកសំអាងទៀតបានដែរ[156]។ ព្រះរាជអាជ្ញា និងក្រឡាបញ្ជី មិនត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងការពិភាក្សាសម្រេចនេះទេ។ ក្នុងដំណាក់កាលនេះ អ្នកចូលរួមសវនាការទាំងអស់ត្រូវនៅក្នុងបន្ទប់សវនាការដដែល ដូចនេះក្រឡាបញ្ជីត្រូវធានាអោយបាននូវគូភាគី និងអ្នកចូលរួមទាំងអស់ឱ្យគោរពបទបញ្ជាផ្ទៃក្នុង និងនីតិវិធីជំនុំជម្រះរបស់តុលាការ។

បន្ទាប់ពីពិចារណារួចហើយ កាលបើយល់ឃើញថាមានភស្តុតាងគ្រប់គ្រាន់ មានពិរុទ្ធភាពអាចដាក់បន្ទុកទៅលើជនជាប់ចោទហើយនោះ ប្រធានសវនាការអាចចេញមកប្រកាសសាលក្រមភ្លាមៗជាសាធារណៈដោយតាងនាមប្រជារាស្ត្រខ្មែរ។ ប៉ុន្តែ ប្រសិនយល់ឃើញថាមិនអាចប្រកាសសាលក្រមភ្លាមៗបានទេនោះ ប្រធានសវនាការត្រូវជូនដំណឹងដល់ភាគីនូវកាលបរិច្ឆេទ ដែលត្រូវប្រកាសសាលក្រម។ គ្រប់សាលក្រមត្រូវតែប្រកាសនៅពេលសវនាការសាធារណៈ ចំណែកផ្នែកនៃសេចក្តីសម្រេចត្រូវអានដោយប្រធានសវនាការដោយប្រើសម្លេងខ្លាំងៗ[157]។

ប្រសិនបើយល់ឃើញថា ការស្រាវជ្រាវថ្មីជាការចាំបាច់តុលាការអាចបង្គាប់តាមសាលក្រមឱ្យធ្វើការស៊ើបសួរបន្ថែម។ អ្នកដែលមានសមត្ថកិច្ចស៊ើបសួរបន្ថែមនេះគឺ[158]៖

- ប្រធានសវនាការ
- ចៅក្រមមួយរូបនៃក្រុមប្រឹក្សាជំនុំជម្រះ
- ចៅក្រមដទៃទៀតនៃសាលាដំបូង។

ចៅក្រមដែលចាត់តាំងដោយសាលក្រមអាចចុះទៅលើគ្រប់វិសាលភាពនៃដែនដីជាតិ អាចស្តាប់ចម្លើយសាក្សី អាចធ្វើការឆែកឆេរ អាចចាប់យកវត្ថុតាង អាចបង្គាប់ឱ្យធ្វើកោសលវិច័យ។ ដើម្បីអាចអនុវត្តការស៊ើបសួរបន្ថែមនេះ ចៅក្រមអាចចេញដីកាចាត់ឱ្យស៊ើបសួរជំនួសបាន។

**ផ្នែកទី៣៖ នីតិវិធីក្រោយសវនាការ**

**១. ការតាក់តែងសាលក្រម**

សេចក្តីសម្រេចរបស់សាលាដំបូងហៅថា សាលក្រម។ សាលក្រមនេះត្រូវបានប្រកាសជា

[156] មាត្រា ៣៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[157] មាត្រា ៣៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[158] មាត្រា ៣៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

សាធារណៈនៅថ្ងៃដែលពិភាក្សាដេញដោល ឬនៅក្រោយពេលសវនាការ ដែលកាលបរិច្ឆេទនៃការចេញសាលក្រមនេះនឹងត្រូវបានប្រាប់ដល់ភាគីដែលមានវត្តមាននៅពេលជំនុំជម្រះ។

នៅក្នុងសេចក្តីសម្រេចរបស់តុលាការមានបញ្ជាក់ពីការកំណត់នូវពិរុទ្ធភាព និងប្រកាសអំពីទោសដែលត្រូវបានកំណត់ដោយច្បាប់។ ករណីតុលាការយល់ឃើញថាមិនមែនជាបទល្មើស ឬជនជាប់ចោទគ្មានពិរុទ្ធភាព តុលាការនឹងប្រកាសសាលក្រមដោយសម្រេចឱ្យជនជាប់ចោទគ្មានទោសពោលគឺរួចផុតពីការចោទប្រកាន់។ ផ្ទុយទៅវិញ ករណីបើតុលាការសម្រេចថាមានទោសត្រូវដាក់ពន្ធនាគារ បើសិនជាជនជាប់ចោទមានវត្តមាននៅក្នុងសវនាការ តុលាការអាចចេញដីកាបង្គាប់ឱ្យឃុំខ្លួន ប៉ុន្តែបើសិនជាជនជាប់ចោទមិនមានវត្តមាននៅក្នុងសវនាការទេ ក្នុងករណីនេះតុលាការនឹងចេញដីកាបង្គាប់ឱ្យចាប់ខ្លួន។

សាលក្រមត្រូវមានចុះសេចក្តីដូចខាងក្រោម[159]៖

- កាលបរិច្ឆេទនៃសវនាការ
- កាលបរិច្ឆេទនៃការប្រកាសសាលក្រម
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលជំនុំជម្រះ
- ឈ្មោះ និងឋានៈតំណាងអយ្យការ
- ឈ្មោះ និងឋានៈរបស់ក្រឡាបញ្ជី
- ឈ្មោះ ទីលំនៅ កាលបរិច្ឆេទ និងទីកន្លែងកំណើត មុខរបររបស់ជនជាប់ចោទរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី
- ឈ្មោះរបស់មេធាវី។

ប្រធាន និងក្រឡាបញ្ជីត្រូវចុះហត្ថលេខាលើសាលក្រម រួចសាលក្រមដើមត្រូវតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជីយ៉ាងយូរបំផុត ៨ (ប្រាំបី) ថ្ងៃ ក្រោយការប្រកាសសាលក្រម។ ការិយាល័យក្រឡាបញ្ជីត្រូវតែរក្សាទុកសាលក្រមដើមជានិច្ច។ ករណីមានបណ្តឹងឧទ្ធរណ៍ ក្រឡាបញ្ជីអាចផ្តល់ច្បាប់ចម្លងនៃសាលក្រម។

[159] មាត្រា ៣៥៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

## ២. ការជូនដំណឹងពីសាលក្រម

គ្រប់សាលក្រមទាំងអស់មិនមែនសុទ្ធតែត្រូវបានធ្វើការជូនដំណឹងនោះទេ ដើម្បីឱ្យដឹងថា សាលក្រមណាខ្លះដែលត្រូវធ្វើការជូនដំណឹងនោះ គប្បីយល់ពីប្រភេទនៃសាលក្រមជាមុនសិន។

សាលក្រមត្រូវបានបែងចែកជាបីប្រភេទគឺ សាលក្រមចំពោះមុខ សាលក្រមដែលត្រូវចាត់ទុកថាចំពោះមុខ សាលក្រមកំបាំងមុខ។

### ២.១ សាលក្រមចំពោះមុខ

ប្រសិនបើជនជាប់ចោទចូលបង្ហាញខ្លួននៅពេលសវនាការនោះសាលក្រម គឺជាសាលក្រមចំពោះមុខជនជាប់ចោទ។ សាលក្រមចំពោះមុខ ជនជាប់ចោទមិនត្រូវបានឱ្យដំណឹងដល់ជននេះទេ ហើយសាលក្រមចំពោះមុខនេះអនុញ្ញាតឱ្យប្តឹងឧទ្ធរណ៍បាន។ ម្យ៉ាងទៀត សាលក្រមនៅតែជាសាលក្រមចំពោះមុខដដែល ទោះក្នុងករណីជនជាប់ចោទចាកចេញពីបន្ទប់សវនាការក៏ដោយ[160]។

មិនតែប៉ុណ្ណោះ សាលក្រមក៏ជាសាលក្រមចំពោះមុខផងដែរ កាលណាជនជាប់ចោទត្រូវបានសួរចម្លើយនៅក្នុងលក្ខខណ្ឌដែលពុំបានបង្ហាញខ្លួនដោយសារតែមូលហេតុនៃសុខភាព ឬមានមូលហេតុធ្ងន់ធ្ងរ ដែលជាហេតុធ្វើឱ្យជនជាប់ចោទមិនអាចចូលទៅបង្ហាញខ្លួននៅក្នុងសវនាការបាន ករណីនេះប្រធានសវនាការអាចធ្វើការបង្គាប់ឱ្យសួរចម្លើយជនជាប់ចោទ នៅទីកន្លែងដែលជននោះស្នាក់នៅ។

ម្យ៉ាងទៀត ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ចូលបង្ហាញខ្លួននៅពេលសវនាការ ឬមានអ្នកតំណាងត្រឹមត្រូវ សាលក្រមគឺជាសាលក្រមចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ហើយសាលក្រមចំពោះមុខនេះមិនត្រូវឱ្យដំណឹងដល់សាមីខ្លួនទេ។

### ២.២ សាលក្រមដែលចាត់ទុកថាចំពោះមុខ

ប្រសិនបើជនជាប់ចោទមិនចូលមកបង្ហាញខ្លួននៅពេលសវនាការទេ ប៉ុន្តែសាមីខ្លួនបានដឹងអំពីដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬបានដឹងពីការកោះហៅហើយនោះសាលក្រមត្រូវចាត់ទុកថាជាសាលក្រមចំពោះមុខជនជាប់ចោទ។

សាលក្រមដែលចាត់ទុកថាចំពោះមុខនេះ ត្រូវជូនដំណឹងដល់ជនជាប់ចោទ និងសាលក្រម

---

[160] មាត្រា ៣៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

នេះអាចត្រូវប្ដឹងឧទ្ធរណ៍បាន[161]។

ក្នុងករណីជនជាប់ចោទអវត្តមានបានបង្ហាញនូវមូលហេតុអំពីការអវត្តមានរបស់ខ្លួន ហើយតុលាការក៏បានទទួលថាត្រឹមត្រូវនោះ តុលាការអាចលើករឿងនេះទៅជំនុំជម្រះនៅសវនាការមួយក្រោយទៀតបាន។

### ២.៣ សាលក្រមកំបាំងមុខ

ប្រសិនបើជនជាប់ចោទមិនចូលបង្ហាញខ្លួននៅពេលសវនាការទេ ហើយនិងប្រសិនបើគ្មានភស្តុតាងបង្ហាញឱ្យឃើញថាសាមីខ្លួនដឹងពីដីកាបញ្ជូនទៅជំនុំជម្រះ ឬបានដឹងអំពីការកោះហៅនោះទេ សាលក្រមត្រូវប្រកាសដោយកំបាំងមុខជនជាប់ចោទ។ សាលក្រមកំបាំងមុខជនជាប់ចោទត្រូវឱ្យដំណឹងដល់ជនជាប់ចោទនេះ ហើយសាលក្រមនេះអាចប្ដឹងទាស់បាន[162]។

ម្យ៉ាងទៀត ប្រសិនបើដើមបណ្ដឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី មិនចូលបង្ហាញខ្លួននៅពេលសវនាការទេ និងគ្មានអ្នកតំណាងត្រឹមត្រូវនោះទេ សាលក្រមត្រូវប្រកាសដោយកំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី។ សាលក្រមកំបាំងមុខនេះ ត្រូវជូនដំណឹងដល់ដើមបណ្ដឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ហើយសាលក្រមនេះអាចប្ដឹងទាស់បាន[163]។

## ៣. បណ្ដឹងទាស់ និងបណ្ដឹងឧទ្ធរណ៍ចំពោះសាលក្រម

### ៣.១ បណ្ដឹងទាស់

ពិរុទ្ធជនអាចធ្វើបណ្ដឹងទាស់នឹងសាលក្រមដែលប្រកាសដោយកំបាំងមុខខ្លួនបាន[164]។ ក្នុងន័យនេះមានន័យថា បណ្ដឹងទាស់ជាបណ្ដឹងដែលធ្វើឡើងដើម្បីប្រឆាំងទៅនឹងសាលក្រមដែលបានប្រកាសឡើងដោយកំបាំងមុខពិរុទ្ធជន។ ក្រៅពីពិរុទ្ធជន ដើមបណ្ដឹងរដ្ឋប្បវេណីក៏អាចប្ដឹងទាស់នឹងសាលក្រម ដែលសម្រេចដោយកំបាំងមុខខ្លួនបានដែរ។

#### ៣.១.១ ទម្រង់នៃបណ្ដឹងទាស់

❖ **បណ្ដឹងទាស់ធ្វើឡើងដោយពិរុទ្ធជន**

---

[161] មាត្រា ៣៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[162] មាត្រា ៣៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[163] មាត្រា ៣៦៣ និង ៣៦៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[164] មាត្រា ៣៦៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

បណ្តឹងទាស់ត្រូវធ្វើដោយពាក្យប្តឹងជាលាយលក្ខណ៍អក្សរ[165]៖

- នៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម
- នៅចំពោះមុខព្រះរាជអាជ្ញា អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ឬនៅចំពោះមុខប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។

ករណីដែលពិរុទ្ធជនមានមេធាវីការពារខ្លួននោះ មេធាវីត្រូវតំណាងឱ្យពិរុទ្ធជននោះ។ មេធាវីត្រូវតែមានលិខិតអនុញ្ញាតឱ្យធ្វើបណ្តឹងទាស់។ ប៉ុន្តែ ចំពោះពិរុទ្ធជនជាអនីតិជនមិនអាចត្រូវមេធាវីជាអ្នកតំណាងឱ្យខ្លួននោះទេ គឺត្រូវតំណាងដោយឪពុក ម្តាយ ឬអ្នកអាណាព្យាបាល។ ករណីនេះអ្នកតំណាងមិនចាំបាច់មានលិខិតប្រគល់សិទ្ធិទេ។

អ្នកប្តឹងទាស់ត្រូវចុះហត្ថលេខាលើបណ្តឹងទាស់ ប៉ុន្តែប្រសិនបើអ្នកប្តឹងទាស់នោះមិនចេះចុះហត្ថលេខាទេ អ្នកប្តឹងទាស់អាចផ្តិតម្រាមដៃជំនួសបាន។

កាលណាទទួលបានពាក្យប្តឹងទាស់ ព្រះរាជអាជ្ញា អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ព្រមទាំងប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ត្រូវបញ្ជូនបណ្តឹងទាស់នោះភ្លាមទៅកាន់ក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម។

❖ **បណ្តឹងទាស់ធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី**

បណ្តឹងទាស់ត្រូវធ្វើជាលាយលក្ខណ៍អក្សរនៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម។

ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី អាចត្រូវបានតំណាងដោយមេធាវីសហព័ទ្ធ ឬញាតិលោហិតផ្ទាល់។ អ្នកតំណាងត្រូវមានលិខិតប្រគល់សិទ្ធិឱ្យប្តឹងទាស់។

### ៣.១.២ រយៈពេលនៃការធ្វើបណ្តឹងទាស់

❖ **បណ្តឹងទាស់ធ្វើឡើងដោយពិរុទ្ធជន**

បណ្តឹងទាស់ត្រូវតែធ្វើនៅក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ដោយផ្តើមគិត៖

- ពីថ្ងៃជូនដំណឹងអំពីសាលក្រមកំបាំងមុខ កាលណាសាលក្រមត្រូវបានប្រគល់ឱ្យពិរុទ្ធជនដោយផ្ទាល់ដៃ ឬ

[165] មាត្រា ៣៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

- ពីថ្ងៃដែលពិរុទ្ធជននេះបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម កាលណាសាលក្រមនេះមិនបានប្រគល់ឱ្យដល់ពិរុទ្ធជនដោយផ្ទាល់ដៃទេ។

ដូច្នេះ ពិរុទ្ធជនដែលមិនសុខចិត្តនឹងសាលក្រមកំបាំងមុខអាចមានសិទ្ធិប្តឹងទាស់បាននៅក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ដោយគិតចាប់ពីថ្ងៃដូចបានកំណត់ខាងលើនេះ។ នៅក្នុងករណីដែលរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ បានកន្លងផុតទៅ ពិរុទ្ធជនមិនបានប្តឹងទាស់នឹងសាលក្រមនេះទេ ខ្លួននឹងត្រូវបាត់បង់សិទ្ធិនៅក្នុងការប្តឹងទាស់នេះ ប៉ុន្តែពិរុទ្ធជននៅមានសិទ្ធិមួយទៀតគឺប្តឹងឧទ្ធរណ៍ទៅនឹងសាលក្រមកំបាំងមុខនោះទៅសាលាឧទ្ធរណ៍។

❖ **បណ្តឹងទាស់ធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី**

បណ្តឹងទាស់ត្រូវតែធ្វើនៅក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ដោយផ្តើមគិតពី[166]៖

- ថ្ងៃឱ្យដំណឹងអំពីសាលក្រមកំបាំងមុខ កាលណាសាលក្រមត្រូវបានប្រគល់ឱ្យដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណីដោយផ្ទាល់ដៃ ឬ
- ថ្ងៃដែលដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណីបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម កាលណាសាលក្រមនេះមិនបានប្រគល់ឱ្យដល់ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណីដោយផ្ទាល់ដៃទេ។

### ៣.១.៣ អានុភាពនៃបណ្តឹងទាស់

កាលណាបណ្តឹងទាស់ធ្វើឡើងប្រឆាំងទៅលើសាលក្រមទាំងមូល សាលក្រមនេះត្រូវទុកជាអសារបង់ ឯការអនុវត្តសាលក្រមត្រូវព្យួរ។ ចំពោះដីកាបង្គាប់ឱ្យចាប់ខ្លួនវិញ គឺនៅតែមានអានុភាព ចំណែកតុលាការនៅតែមានសមត្ថកិច្ច ដើម្បីសម្រេចពីការដោះលែងជនជាប់ចោទឱ្យមានសេរីភាពវិញ[167]។

កាលណាបណ្តឹងទាស់ធ្វើប្រឆាំងលើសេចក្តីសម្រេចផ្នែករដ្ឋប្បវេណី មានតែសេចក្តីសម្រេចផ្នែកនេះប៉ុណ្ណោះដែលត្រូវទុកជាអសារបង់។ ការអនុវត្តសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីត្រូវព្យួរ។

### ៣.២ បណ្តឹងឧទ្ធរណ៍

ជាគោលការណ៍ នៅពេលដែលភាគីបាត់បង់នូវសិទ្ធិនៅក្នុងការប្តឹងទាស់ទៅនឹងសាលក្រម

[166] មាត្រា ៣៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[167] មាត្រា ៣៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

កំបាំងមុខនោះ ភាគីមានសិទ្ធិប្ដឹងឧទ្ធរណ៍ទៅតាមការកំណត់ដោយច្បាប់។

ចំពោះបុគ្គលដែលមានសិទ្ធិធ្វើបណ្ដឹងឧទ្ធរណ៍បានមានដូចជា[168]៖

- ព្រះរាជអាជ្ញានៃតុលាការជាន់ដំបូង និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
- ពិរុទ្ធជន
- ដើមបណ្ដឹងរដ្ឋប្បវេណី ចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី
- អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី។

### ៣.២.១ ទម្រង់នៃបណ្ដឹងឧទ្ធរណ៍

**❖ បណ្ដឹងឧទ្ធរណ៍ធ្វើឡើងដោយ ព្រះរាជអាជ្ញា ពិរុទ្ធជន ឬដើមបណ្ដឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី**

ជាទូទៅ បណ្ដឹងឧទ្ធរណ៍ត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយធ្វើនៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម។ ករណីនេះ ពិរុទ្ធជនត្រូវបានតំណាងដោយមេធាវី ដោយមេធាវីត្រូវមានលិខិតប្រគល់សិទ្ធិឱ្យខ្លួនធ្វើបណ្ដឹងឧទ្ធរណ៍។ ករណីដែលពិរុទ្ធជនជាអនីតិជន អាចត្រូវបានតំណាងដោយឪពុក ម្ដាយ ឬអ្នកអាណាព្យាបាល។ ករណីនេះ អ្នកតំណាងមិនចាំបាច់មានលិខិតប្រគល់សិទ្ធិឱ្យធ្វើបណ្ដឹងឧទ្ធរណ៍ទេ[169]។

ដើមបណ្ដឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី អាចត្រូវបានតំណាងដោយមេធាវីសហព័ទ្ធ ឬញាតិលោហិតផ្ទាល់។ អ្នកតំណាងត្រូវមានលិខិតប្រគល់សិទ្ធិធ្វើបណ្ដឹងឧទ្ធរណ៍។

នៅពេលដែលពិនិត្យឃើញថាបណ្ដឹងឧទ្ធរណ៍មានលក្ខណៈត្រឹមត្រូវហើយ ក្រឡាបញ្ជីនឹងចុះបញ្ជីបណ្ដឹងឧទ្ធរណ៍នៅលើបញ្ជីពិសេស ដែលរក្សាទុកនៅក្នុងបញ្ជីនៃតុលាការ។ លិខិតបណ្ដឹងឧទ្ធរណ៍ត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី និងអ្នកប្ដឹងឧទ្ធរណ៍ ឬអ្នកតំណាង ដោយលិខិតប្រគល់សិទ្ធិត្រូវភ្ជាប់ទៅនឹងលិខិតប្ដឹងឧទ្ធរណ៍ដែលបញ្ចូលនៅក្នុងសំណុំរឿង។

**❖ បណ្ដឹងឧទ្ធរណ៍ធ្វើឡើងដោយអគ្គព្រះរាជអាជ្ញា**

ខុសពីនីតិវិធីនៃការប្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ពិរុទ្ធជន ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ដែលធ្វើពាក្យបណ្ដឹងឧទ្ធរណ៍ត្រូវដាក់នៅការិយាល័យរបស់ក្រឡាបញ្ជីនៃ

[168] មាត្រា ៣៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[169] មាត្រា ៣៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

តុលាការដែលបានប្រកាសសាលក្រម។ ចំណែកការប្ដឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា ត្រូវធ្វើតាមពាក្យប្ដឹងនៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍[170]។ ក្រោយទទួលបានពាក្យបណ្ដឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញាហើយ ក្រឡាបញ្ជីនឹងចុះលិខិតប្ដឹងឧទ្ធរណ៍នៅលើបញ្ជីពិសេសដែលរក្សាទុកនៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍។ ចំពោះលិខិតប្ដឹងឧទ្ធរណ៍ត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី និងអគ្គព្រះរាជអាជ្ញា។

### ៣.២.២ រយៈពេលនៃការប្ដឹងឧទ្ធរណ៍

❖ **រយៈពេលនៃការប្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញា**

ការប្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ត្រូវធ្វើនៅក្នុងរយៈពេល ១ (មួយ) ខែ។ ចំពោះរយៈពេលនៃការប្ដឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា គឺមានរយៈពេល ៣ (បី) ខែ ដោយរយៈពេលទាំងពីរនេះត្រូវគិតចាប់ពីថ្ងៃប្រកាសសាលក្រម[171]។

❖ **រយៈពេលនៃការប្ដឹងឧទ្ធរណ៍របស់ពិរុទ្ធជន ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី**

ការប្ដឹងឧទ្ធរណ៍របស់ពិរុទ្ធជន ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីត្រូវតែធ្វើក្នុងរយៈពេល ១ (មួយ) ខែ។ កាលណាសាលក្រមនោះជាសាលក្រមចំពោះមុខ រយៈពេលប្ដឹងឧទ្ធរណ៍ផ្ដើមគិតពីពេលប្រកាសសាលក្រម។ ជាមួយគ្នានេះ កាលបើសាលក្រមនោះជាសាលក្រមចាត់ទុកថាចំពោះមុខ រយៈពេលនៃការប្ដឹងឧទ្ធរណ៍ផ្ដើមគិតពីពេលទទួលដំណឹងសាលក្រម ទោះបីជាការឱ្យដំណឹងនេះធ្វើតាមនីតិវិធីណាក៏ដោយ[172]។

តាមអត្ថន័យខាងលើនេះអាចនាំឱ្យមានការបកស្រាយថា ការប្ដឹងឧទ្ធរណ៍ទៅនឹងសាលក្រមកំបាំងមុខ មិនអាចធ្វើទៅបាននោះទេ ដោយហេតុថាមាត្រា ៣៨២ អនុញ្ញាតឱ្យប្ដឹងឧទ្ធរណ៍តែអំពីសាលក្រមចំពោះមុខ និងសាលក្រមចាត់ទុកជាចំពោះមុខប៉ុណ្ណោះ។ ប៉ុន្តែក្នុងការអនុវត្តជាក់ស្ដែង ទោះបីជាសាលក្រមកំបាំងមុខក៏ដោយ ក៏អនុញ្ញាតឱ្យប្ដឹងឧទ្ធរណ៍បានដែរក្នុងករណីសាមីខ្លួនពុំមានបំណងប្ដឹងទាស់ទៅនឹងសាលក្រមកំបាំងមុខ ដោយជ្រើសរើសយកការប្ដឹងឧទ្ធរណ៍តែម្ដង។ ការប្ដឹង

---

170 មាត្រា ៣៧៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

171 មាត្រា ៣៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

172 មាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ឧទ្ធរណ៍នឹងសាលក្រមកំបាំងមុខ ត្រូវធ្វើក្នុងរយៈពេល ១ (មួយ) ខែ ដែលកំណត់ដោយច្បាប់ ដោយផ្តើមគិតពីពេលទទួលដំណឹងពីសាលក្រមកំបាំងមុខ។ ការទទួលយកបណ្តឹងឧទ្ធរណ៍នឹងសាលក្រមកំបាំងមុខ ថ្វីត្បិតតែក្រមនីតិវិធីព្រហ្មទណ្ឌពុំបានចែងច្បាស់ក៏ដោយ តែក៏ពុំផ្ទុយនឹងច្បាប់ដែរ ដោយហេតុថាក្រមនីតិវិធីព្រហ្មទណ្ឌ ពុំបានហាមឃាត់ការប្តឹងឧទ្ធរណ៍ទៅនឹងសាលក្រមកំបាំងមុខទេ។ ម្យ៉ាងវិញទៀត ក្រមនីតិវិធីព្រហ្មទណ្ឌក៏អនុញ្ញាតឱ្យសាមីខ្លួនប្តឹងទៅនឹងសាលក្រមដែលសម្រេចលើបណ្តឹងទាស់ទៀតផង ដូច្នេះ កាលបើសាមីខ្លួនមិនប្រើសិទ្ធិក្នុងការប្តឹងទាស់ទៅនឹងសាលក្រមកំបាំងមុខក៏មិនជាការខុសឆ្គងអ្វីដែរ។

លើសពីនេះ មាត្រា ៣៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌផ្តល់រយៈពេលបន្ថែមសម្រាប់ធ្វើបណ្តឹងឧទ្ធរណ៍ក្នុងករណីជាបណ្តឹងឧទ្ធរណ៍ឧប្បត្តិហេតុ ដោយមាត្រានេះបានចែងថា ក្នុងករណីដែលភាគីណាមួយបានប្តឹងឧទ្ធរណ៍នៅក្នុងរយៈពេលខាងលើនេះ ភាគីដទៃទៀតនៅមានរយៈពេលបន្ថែម ៧ (ប្រាំពីរ) ថ្ងៃ ដើម្បីធ្វើបណ្តឹងឧទ្ធរណ៍ឧប្បត្តិហេតុ។ រយៈពេលបន្ថែមនេះ ផ្តើមគិតពីការផុតរយៈពេលធម្មតា។

កាលណាសាលាឧទ្ធរណ៍យល់ឃើញថាបណ្តឹងឧទ្ធរណ៍ធ្វើហួសពេលកំណត់ ឬធ្វើនៅក្នុងលក្ខខណ្ឌមិនត្រឹមត្រូវនោះ សាលាឧទ្ធរណ៍ប្រកាសថាបណ្តឹងឧទ្ធរណ៍មិនអាចទទួលយកបាន[173]។

### ៣.២.៣ អានុភាពនៃបណ្តឹងឧទ្ធរណ៍

- **អានុភាពផ្ទេរនៃបណ្តឹងឧទ្ធរណ៍**

សំណុំរឿងត្រូវបានផ្ទេរជូនសាលាឧទ្ធរណ៍ ក្នុងព្រំដែនដែលកំណត់ដោយលិខិតប្តឹងឧទ្ធរណ៍ និងតាមឋានៈរបស់អ្នកប្តឹងឧទ្ធរណ៍[174]។ មានន័យថា នៅពេលដែលសាលាឧទ្ធរណ៍បានទទួលពាក្យប្តឹងឧទ្ធរណ៍ហើយ សាលាឧទ្ធរណ៍នឹងមានសមត្ថកិច្ចជំនុំជម្រះនៅលើរឿងក្តីនេះ ដូច្នេះសាលាដំបូងដែលបានធ្វើការប្រកាសសាលក្រម ត្រូវបញ្ជូននូវសំណុំរឿងទាំងអស់ជូនទៅសាលាឧទ្ធរណ៍ដើម្បីធ្វើការពិនិត្យ។

- **អានុភាពនៃបណ្តឹងឧទ្ធរណ៍លើការអនុវត្តសាលក្រម**

នៅក្នុងរយៈពេលប្តឹងឧទ្ធរណ៍ ការអនុវត្តសាលក្រមត្រូវបង្អង់សិន។ ប៉ុន្តែជនជាប់ចោទដែល

[173] មាត្រា ៤០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[174] មាត្រា ៣៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ជាប់ឃុំដែលបានចូលបង្ហាញខ្លួន នៅមុខតុលាការជាន់ដំបូងត្រូវនៅក្នុងពន្ធនាគារនៅក្នុងរយៈពេលសម្រាប់ប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា និងក្នុងករណីមានបណ្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចខាងបទព្រហ្មទណ្ឌ ជនជាប់ចោទនឹងត្រូវនៅក្នុងពន្ធនាគាររហូតដល់ពេលសាលាឧទ្ធរណ៍សម្រេច។ ក្នុងករណីដែលតុលាការជាន់ដំបូងបានសម្រេចឱ្យរួចខ្លួន ឬបានផ្តន្ទាទោសដាក់ពន្ធនាគារ រយៈពេលតិចជាង ឬស្មើនឹងរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន ព្រះរាជអាជ្ញាអាចយល់ព្រមដោះលែងជនជាប់ចោទឱ្យមានសេរីភាព មុនពេលផុតកំណត់នៃរយៈពេលសម្រាប់ប្តឹងឧទ្ធរណ៍។ ទោះជាយ៉ាងណា រយៈពេលសម្រាប់ប្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញាមិនមែនជាឧបសគ្គដល់ការអនុវត្តទោសឡើយ[175]។

❖ **អានុភាពនៃបណ្តឹងឧទ្ធរណ៍តែពីជនជាប់ចោទ**

សាលាឧទ្ធរណ៍កាលណាបានទទួលបណ្តឹងឧទ្ធរណ៍តែពីជនជាប់ចោទ មិនអាចដាក់ទម្ងន់ទោសជននោះ ឬបន្ថែមទោសបន្ថែមពីលើមូលទោស ឬបន្ថែមចំនួនទឹកប្រាក់សម្រាប់ជួសជុលការខូចខាតឱ្យដល់ដើមបណ្តឹងរដ្ឋប្បវេណីទេ។ ប៉ុន្តែ សាលាឧទ្ធរណ៍អាចកែប្រែសាលក្រមបាននៅក្នុងន័យដែលអនុគ្រោះដល់ជនជាប់ចោទ ឬអាចជំនួសឈ្មោះបទល្មើសដែលកំណត់ដោយតុលាការជាន់ដំបូង ដោយឈ្មោះបទល្មើសមួយទៀតបាន[176]។ ម្យ៉ាងទៀត ប្រសិនបើតុលាការជាន់ដំបូងភ្លេចប្រកាសទោសបន្ថែមណាមួយដែលដាច់ខាតត្រូវតែប្រកាសនោះ សាលាឧទ្ធរណ៍អាចបដិសេធនូវសាលក្រមហើយសម្រេចអំពីទោសជាថ្មីម្តងទៀត។

❖ **អានុភាពនៃបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញា**

បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញា គឺនាំឱ្យមានការសើរើឡើងវិញនូវសេចក្តីសម្រេចខាងព្រហ្មទណ្ឌនៃតុលាការជាន់ដំបូង។ លើសពីនេះ សាលាឧទ្ធរណ៍អាចបដិសេធសាលក្រមដែលសម្រេចឱ្យរួចខ្លួន ឬអាចសម្រេចដាក់ទម្ងន់ទោសដែលបានប្រកាសដោយតុលាការជាន់ដំបូង។ សាលាឧទ្ធរណ៍ក៏អាចសម្រេចឱ្យជនជាប់ចោទរួចខ្លួនជានិច្ច ប្រសិនបើយល់ឃើញថាពិរុទ្ធភាពលើជននេះមិនអាចបង្ហាញឱ្យឃើញទេ[177]។

---

[175] មាត្រា ៣៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[176] មាត្រា ៣៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[177] មាត្រា ៤០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

❖ **អានុភាពនៃបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី**

បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីអាចធ្វើបានតែលើផលប្រយោជន៍ផ្នែករដ្ឋប្បវេណីប៉ុណ្ណោះ[178]។ នៅមុខសាលាឧទ្ធរណ៍ ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចធ្វើពាក្យប្តឹងសុំថ្មីដែលមិនបានដាក់ជូនតុលាការពិនិត្យនោះទេ។

[178] មាត្រា ៤០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

# សេចក្តីសន្និដ្ឋាន

រាល់ការចាប់ផ្តើមទាំងឡាយតែងតែមាននូវសេចក្តីបញ្ចប់ ដែលជាការសរុបនូវលទ្ធផលមួយ ដើម្បីធ្វើការបញ្ជាក់ពីការងារដែលបានបំពេញចំពោះហេតុការណ៍ដែលបានកើតឡើង។ ជាក់ស្តែង ក្រោយពីធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទ " **ដំណើរការរឿងក្តីព្រហ្មទណ្ឌនៅសាលាដំបូងខេត្តបាត់ដំបង**" ដើម្បីចងក្រងជាសារណាមួយនេះអស់ពេលមួយរយៈមក ក្រុមយើងខ្ញុំបានសង្កេត និងកត់សម្គាល់ឃើញថា ក្នុងការងារប្រតិបត្តិនូវនីតិវិធីព្រហ្មទណ្ឌ វាជាភារកិច្ចមួយដែលមិនមែនជាការងារងាយស្រួលនោះទេ ដោយត្រូវគោរពលក្ខខណ្ឌជាច្រើនដើម្បីដំណើរការ។

ជាការពិតណាស់ ចំពោះចំណាត់ការលើរឿងក្តីព្រហ្មទណ្ឌនៃសាលាដំបូងខេត្តបាត់ដំបង មានលក្ខណៈមិនខុសពីបទប្បញ្ញត្តិដែលបានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ ប៉ុន្មានទេ។ នៅពេលមាននូវរឿងក្តីព្រហ្មទណ្ឌណាមួយបានកើតឡើង ក្នុងដំណាក់កាលដំបូងបានតម្រូវទៅលើសមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលមានភារកិច្ចទទួលនូវបណ្តឹងទាមទារ និងបណ្តឹងបរិហារ ហើយធ្វើកំណត់ហេតុតាមសេចក្តីរាយការណ៍របស់អ្នកដែលបានប្តឹង។ ម្យ៉ាងទៀត មន្ត្រីនគរបាលយុត្តិធម៌មានតួនាទីក្នុងការត្រួតពិនិត្យបទល្មើស តាមរយៈការស៊ើបអង្កេតបទល្មើសជាក់ស្តែង និងការស៊ើបអង្កេតបឋម ដើម្បីស្វែងរកភស្តុតាងអាចឱ្យព្រះរាជអាជ្ញាឈានដល់ការចោទប្រកាន់។

ក្រោយពីនីតិវិធីនៃការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌បានបញ្ចប់ នីតិវិធីបន្តគឺត្រូវបានប្រគល់ទៅឱ្យអយ្យការ។ អយ្យការត្រូវធ្វើការត្រួតពិនិត្យទៅលើរបាយការណ៍ដែលទទួលបានពីមន្ត្រីនគរបាលយុត្តិធម៌ដើម្បីធ្វើការសម្រេចចិត្តថា គួរធ្វើការចោទប្រកាន់ ឬតម្កល់រឿងទុកឥតចាត់ការ។ ករណីបើសិនជារឿងក្តីនោះជាប្រភេទរឿងក្តីរដ្ឋប្បវេណី មិនមែនជារឿងក្តីព្រហ្មទណ្ឌ ឬមិនបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីអាចធ្វើការចោទប្រកាន់បាន នោះព្រះរាជអាជ្ញានឹងចេញដីកាតម្កល់រឿងទុកឥតចាត់ការ ដោយមានទាំងសំអាងច្បាប់ និងសំអាងហេតុ។ ផ្ទុយទៅវិញ ករណីប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថា រឿងក្តីនោះជារឿងក្តីព្រហ្មទណ្ឌដែលមានភស្តុតាងពិរុទ្ធភាពគ្រប់គ្រាន់ អាចដាក់បន្ទុកទៅលើជនសង្ស័យបាននោះព្រះរាជអាជ្ញានឹងមានចំណាត់ការដើម្បីធ្វើការចោទប្រកាន់ ដោយការចោទប្រកាន់របស់ព្រះរាជអាជ្ញាអាចធ្វើទៅបានតាមរយៈបីរបៀបគឺ ទីមួយការប្តឹងទៅយុត្តាធិការស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ក្នុងករណីបទល្មើសឧក្រិដ្ឋជាក់ស្តែង ឬមិនជាក់ស្តែង និងករណីបទល្មើសមជ្ឈិមដែលព្រះរាជអាជ្ញាយល់ឃើញថាត្រូវឱ្យ

ការបើកការស៊ើបសួរ។ ទីពីរ ការប្ដឹងទៅយុត្តាធិការជំនុំជម្រះតាមរយៈការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ក្នុងករណីចំពោះបទល្មើសមជ្ឈិម និងបទល្មើសលហុ និងទីបី គឺការធ្វើកំណត់ហេតុបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម ក្នុងករណីបទមជ្ឈិមជាក់ស្ដែងដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច ១ (មួយ) ឆ្នាំ និងយ៉ាងច្រើន ៥ (ប្រាំ) ឆ្នាំ ហើយប្រព្រឹត្តដោយនីតិជន និងសំណុំរឿងស្ថិតនៅក្នុងស្ថានភាពដែលអាចជំនុំជម្រះបាន។

បន្ទាប់ពីដំណាក់កាលនៃចោទប្រកាន់របស់អយ្យការរួចមក នីតិវិធីបន្ទាប់គឺជាដំណាក់កាលស៊ើបសួររបស់ចៅក្រមស៊ើបសួរ ដោយការស៊ើបសួរនេះអាចបើកបានតាមរយៈមធ្យោបាយពីរយ៉ាង គឺការបើកការស៊ើបសួរដោយអយ្យការតាមរយៈដីការសន្និដ្ឋានស៊ើបសួរ និងមធ្យោបាយមួយទៀតគឺការបើកការស៊ើបសួរដោយភាគីជនរងគ្រោះតាមរយៈការទទួលនូវពាក្យបណ្ដឹងពីជនរងគ្រោះដោយការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។ កាលបើការស៊ើបសួររបស់ចៅក្រមស៊ើបសួរត្រូវបានបញ្ចប់ ចៅក្រមស៊ើបសួរអាចបិទការស៊ើបសួរបានតាមរយៈការចេញនូវដីកាដំណោះស្រាយ ដែលត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវី។ ដីកាដំណោះស្រាយនោះអាចជាដីកាលើកលែងការចោទប្រកាន់ ឬដីកាបញ្ជូនទៅជំនុំជម្រះ។ ចៅក្រមស៊ើបសួរនឹងចេញដីកាលើកលែងការចោទប្រកាន់ ក្នុងករណីអំពើនោះមិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ជនដែលប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់ និងគ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ។ទោះជាយ៉ាងណា សេចក្ដីសម្រេចលើកលែងការចោទប្រកាន់របស់ចៅក្រមស៊ើបសួរនេះមិនមានអានុភាពបិទផ្លូវប្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណីនោះឡើយ។ តែផ្ទុយទៅវិញ ចៅក្រមស៊ើបសួរនឹងសម្រេចចេញនូវដីកាបញ្ជូនខ្លួនជនត្រូវចោទទៅជំនុំជម្រះ ករណីយល់ឃើញថាអំពើនោះជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ។

កាលណាដំណាក់កាលស៊ើបសួររបស់ចៅក្រមស៊ើបសួរត្រូវបានបញ្ចប់ ប្រសិនបើចៅក្រមស៊ើបសួរបានធ្វើការសម្រេចចេញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ចៅក្រមស៊ើបសួរត្រូវតែបញ្ជូនសំណុំរឿងជាបន្ទាន់ទៅប្រធានតុលាការដើម្បីកំណត់ពេលសវនាការជំនុំជម្រះ និងកំណត់ពីសមាសភាពនៃចៅក្រមជំនុំជម្រះ ឬក្រុមប្រឹក្សាជំនុំជម្រះ។ ចំណែកឯព្រះរាជអាជ្ញាមានតួនាទីក្នុងការកោះហៅភាគីឱ្យចូលខ្លួនចូលរួមក្នុងសវនាការតាមរយៈដីកាកោះហៅ។ លុះដល់កាលបរិច្ឆេទនៃការបើកសវនាការ កិច្ចពិភាក្សាដេញដោលត្រូវបានប្រព្រឹត្តឡើងជាសាធារណៈដោយមានការដឹកនាំ

របស់ចៅក្រមជំនុំជម្រះ ឬប្រធានសវនាការ។ ក្នុងកិច្ចពិភាក្សាដេញដោលនេះរួមមាន ការសួរចម្លើយ ការស្តាប់ចម្លើយរបស់ភាគី ឬអាចមានការថ្លឹងថ្លែងពីតម្លៃភស្តុតាងដែលបានដាក់ជូនឱ្យតុលាការធ្វើការពិនិត្យ។ ក្រោយពីបិទកិច្ចពិភាក្សាដេញដោល តុលាការត្រូវធ្វើនូវសេចក្តីសម្រេចតាមរយៈការចេញសាលក្រម ដែលសាលក្រមនេះនឹងត្រូវបានធ្វើការប្រកាសជាសាធារណៈដោយចៅក្រមជំនុំជម្រះ ឬប្រធានសវនាការ។ សាលក្រមដែលចេញដោយតុលាការអាចជាសាលក្រមចំពោះមុខ ឬជាសាលក្រមដែលត្រូវចាត់ទុកថាចំពោះមុខ ឬអាចជាសាលក្រមកំបាំងមុខ។ ចំពោះសាលក្រមដែលចាត់ទុកថាចំពោះមុខ និងសាលក្រមកំបាំងមុខ ច្បាប់តម្រូវឱ្យមានការជូនដំណឹងទៅដល់ភាគី ហើយមានតែសាលក្រមកំបាំងមុខតែប៉ុណ្ណោះដែលក្នុងនាមជាជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិប្តឹងទាស់ប្រឆាំងទៅលើសាលក្រម ដែលបានចេញដោយសាលាដំបូងដោយត្រូវគោរពនូវលក្ខខណ្ឌមួយចំនួននៃការប្តឹងទាស់រួមមានដូចជា ត្រូវបំពេញនូវទម្រង់នៃបណ្តឹងទាស់ និងថិរវេលានៃការធ្វើបណ្តឹងទាស់ ដែលបានបញ្ញត្តិក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ ។ ករណីបើជនជាប់ចោទ ឬដើមបណ្តឹង រដ្ឋប្បវេណីខកខានមិនបានធ្វើបណ្តឹងទាស់នោះទេ ជនទាំងនោះនៅមានផ្លូវប្តឹងតវ៉ាមួយផ្សេងទៀតនោះគឺការធ្វើប្តឹងឧទ្ធរណ៍។ មិនតែប៉ុណ្ណោះ សាលក្រមចំពោះមុខ និងសាលក្រមដែលចាត់ទុកថាចំពោះក៏បានបើកសិទ្ធិឱ្យជនជាប់ចោទមានលទ្ធភាពក្នុងការប្តឹងឧទ្ធរណ៍ផងដែរ។ ទោះជាយ៉ាងណាចំពោះការប្តឹងឧទ្ធរណ៍ក៏ត្រូវបំពេញទម្រង់នៃការប្តឹងនោះឱ្យបានត្រឹមត្រូវ និងគោរពនូវថិរវេលាដែលច្បាប់បានកំណត់ផងដែរ បើពុំដូច្នោះទេការប្តឹងឧទ្ធរណ៍នោះនឹងត្រូវបានចាត់ទុកជាមោឃៈ។

# ការផ្តល់អនុសាសន៍

យើងសង្កេតឃើញថា ខេត្តបាត់ដំបងត្រូវបានគេចាត់ទុកថាគឺជាខេត្តមួយដែលមានចំនួនប្រជាជនច្រើនជាងគេ បើធ្វើការប្រៀបធៀបទៅនឹងបណ្តាខេត្តនានានៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង។ ដោយហេតុតែខេត្តនេះមានចំនួនប្រជាជនច្រើនបែបនេះហើយ ដែលជាកត្តានាំឱ្យខេត្តនេះកើតមាននូវបទល្មើសផ្សេងៗជាច្រើនគួរឱ្យកត់សម្គាល់។ បើយើងងាកទៅមើលសមាសភាពនៃមន្រ្តីនៅក្នុងសាលាដំបូងខេត្តបាត់ដំបង និងចំនួនរឿងក្តីដែលតុលាការនេះទទួលបានវិញ ព្រមទាំងមើលទៅលើលទ្ធភាពក្នុងការធ្វើចំណាត់ការលើរឿងក្តីទាំងនោះ យើងឃើញថាក្នុងអំឡុងពេលមួយឆ្នាំៗតែងតែមានសល់នូវរឿងក្តីពីឆ្នាំមុនៗចាប់ពី ២៥០ រឿងក្តីឡើងទៅ យើងអាចធ្វើការសន្និដ្ឋានបានថាចំនួនមន្រ្តីនៅក្នុងតុលាការនេះ នៅពុំទាន់មានចំនួនគ្រប់គ្រាន់សមតុល្យទៅនឹងរឿងក្តីដែលចូលមកនៅឡើយទេ ដោយសព្វថ្ងៃនេះមិនថាទាំងប្រធានសាលាដំបូង អនុប្រធានសាលាដំបូង ចៅក្រមព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង ឬទាំងក្រឡាបញ្ជីនោះទេ គឺពួកគាត់មានភាពមមាញឹកយ៉ាងខ្លាំងក្នុងការធ្វើចំណាត់ការទៅលើរឿងក្តីដែលតុលាការទទួលបានទាំងឡាយ។ ជាក់ស្តែង នាពេលបច្ចុប្បន្ននេះនៅសាលាដំបូងខេត្តបាត់ដំបងមានចៅក្រមចំនួន ០៩រូប គិតរួមទាំងប្រធានសាលាដំបូង និងអនុប្រធានសាលាដំបូង ឯផ្នែកខាងតំណាងអយ្យការមានចំនួន ០៦រូប គិតរួមទាំងព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ដែលនៅក្នុងចំណោមចៅក្រម ឬតំណាងអយ្យការនីមួយៗមានចៅក្រម ឬតំណាងអយ្យការរូបខ្លះមានក្រឡាបញ្ជីជាជំនួយការផ្ទាល់ខ្លួនចំនួន ០២រូប ឯចៅក្រម ឬតំណាងអយ្យការរូបខ្លះទៀតគឺមានក្រឡាបញ្ជីជាជំនួយការផ្ទាល់ខ្លួន ០១រូប តែប៉ុណ្ណោះ។ ដូច្នេះ ដើម្បីអាចបំពេញការងារឱ្យបានលឿន និងសមស្របទៅតាមនឹងកំណើននៃរឿងក្តីជាប្រចាំបែបនេះ សាលាដំបូងខេត្តបាត់ដំបងគប្បីគួរតែធ្វើការបំពេញបន្ថែមនូវក្រឡាបញ្ជីថែមទៀត គឺធ្វើយ៉ាងណាឱ្យក្នុងចំនួនចៅក្រម ឬតំណាងអយ្យការមួយរូប មានលទ្ធភាពអាចមានក្រឡាបញ្ជីជាជំនួយការផ្ទាល់របស់ខ្លួនយ៉ាងតិចមានចំនួន ០៣រូប ដើម្បីអាចជួយសម្រួលការងារដល់ចៅក្រម ឬតំណាងអយ្យការឱ្យអាចធ្វើចំណាត់ការរឿងក្តីទាំងឡាយបានលឿនស្របទៅនឹងកំណើននៃរឿងក្តី ជៀសវាងការរាំងស្ទះការងារ។

បើផ្អែកលើចំនួនបទល្មើសទាំងឡាយដែលកើតមានជារៀងរាល់ថ្ងៃនេះ យើងយល់ឃើញថាមិនគួរបណ្តែតបណ្តោយឱ្យបទល្មើសទាំងនោះ នៅតែបន្តកើតឡើងឥតឈប់ឈរបែបនេះឡើយ។ ក្នុងករណីនេះ យើងយល់ថាមន្រ្តីតុលាការ ក៏ដូចជាអាជ្ញាធរដែលមានសមត្ថកិច្ចពាក់ព័ន្ធទាំងឡាយ

គួរតែបង្កើននូវការបង្កើតឱ្យមានកម្មវិធី ដែលអាចធ្វើការបញ្ជ្រៀបនូវចំណេះដឹងផ្នែកច្បាប់មួយចំនួនដល់ថ្នាក់មូលដ្ឋាន ទាក់ទងនឹងបទល្មើសដែលតែងតែកើតឡើងជាញឹកញាប់នៅក្នុងខេត្តបាត់ដំបងដោយគួរផ្តោតសំខាន់លើប្រជាពលរដ្ឋដែលរស់នៅតាមតំបន់ដាច់ស្រយាល ព្រមទាំងប្រជាពលរដ្ឋទាំងឡាយដែលមានចំណេះដឹងនៅមានកម្រិតនៅឡើយ ដែលជាហេតុនាំឱ្យងាយនឹងត្រូវជនខិលខូចអាចអូសទាញ ឬបោកប្រាស់បានដោយងាយស្រួល។ ដូច្នេះ គប្បីផ្តល់ជាព័ត៌មានផ្នែកច្បាប់ដល់ពួកគាត់ឱ្យបានយល់ដឹងខ្លះ ដើម្បីឱ្យយល់ពីផលលំបាកកាលបើពួកគាត់បានទៅប្រព្រឹត្តអំពើនានាដែលច្បាប់បានកំណត់ថាវាជាបទល្មើសនោះ ហើយវាក៏អាចជាកត្តាមួយដែលអាចដាស់តឿនដល់សតិអារម្មណ៍របស់ពួកគាត់ឱ្យខ្លាចរអានឹងប្រព្រឹត្តនូវអំពើទាំងនោះផងដែរ។ ក្រៅពីការបញ្ជ្រៀបនូវចំណេះដឹងនេះដែរ ក្នុងនាមជាមន្ត្រីមានសមត្ថកិច្ចគួរតែបន្តនូវការខិតខំប្រឹងប្រែងធ្វើយ៉ាងណាអាចបង្ក្រាបឱ្យបាននូវជនដែលបង្កភាពអាណាធិបតេយ្យនៅក្នុងសង្គមឱ្យបាន ហើយយកមកផ្តន្ទាទោសទៅតាមនីតិវិធីច្បាប់ដែលបានកំណត់ជាធរមាន ដើម្បីឱ្យជនទាំងនោះទទួលបានភាពរាងចាលក្នុងការប្រព្រឹត្តអំពើល្មើសទាំងនោះតទៅទៀត និងក៏ដើម្បីរក្សាឱ្យបាននូវស្ថេរភាព ព្រមទាំងសន្តិសុខនៅក្នុងសង្គមជូនដល់ប្រជាពលរដ្ឋផងដែរ។

ក្រៅពីនេះយើងក៏នៅមើលឃើញថា សម្ភារៈការិយាល័យសម្រាប់មន្ត្រីក្នុងសាលាដំបូងខេត្តបាត់ដំបងនេះក៏នៅមានភាពខ្វះខាតនៅឡើយ។ ជាក់ស្តែង នាពេលបច្ចុប្បន្ននេះដោយសារតែមានតម្រូវការនូវសម្ភារៈការិយាល័យមួយចំនួនជាចាំបាច់ ដើម្បីអាចដំណើរការបំពេញការងារបានងាយស្រួល និងទាន់ពេលវេលា មន្ត្រីតុលាការមួយចំនួនបានចំណាយនូវថវិកាផ្ទាល់ខ្លួន។ ដូចនេះ ត្រង់ករណីនេះ ក្រសួងយុត្តិធម៌ដែលគឺជាក្រសួងពាក់ព័ន្ធគប្បីគួរតែយកចិត្តទុកដាក់ទៅលើចំណុចនេះធ្វើយ៉ាងណាឱ្យអាចផ្តល់ជាសម្ភារៈ សម្រាប់បំពេញការងារដល់មន្ត្រីតុលាការគ្រប់ៗរូបឱ្យបានគ្រប់គ្រាន់ ដើម្បីគឺជាកត្តាមួយដែលអាចជួយជម្រុញឱ្យការបំពេញការងាររបស់មន្ត្រីក្នុងសាលាដំបូងខេត្តបាត់ដំបងនេះកាន់តែមានប្រសិទ្ធភាពប្រសើរឡើង និងមានភាពរហ័សទាន់នឹងសភាពការណ៍។

# ឯកសារពិគ្រោះ

## ១. កម្រងឯកសារច្បាប់

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣
- ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧
- ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញាឆ្នាំ ២០១៤
- ច្បាប់ស្តីពីការរៀបចំអង្គការតុលាការឆ្នាំ ២០១៤
- សៀវភៅនីតិវិធីព្រហ្មទណ្ឌសម្រាប់នគរបាលឆ្នាំ ២០០៩
- ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៤

## ២. កម្រងឯកសារមេរៀន

- សៀវភៅមេរៀននីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត (បោះពុម្ពឆ្នាំ ២០១៥)
- មេរៀននីតិវិធីព្រហ្មទណ្ឌ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ (បោះពុម្ពឆ្នាំ ២០០៧)
- សៀវភៅក្រឡាបញ្ជីតុលាការ និងអយ្យការក្នុងរឿងព្រហ្មទណ្ឌ និពន្ធដោយលោក ហ៊ីង ធីឬទ្ធិ (បោះពុម្ពឆ្នាំ ២០០៤)
- សៀវភៅទ្រឹស្តីនីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយលោកសាស្ត្រាចារ្យ អៀង សំណាង (បោះពុម្ពឆ្នាំ ២០១៥)
- សៀវភៅដំណើរការរឿងក្តីព្រហ្មទណ្ឌនៅកម្ពុជាបច្ចុប្បន្ន និពន្ធដោយវរសេនីយ៍ទោ អាន សូរីដា (បោះពុម្ពឆ្នាំ ២០១៤)
- សៀវភៅសំណួរ-ចម្លើយអំពីនីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយ អៀង សំណាង (បោះពុម្ពឆ្នាំ ២០១៦)